PhillipBank



# របាយការណ៍ប្រចាំឆ្នាំ

# 2023

1. ទិដ្ឋភាពទូទៅ

- សារតារធនាគារ
- ចក្ខុវិស័យ និងបេសកកម្មរបស់ធនាគារ
- សេចក្តីថ្លែងការណ៍ប្រធានក្រុមប្រឹក្សាភិបាល

6. ការពិនិត្យមើលធុរកិច្ច

- អាទិភាពរបស់អាជីវកម្ម
- អនុសាសន៍របស់អតិថិជន
- ទំនួលខុសត្រូវសង្គម
- សេចក្តីសង្ខេបផ្នែកហិរញ្ញវត្ថុ
- សេចក្តីសង្ខេបផ្នែកហិរញ្ញវត្ថុរយៈពេល 2 ឆ្នាំ
- ការវិភាគលើលទ្ធផលហិរញ្ញវត្ថុ
- គោលនយោបាយ និងគោលការណ៍អនុវត្តន៍សម្រាប់អភិបាលកិច្ចក្រុមហ៊ុន
- ធនាគារ ហ្វីលីព នៅក្នុងទំព័រព័ត៌មាន

33. អភិបាលកិច្ចធនាគារ

- ប្រវត្តិរូបក្រុមប្រឹក្សាភិបាល
- ប្រវត្តិរូបគណៈគ្រប់គ្រង
- រចនាសម្ព័ន្ធរបស់ធនាគារ ហ្វីលីព

47. ហិរញ្ញវត្ថុ

- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
  និងរបាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក
  ដែលបានធ្វើសវនកម្ម

# ទិដ្ឋភាពទូទៅ


- សាវតារធនាគារ ........ 02
- ចក្ខុវិស័យ និងបេសកកម្មរបស់ធនាគារ ........ 03
- សេចក្តីថ្លែងការណ៍ប្រធានក្រុមប្រឹក្សាភិបាល ........ 04


01

# សារធនាគារ

ធនាគារ ហ្វីលីព ភីអិលសុី គឺជាផ្នែកមួយនៃ PhillipCapitalគ្រុប ដែលមានការិយាល័យកណ្តាលនៅក្នុងប្រទេសសិង្ហបុរី ហើយត្រូវបានបង្កើតឡើងតាំងពីឆ្នាំ1975។

PhillipCapitalគ្រុប មានវត្តមាននៅលើបណ្តាប្រទេសចំនួន 15 ដែលរួមមាន អូស្ត្រាលី កម្ពុជា ចិន (រួមបញ្ចូលហុងកុង) អេស្ប៉ាញ ឥណ្ឌា ឥណ្ឌូនេសុី ជប៉ុន ម៉ាឡេសុី សិង្ហបុរី ថៃ តួកគី ចក្រភពអង់គ្លេស អារ៉ាប់ សហរដ្ឋអាមេរិក និងវៀតណាម។

PhillipCapitalគ្រុប ផ្តល់ជូននូវផលិតផលប្រកបដោយភាពច្នៃប្រឌិតដែលមានគុណភាព និងសេវាកម្មទៅកាន់បុគ្គល អតិថិជនដែលមានទ្រព្យធនខ្ពស់ សាជីវកម្ម និងអតិថិជននៅតាមស្ថាប័ននានា។ ទាំងនេះរួមបញ្ចូលទាំងការជួញដូរមូលប័ត្រ ប័ណ្ណនាពេលអនាគត ការប្តូររូបិយវត្ថុ មូលប័ត្របំណុល លោហៈ និងទំនិញដ៏មានតម្លៃ កិច្ចសន្យា ការផ្លាស់ប្តូរមូលនិធិជួញដូរ ការគ្រប់គ្រងមូលនិធិ ការគ្រប់គ្រងគណនី ការធ្វើផែនការធានារ៉ាប់រង ផែនការសន្សំទៀងទាត់ ការស្រាវជ្រាវ ការវិនិយោគ ការផ្តល់ហិរញ្ញប្បទានទុន និងប្រឹក្សាយោបល់លើទ្រព្យសម្បត្តិ។

បណ្តាញក្រុមហ៊ុន PhillipCapitalគ្រុប បានរីកចម្រើនលើសកលលោកដែលជាក្រុមហ៊ុនហិរញ្ញវត្ថុអាស៊ីរួមបញ្ចូលគ្នា ដែលមានបុគ្គលិកច្រើនជាង 5,000នាក់ និងអតិថិជនច្រើនជាង 1លាននាក់ នៅទូទាំងពិភពលោក ហើយទ្រព្យសម្បត្តិស្ថិតនៅក្រោមការគ្រប់គ្រងលើស 50 ពាន់លានដុល្លារអាមេរិក និងមូលនិធិរបស់ម្ចាស់ភាគហ៊ុនលើសពី 1.5 ពាន់លានដុល្លារអាមេរិក។

PhillipCapitalគ្រុប បានឈានជើងចូលក្នុងប្រទេសកម្ពុជាជាលើកដំបូងក្នុងឆ្នាំ2009 ក្នុងការវិនិយោគលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ First Finance និងបន្ទាប់មកជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រេឌីត ក្នុងឆ្នាំ2012 និងធនាគារ ហ្វីលីព ក្នុងឆ្នាំ2014 ពេលដែលក្រុមហ៊ុនទិញធនាគារ ហ័ង ឌីប៊ីអេស និងប្តូរឈ្មោះជាធនាគារ ហ្វីលីព។ មុខងាររបស់យើងក្នុងនាមជាអ្នកផ្តល់ដំណោះស្រាយសេវាកម្មហិរញ្ញវត្ថុដ៏សំខាន់នៅក្នុងប្រទេសកម្ពុជាត្រូវបានពង្រីកបន្ថែមជាមួយនឹងការបន្ថែមនូវក្រុមហ៊ុនធានារ៉ាប់រង Phillip Life Assurance (Cambodia) Plc, ក្រុមហ៊ុន Phillip General Insurance (Cambodia) Plc និងក្រុមហ៊ុន Phillip Trustee (Cambodia) Co., Ltd.។

ធនាគារ ហ្វីលីព បច្ចុប្បន្នមានជាង 70សាខា នៅក្នុងប្រទេសកម្ពុជា ហើយយើងមានគម្រោងពង្រីកវត្តមានរបស់យើង នៅទូទាំងប្រទេសនៃព្រះរាជាណាចក្រកម្ពុជា។




**វត្តមានជាសកលរបស់ក្រុមហ៊ុន PhillipCapitalគ្រុប**

# ចក្ខុវិស័យរបស់ធនាគារ

- ផ្តល់ភាពពេញចិត្តដល់អតិថិជន
- កសាងធនធានមនុស្ស
- ចូលរួមចំណែកកសាងសហគមន៍

# បេសកកម្មរបស់ធនាគារ

ផ្តល់ជូននូវដំណោះស្រាយហិរញ្ញវត្ថុ ដែលប្រកបដោយភាពងាយស្រួល ច្នៃប្រឌិត និងទំនុកចិត្តដោយប្រើប្រាស់នូវបច្ចេកវិទ្យាទំនើបៗ រួមជាមួយនឹងកិច្ចសហការដ៏ល្អរវាងបុគ្គលិករបស់យើង ជាមួយដៃគូពាណិជ្ជកម្ម និងអតិថិជន ដើម្បីបង្កើនសុខុមាលភាពផ្នែកសេដ្ឋកិច្ចរបស់គ្រួសារនៅ តាមសហគមន៍ជនបទ និងទីក្រុងប្រកបដោយនិរន្តរភាព។



# សេចក្តីថ្លែងការណ៍ ប្រធានក្រុមប្រឹក្សាភិបាល



**លោក LIM HUA MIN**

បន្ទាប់ពីជំងឺកូវីដ-19 កាលពីប៉ុន្មានឆ្នាំកន្លងមកនេះ ប្រទេសកម្ពុជា ក៏ដូចជាប្រទេសដែលកំពុងរីកចម្រើនមួយចំនួនផ្សេងទៀត ហាក់មានភាពប្រសើរឡើងជាងមុនបន្តិចម្តងៗទៅលើផ្នែកសេដ្ឋកិច្ច នាឆ្នាំ2023។ បើយោងតាមធនាគារពិភពលោក កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាគឺ 5.4%។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្ហាញផងដែរថា GDP របស់ប្រទេសកម្ពុជាក្នុងឆ្នាំ2023 មានចំនួន 1,917 ដុល្លារ ហើយរំពឹងថានឹងកើនឡើងដល់ 2,071 ដុល្លារក្នុងឆ្នាំ2024 ។

ធនាគារ ហ្វីលីព មានគោលដៅក្នុងការផ្តោតសំខាន់ទៅលើការអភិវឌ្ឍបន្ថែមទៅលើផលិតផល និងសេវាកម្មរបស់ខ្លួននាឆ្នាំ2023 ក៏ដូចជាការបន្តរក្សាតំណែង ជាធនាគារដែលឈានមុខគេ ក្នុងវិស័យធនាគារនៅកម្ពុជា។ ជំងឺកូវីដ-19 បានរុញច្រានប្រទេសកម្ពុជាទៅរករបត់នៃការរស់នៅថ្មី ពោលគឺការប្រើប្រាស់រូបិយប័ណ្ណឌីជីថលដែលការទូទាត់បែបនេះបានក្លាយជាទម្លាប់ប្រចាំថ្ងៃរបស់ប្រជាជនគ្រប់រូប។ ដោយមើលឃើញនូវឱកាសនេះ ធនាគារ ហ្វីលីព បានបន្តសហការយ៉ាងជិតស្និទ្ធជាមួយធនាគារជាតិនៃកម្ពុជា (NBC) ដើម្បីគាំទ្រដល់មធ្យោបាយទូទាត់តាមរយៈបាគង ក៏ដូចជា KHQR។ ធនាគារ ហ្វីលីព ស្ថិតក្នុងចំណោមធនាគារដែលជាសមាជិកបាគងចំនួនបួនដំបូង ក្នុងការលើកកម្ពស់អន្តរប្រតិបត្តិការនៃការទូទាត់នេះ។

បន្ទាប់ពីទទួលបានភាពជោគជ័យនៃការទូទាត់បាគង KHQR នៅក្នុងប្រទេសកម្ពុជា ធនាគារបានពង្រីកគំនិតផ្តួចផ្តើមថ្មីមួយទៀត សម្រាប់ការទូទាត់តាមរយៈ QR ឆ្លងដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ ដើម្បីផ្តល់ភាពងាយស្រួល សុវត្ថិភាព និងទំនុកចិត្តទៅកាន់អតិថិជនមួយកម្រិតទៀត។ នៅក្នុងឆ្នាំ2024 យើងក៏នៅបន្តសហការជាមួយ NBC ដើម្បីរៀបចំក្នុងការធ្វើឲ្យសេវាកម្មនេះអាចប្រើប្រាស់បាននៅក្នុងប្រទេសដទៃទៀត។ ធនាគារ ហ្វីលីព ក៏មានការទន្ទឹងរង់ចាំយ៉ាងខ្លាំងចំពោះការបង្កើតបណ្តាញទូទាត់បែបឌីជីថលដ៏ធំប្រចាំតំបន់ផងដែរ។

ក្រៅពីវឌ្ឍនភាពខាងក្រៅ យើងក៏ផ្តោតសំខាន់ទៅលើការកែច្នៃបន្ថែមនៃផលិតផល និងសេវាកម្មរបស់ធនាគារ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់អតិថិជនជា សហគ្រាសធុនតូច និងមធ្យម និងបុគ្គល ដែលកំពុងតែស្វែងរកមធ្យោបាយដំណោះស្រាយ ដើម្បីកែប្រែជីវភាពរស់នៅប្រចាំថ្ងៃ ឬអាជីវកម្មរបស់ពួកគេឲ្យកាន់តែប្រសើរឡើង ក្រោយជំងឺកូវីដ-19។ ថ្មីៗនេះ យើងបានពង្រីកសេវាកម្មរបស់យើងសម្រាប់អាជីវកម្ម ដោយដាក់ឱ្យដំណើរការនូវ ដំណោះស្រាយហិរញ្ញវត្ថុសម្រាប់វិស័យរោងចក្រ និងហិរញ្ញប្បទានពាណិជ្ជកម្ម។ មិនត្រឹមតែប៉ុណ្ណោះ ធនាគារ ហ្វីលីព ក៏ស្ថិតក្នុងចំណោមធនាគារមួយចំនួនដំបូងនៅក្នុងប្រទេសកម្ពុជាដែលផ្តល់ជូននូវផលិតផលនេះ។

# សេចក្តីថ្លែងការណ៍ ប្រធានក្រុមប្រឹក្សាភិបាល

សម្រាប់អតិថិជនដែលមានភាពទាន់សម័យ និងពេញនិយមក្នុងការប្រើប្រាស់បច្ចេកវិទ្យា ធនាគារ ហ្វីលីព តែងតែនាំមកនូវផលិតផល និងដំណោះស្រាយឌីជីថលថ្មីៗ ស្របពេលដែលរក្សានូវភាពងាយស្រួលក្នុងការប្រើប្រាស់សម្រាប់អតិថិជន។ ដោយសារតែប្រទេសកម្ពុជាកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស ផ្នែកឌីជីថល យើងបានកំពុងកសាងភាពជាដៃគូជាមួយនឹងអ្នកផ្គត់ផ្គង់សេវាកម្មសាធារណៈ និងឯកជនជាច្រើន ដើម្បីធានាថាអតិថិជនអាចប្រើប្រាស់សេវាកម្មទូទាត់ដោយមិនប្រើប្រាស់សាច់ប្រាក់ មិនថាជាវិក្កយប័ត្រប្រើប្រាស់ ការទូទាត់ជាមួយសាលារៀន ឬសេវាកម្មផ្សេងៗទៀតឡើយ។

ដោយមើលឃើញពីសារៈសំខាន់នៃការបង្កើតប្រព័ន្ធអេកូឡូស៊ីនៃដំណោះស្រាយជារួមសម្រាប់ក្រុមហ៊ុនដែលជាសមាជិក ក្រុមហ៊ុន PhillipCapital ប្រចាំនៅប្រទេសកម្ពុជា ធនាគារបានធ្វើការសហការជាមួយក្រុមហ៊ុនកុលសម្ព័ន្ធរបស់ខ្លួនដែលមានដូចជាក្រុមហ៊ុនត្រាស់ធី និងក្រុមហ៊ុនធានារ៉ាប់រង ដើម្បីផ្តល់នូវដំណោះស្រាយផ្សេងៗដោយផ្ទាល់ និងតាមរយៈប្រព័ន្ធអ៊ីនធឺណិត។ វិធីសាស្ត្រនេះ ពិតជាប្រកបដោយភាពច្នៃប្រឌិត និងផ្តល់នូវគុណតម្លៃបន្ថែមទៅកាន់អតិថិជន និងនាំឱ្យធនាគារមានលក្ខណៈពិសេសបើប្រៀបធៀបនឹងដៃគូប្រកួតប្រជែងមួយចំនួន។

នៅក្នុងឆ្នាំ2023 ធនាគារទទួលបានចំណូលប្រតិបត្តិការសរុបចំនួន 79.31 លានដុល្លារអាមេរិក (ធៀបនឹងចំនួន 76.26 លានដុល្លារអាមេរិក) និងបានកត់ត្រាប្រាក់ចំណេញ មុនគិតពន្ធចំនួន 6.66 លានដុល្លារអាមេរិក ធៀបនឹងចំនួនប្រាក់ចំណេញ មុនគិតពន្ធចំនួន 13.78 លានដុល្លារអាមេរិក នៅក្នុងឆ្នាំ2022 ដោយសារតែកើនឡើងនូវថ្លៃដើម។ អនុបាតចំណាយនៃប្រាក់ចំណូលសម្រាប់ធនាគារសម្រាប់ឆ្នាំ2023 គឺខ្ពស់ជាងនៅ 0.76:1 ធៀបនឹង 0.70:1 នៅឆ្នាំមុន។

ជាមួយនឹងដើមទុនសរុបចំនួន 75 លានដុល្លារអាមេរិក ដែលអនុលោមតាមតម្រូវការបទប្បញ្ញត្តិ ធនាគារនៅតែប្រកាន់ខ្ជាប់ក្នុងការរក្សាការអនុលោមតាមប្រកាស និងបទប្បញ្ញត្តិដែលកំណត់ដោយ NBC ។

លើសពីនេះ ធនាគារ ហ្វីលីព បានពង្រីកនូវប្រព័ន្ធអេកូឡូស៊ីក្នុងប្រទេសដោយបង្កើតក្រុមហ៊ុនបរធនបាល ដើម្បីធ្វើពិពិតកម្ម សេវាកម្មហិរញ្ញវត្ថុរបស់ខ្លួន។ ក្រុមហ៊ុន ហ្វីលីព ត្រាសធី (ខេមបូឌា) ឯ.ក គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធ របស់ធនាគារ ហ្វីលីព។ បច្ចុប្បន្ននេះ យើងខ្ញុំកំពុងផ្តល់ជូននូវសេវាបរធនបាលកិច្ចជូនវិនិយោគិនរបស់យើងខ្ញុំ រួមទាំងសេវាបរធនបាលកិច្ចសម្រាប់គោលបំណងពាណិជ្ជកម្ម សង្គម និងបុគ្គល សេវាបរធនបាលកិច្ចលើមូលនិធិ និងការវិនិយោគសម្រាប់អតិថិជន ដោយដើរតួជាអន្តរការីភ្នាក់ងារផ្តល់សេវារក្សាសុវត្ថិភាពសម្រាប់ប្រតិបត្តិការអចលនវត្ថុណាមួយ ព្រមទាំងការប្រឹក្សាយោបល់ ពីសេវាបរធនបាលកិច្ចផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

នាឆ្នាំ2023 កន្លងមក យើងខ្ញុំបានចាត់ចែងបរធនបាលកិច្ចចំនួន11 ដែលមានទំហំបរធនមានតម្លៃសរុបជាង 8 លានដុល្លារក្នុងឆ្នាំដំបូងនៃប្រតិបត្តិការរបស់យើងខ្ញុំ។ យើងខ្ញុំក៏បានចុះហត្ថលេខាលើអនុស្សរណៈជាមួយដៃគូចំនួន 20 សម្រាប់កិច្ចសហប្រតិបត្តិការអាជីវកម្ម និងបានចូលរួមក្នុងព្រឹត្តិការណ៍ជិត 20 ដើម្បីជម្រុញបង្កើននូវការយល់ដឹងជាសាធារណៈអំពីយន្តការបរធនបាលកិច្ចជាដំណោះស្រាយដែលអាចជឿទុកចិត្តបានជាមួយសភាពាណិជ្ជកម្ម ដៃគូ និងវិនិយោគិនមួយចំនួនផ្សេងទៀត។

តាំងនាមឲ្យក្រុមប្រឹក្សា ខ្ញុំសូមឆ្លៀតឱកាសនេះថ្លែងអំណរគុណដល់មន្ត្រីធនាគារជាតិនៃកម្ពុជាទាំងអស់ចំពោះការណែនាំគាំទ្រ និងការផ្តល់យោបល់ផ្សេងៗ។ ជូនចំពោះអតិថិជនទាំងអស់ សូមអរគុណចំពោះការជឿជាក់ និងការគាំទ្រឥតឈប់ឈររបស់លោកអ្នក។ យើងទន្ទឹងរង់ចាំបន្តកសាងភាពជាដៃគូរឹងមាំ និងមានផលប្រយោជន៍ទៅវិញទៅមកនៅក្នុងឆ្នាំខាងមុខដែលនេះបានបង្ហាញពីការប្តេជ្ញាចិត្តរបស់យើង ក្នុងការផ្តល់នូវភាពពេញចិត្តដល់អតិថិជន កសាងធនធានមនុស្ស និងចូលរួមចំណែកកសាងសហគមន៍។ ជាចុងក្រោយ សមិទ្ធផលរបស់ពួកយើងត្រូវបានចូលរួមដោយការខិតខំ និងប្តេជ្ញាចិត្តរបស់និយោជិក ដែលជាទ្រព្យសម្បត្តិដ៏អស្ចារ្យបំផុតរបស់យើង និងជាទីកោតសរសើរយ៉ាងជ្រាលជ្រៅ។ សូមអរគុណចំពោះការប្តេជ្ញាចិត្ត និងការលះបង់របស់អ្នកចំពោះធនាគារ និងអតិថិជន។



**លោក Lim Hua Min**
ប្រធានក្រុមប្រឹក្សាភិបាល

# ការពិនិត្យមើលទុរកិច្ច


- អាទិភាពរបស់អាជីវកម្ម ........ 08
- អនុសាសន៍របស់អតិថិជន ........ 11
- ទំនួលខុសត្រូវសង្គម ........ 15
- សេចក្តីសង្ខេបផ្នែកហិរញ្ញវត្ថុ ........ 19
- សេចក្តីសង្ខេបផ្នែកហិរញ្ញវត្ថុរយៈពេល 2 ឆ្នាំ ........ 20
- ការវិភាគលើលទ្ធផលហិរញ្ញវត្ថុ ........ 21
- គោលនយោបាយ និងគោលការណ៍អនុវត្តន៍សម្រាប់អភិបាលកិច្ចក្រុមហ៊ុន .. 23
- ធនាគារ ហ្វីលីព នៅក្នុងទំព័រព័ត៌មាន ........ 31


06

# អាទិភាពរបស់អាជីវកម្ម

## ចក្ខុវិស័យផ្នែកហិរញ្ញវត្ថុ

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ធនាគារទទួលបានចំណូលប្រតិបត្តិការសរុបចំនួន 79.31 លានដុល្លារអាមេរិក (ធៀបនឹងចំនួន 76.26 លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022) និងបានកត់ត្រាប្រាក់ចំណេញ មុនគិតពន្ធចំនួន 6.66 លានដុល្លារអាមេរិក (ធៀបនឹងចំនួនប្រាក់ចំណេញ មុនគិតពន្ធចំនួន 13.78 លានដុល្លារអាមេរិកគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022)។ ការថយចុះនៃប្រាក់ចំណេញ មុនគិតពន្ធ គឺដោយសារតែការកើនឡើងនៃថ្លៃដើម និងការកើនឡើងនៃឱនភាព។

ធនាគារនឹងបន្តអនុវត្តយុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីផ្តោតលើការបំពេញតម្រូវការហិរញ្ញវត្ថុរបស់សហគ្រាសខ្នាតតូចនិងមធ្យម និងអតិថិជនបុគ្គល (ដូចជាការផ្តល់នូវឥណទានបុគ្គល គេហដ្ឋាន និងរថយន្ត)។ ធនាគារក៏នឹងផ្តោតការយកចិត្តទុកដាក់លើការបង្កើនទំហំឥណទាន ក៏ដូចជាការបង្កើនចំនួនទឹកប្រាក់បញ្ញើ ជាពិសេសពីអតិថិជនបុគ្គល អាជីវកម្មខ្នាតតូច និងសហគ្រាសខ្នាតតូច និងមធ្យមផងដែរ។

## ចក្ខុវិស័យចំពោះអតិថិជន

ធនាគារផ្តល់ជូននូវផលិតផល និងសេវាកម្មជាច្រើនប្រភេទ សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ក៏ដូចជាអតិថិជនឥណទានបុគ្គល ដើម្បីបំពេញតម្រូវការហិរញ្ញវត្ថុរបស់បុគ្គល និងសាជីវកម្ម ហើយថែមទាំងធានាឲ្យបាននូវសុវត្ថិភាពទ្រព្យសម្បត្តិរបស់ប្រជាជនក្នុងមូលដ្ឋានសម្រាប់អ្នកជំនាន់ក្រោយ។

ធនាគារជឿជាក់លើការខិតខំប្រឹងប្រែងកាន់តែខ្លាំងបន្ថែមទៀត ដើម្បីបំពេញតាមតម្រូវការ និងភាពងាយស្រួលរបស់អតិថិជន និងផ្តល់ជូននូវដំណោះស្រាយដែលសមស្របទៅតាមតម្រូវការ ក៏ដូចជាបទពិសោធន៍ដ៏ល្អឥតខ្ចោះ។ យើងធានាថាប្រតិបត្តិការត្រូវបានបំពេញដោយជោគជ័យ និងដើម្បីជួយដល់តម្រូវការសេវាកម្មធនាគាររបស់ពួកគេ។

ការប្តេជ្ញាចិត្តនេះ គឺជាលក្ខណៈពិសេសដែលធ្វើឲ្យធនាគារ ហ្វីលីព មានភាពខុសប្លែកគ្នាពីធនាគារដទៃ ស្របតាមអត្ថន័យថ្មីមួយគឺ “បទពិសោធន៍ និងទំនាក់ទំនងអតិថិជនល្អបំផុត” ដើម្បីសម្រេចបានចក្ខុវិស័យ “ផ្តល់ភាពពេញចិត្តដល់អតិថិជន កសាងធនធានមនុស្ស និងចូលរួមចំណែកកសាងសហគមន៍”។

## ចក្ខុវិស័យចំពោះសហគមន៍

ធនាគារក៏ចូលរួមផងដែរក្នុងការអនុវត្តន៍យុទ្ធសាស្ត្រ ទំនួលខុសត្រូវសង្គមជាច្រើនដើម្បីគាំទ្រសហគមន៍។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ធនាគារបានឧបត្ថម្ភក្នុងកម្មវិធីសប្បុរសធម៌ជាច្រើន។ ចាប់ពីឆ្នាំ2018 រហូតមកដល់ពេលនេះ ធនាគារបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើសហគមន៍ជនពិការ និងការអប់រំតាមរយៈការឧបត្ថម្ភ និងសហការគ្នា ដើម្បីជួយគាំទ្រលើកកម្ពស់សហគមន៍ជនពិការតាមរយៈអង្គការសិល្បៈ Epic Arts។ លើសពីនេះទៅទៀត យើងក៏បានចូលរួមគាំទ្រកម្មវិធី E2STEM នៅវិទ្យាល័យព្រះយុគន្ធរដោយផ្តល់ជាអាហារូបករណ៍ និងឱកាសហ្វឹកហាត់ការងារ ដើម្បីជួយជំរុញដល់ការអប់រំផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេសនៅកម្ពុជា។ និស្សិតអាហារូបករណ៍ទាំងអស់ក៏មានឱកាសក្លាយជាអ្នកហ្វឹកហាត់ការងារ នៅធនាគារ ហ្វីលីព ដោយពួកគេអាចទទួលបាននូវបទពិសោធន៍ការងារជាក់ស្តែង ដែលជួយឲ្យពួកគេត្រៀមខ្លួនរួចជាស្រេចក្នុងការចូលបម្រើការងារបន្ទាប់ពីបញ្ចប់ការសិក្សា។

ធនាគារនឹងបន្តចូលរួមគាំទ្រ និងបរិច្ចាគជូនដល់សង្គមជាតិ តាមរយៈគំនិតផ្តួចផ្តើមជាច្រើនផ្សេងទៀត ក៏ដូចជាគម្រោងនៅក្នុងឆ្នាំបន្តបន្ទាប់ដែលរួមមានការគាំទ្រផ្នែកសុខាភិបាល ផ្នែកកីឡា ការបរិច្ចាគជូនដល់សហគមន៍ និងតាមបណ្តាគម្រោងផ្សេងៗទៀត។ ធនាគារ ហ្វីលីព គឺជាធនាគារតែមួយគត់ក្នុងប្រទេសកម្ពុជា ដែលមានអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកជារបស់ខ្លួន ដែលធ្វើសកម្មភាពគាំទ្រ និងជាផ្នែកមួយនៃទំនួលខុសត្រូវសង្គមរបស់ធនាគារ។ អង្គការគាំពារភូមិយើងដែលមានន័យជាភាសាខ្មែរថា "ថែរក្សាភូមិយើង" បានបើកដំណើរការអស់រយៈពេលជាង 10ឆ្នាំមកហើយ ចាប់តាំងពីគម្រោងនេះស្ថិតនៅក្រោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌីត ដើម្បីជួយដល់កុមារ ក្រុមគ្រួសារ និងសហគមន៍ដែលជួបប្រទះភាពខ្វះខាតនៅទូទាំងប្រទេសកម្ពុជា ដោយផ្តល់នូវការបណ្តុះបណ្តាល និងផ្តល់ប្រឹក្សាទៅនឹងចំណេះដឹងហិរញ្ញវត្ថុ កសិកម្ម សិទ្ធិកុមារ សុខភាព និងការអប់រំ។

## ចក្ខុវិស័យចំពោះដំណើរការផ្ទៃក្នុង

ធនាគារមានគោលបំណងរៀបចំគម្រោង និងឈរជើងនៅក្នុងវិស័យនេះជាអ្នក “ផ្តល់ភាពពេញចិត្តដល់អតិថិជន កសាងធនធានមនុស្ស និងចូលរួមចំណែកកសាងសហគមន៍” ដែលផ្តោតការយកចិត្តទុកដាក់ជាខ្លាំងលើដំណើរការគ្រប់គ្រងហានិភ័យយ៉ាងម៉ឺងម៉ាត់ សម្រាប់ជាឧត្តម

# អាទិភាពរបស់អាជីវកម្ម

ប្រយោជន៍របស់អតិថិជន។ ធនាគារបានដាក់ចេញនូវគោលនយោបាយ និងនីតិវិធីកម្រិតស្តង់ដារធនាគារអន្តរជាតិ ព្រមទាំងបានធ្វើការវិនិយោគជាបន្តបន្ទាប់លើវិស័យសន្តិសុខបច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធដើម្បីបង្កើនការជឿទុកចិត្តពីសំណាក់អតិថិជន។

## ចក្ខុវិស័យធនធានមនុស្ស

នៅក្នុងឆ្នាំ2023 វិស័យហិរញ្ញវត្ថុត្រូវបានប្រឈមមុខនឹងបញ្ហាជាច្រើន ដោយសារតែកត្តាបម្រែបម្រួលនៃសេដ្ឋកិច្ច និងភាពមិនច្បាស់លាស់ជាច្រើនផ្សេងទៀត។ លក្ខខណ្ឌសេដ្ឋកិច្ចទាំងនោះបានទាមទារឲ្យមានការផ្លាស់ប្តូរជាយុទ្ធសាស្ត្រក្នុងការអនុវត្តន៍វិធានការផ្សេងៗនៃផ្នែកធនធានមនុស្ស ដើម្បីធានាបាននូវប្រសិទ្ធភាពនៃប្រតិបត្តិការ និងនិរន្តរភាព។

### ការជ្រើសរើស និងគ្រប់គ្រងបុគ្គលិក៖

ដំណើរការជ្រើសរើសបុគ្គលិករបស់យើងត្រូវបានជ្រើសរើសយ៉ាងហ្មត់ចត់ និងផ្តោតសំខាន់ទៅលើមុខតំណែង ដែលមានសារៈសំខាន់ចំពោះគោលដៅយុទ្ធសាស្ត្ររបស់យើង។ វិធីសាស្ត្រនេះអាចធានាបានថា យើងពិតជាបាននាំមកនូវបុគ្គលដែលមានទេពកោសល្យខ្ពស់ដែលអាចជួយសម្រេចគោលដៅរយៈពេលវែងរបស់យើងបាន។

### បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG)៖

នៅក្នុងឆ្នាំ2023 យើងបានពង្រឹងការអនុវត្តន៍គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ដោយអនុវត្តនូវគំនិតផ្តួចផ្តើមជាច្រើនក្នុងគោលបំណងលើកកម្ពស់និរន្តរភាព ក៏ដូចជាការណែនាំការយល់ដឹងបន្ថែមអំពី ESG ទៅកាន់បុគ្គលិករបស់យើង ក៏ដូចជាការគ្រប់គ្រងចំណាយផងដែរ។

បច្ចុប្បន្ននេះ យើងមានបុគ្គលិកដែលមានតួនាទីដឹកនាំគំនិតផ្តួចផ្តើមកម្មវិធី ESG របស់យើងឲ្យកាន់តែរីកចម្រើន។

### ការពង្រឹងបន្ថែមចំណេះជំនាញ៖

ការពង្រឹងចំណេះ និងជំនាញរបស់បុគ្គលិកនៅតែជាការផ្តោតសំខាន់របស់យើង។ យើងបានណែនាំកម្មវិធីបណ្តុះបណ្តាល ដើម្បីបង្កើនជំនាញទៅកាន់បុគ្គលិករបស់យើង ដោយធានាថាពួកគេមានការយល់ដឹងច្បាស់លាស់ ដើម្បីសម្របទៅនឹងតម្រូវការការងារដែលកំពុងវិវត្ត និងការរីកចម្រើនផ្នែកបច្ចេកវិទ្យា។

### កម្មវិធីបណ្តុះបណ្តាលអ្នកមានទេពកោសល្យវ័យក្មេង៖

ការអភិវឌ្ឍន៍ទេពកោសល្យសិស្សនិស្សិតនៅតែបន្តជាការផ្តោតសំខាន់នៅក្នុងធនាគារតាមរយៈកម្មវិធីបណ្តុះបណ្តាលអ្នកមានទេពកោសល្យវ័យក្មេងប្រកបដោយភាពច្នៃប្រឌិតក្នុងគោលបំណងជំរុញអ្នកដឹកនាំជំនាន់ក្រោយឲ្យកាន់តែរឹងមាំ និងល្អប្រសើរ។ គោលបំណងមួយក្នុងចំណោមគំនិតផ្តួចផ្តើម ក្នុងកម្មវិធីបណ្តុះបណ្តាលនេះ គឺធនាគារបានបង្កើតយុទ្ធសាស្ត្រក្នុងការបង្កើតកិច្ចសហការជាមួយសាកលវិទ្យាល័យក្នុងប្រទេស និងសាកលវិទ្យាល័យនាំមុខគេទាំងក្នុង និងក្រៅប្រទេស រួមទាំងសាកលវិទ្យាល័យជាតិសិង្ហបុរី (NUS) និងសាកលវិទ្យាល័យ Nanyang Technological University (NTU) ដើម្បីបង្កើតទម្លាប់ចែករំលែក និងផ្លាស់ប្តូរវប្បធម៌ទៅវិញទៅមក។

### ការចូលរួមជាមួយសហគមន៍៖

យើងបានចូលរួមជាមួយសហគមន៍ដោយសហការជាមួយទីភ្នាក់ងារ និងស្ថាប័នឯករាជ្យផ្សេងៗ ដើម្បីគាំទ្រដល់និស្សិតក្នុងប្រទេស និងនិស្សិតពីប្រទេសសិង្ហបុរីក្នុងការអភិវឌ្ឍន៍ជំនាញ។ គោលបំណងរបស់យើងគឺផ្តោតលើការពង្រឹងជំនាញ និងចំណេះដឹងដែលចាំបាច់ ទៅកាន់សិស្សានុសិស្សដើម្បីឲ្យពួកគេត្រៀមខ្លួនរួចជាស្រេច សម្រាប់ភាពជោគជ័យក្នុងអាជីពការងារនាពេលអនាគត។ យើងមានកិត្តិយសដែលបានទទួលក្រុមនិស្សិតវ័យក្មេងពីរក្រុមមកពីប្រទេសសិង្ហបុរីកាលពីឆ្នាំមុន។

ការងារនេះគឺជាគំនិតផ្តួចផ្តើមដ៏ជោគជ័យមួយដែលបង្ហាញពីឱកាសនៅក្នុងវិស័យធនាគារកម្ពុជា។ តាមរយៈការចូលរួមជាមួយសិស្សានុសិស្ស និងផ្តល់ឲ្យពួកគេនូវការយល់ដឹងបន្ថែម យើងមិនត្រឹមតែបានបើកបង្ហាញប្រទេសកម្ពុជាជាគោលដៅសម្រាប់អាជីពការងារជាច្រើនប៉ុណ្ណោះទេ ថែមទាំងបានគាំទ្រនូវទម្លាប់ចែករំលែក និងធ្វើការងារក្រុមផងដែរ។

ជាចុងបញ្ចប់ ចក្ខុវិស័យនៃផ្នែកធនធានមនុស្សរបស់យើងត្រូវបានបង្កើតឡើងដោយយកចិត្តទុកដាក់ និងល្អិតល្អន់ ដោយផ្តោតសំខាន់ទៅលើការជ្រើសរើសបុគ្គលិក ការគ្រប់គ្រងចំណាយដោយប្រសិទ្ធភាពខ្ពស់ និងការពង្រឹងចំណេះជំនាញ។ យើងអាចធានាបានថាបុគ្គលិករបស់យើងនៅតែមានភាពស្វាហាប់ និងវិជ្ជាជីវៈខ្ពស់ ដើម្បីស្របទៅតាមចក្ខុវិស័យរបស់យើង ទោះបីក្នុងកំឡុងពេលសេដ្ឋកិច្ចមិនទាន់មានស្ថិរភាពក៏ដោយ។

# អាទិភាពរបស់អាជីវកម្ម

## ចក្ខុវិស័យផ្នែកសិក្សាធិការ និងអភិវឌ្ឍន៍

នៅក្នុងឆ្នាំ2023 នាយកដ្ឋានសិក្សាធិការ និងអភិវឌ្ឍន៍ (L&D) របស់យើង បានផ្តោតសំខាន់ទៅលើការពង្រឹងជំនាញ និងសមត្ថភាពរបស់បុគ្គលិក ដើម្បីបំពេញតម្រូវការនៃអាជីវកម្មដែលកំពុងអភិវឌ្ឍ និងកែលម្អបន្ថែមទៅលើផ្នែកសេវាកម្មបម្រើអតិថិជន។ គោលគំនិត ផ្តួចផ្តើមរបស់យើងរួមមានការបង្កើត និងអនុវត្តឲ្យមានកម្មវិធីបណ្តុះបណ្តាលសំខាន់ៗ ក៏ដូចជាពង្រឹងការអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ និងកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានផ្សេងៗ និងការផ្តល់នូវឱកាសបណ្តុះបណ្តាលផ្នែកខាងភាសា និងការហ្វឹកហាត់នៅក្រៅប្រទេស។

### កម្មវិធីផ្នែកសេវាកម្មអតិថិជន៖

កម្មវិធីផ្នែកសេវាកម្មអតិថិជន WECARE ត្រូវបានបង្កើតឡើងដើម្បីឆ្លុះបញ្ចាំងពីទស្សនវិស័យសេវាកម្មរបស់ធនាគារ និងការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់ផ្នែកសេវាកម្មអតិថិជន។ កម្មវិធីនេះត្រូវបានបែងចែកជាបីផ្នែក ដែលផ្នែកនីមួយៗផ្តោតលើការផ្តល់នូវសេវាកម្មល្អឥតខ្ចោះទៅកាន់អតិថិជន។ យើងទទួលបានជោគជ័យក្នុងការអនុវត្តន៍យ៉ាងខ្ជាប់ខ្ជួន ទៅតាមគ្រប់តំបន់ប្រតិបត្តិការទាំងអស់។ តាមរយៈកម្មវិធី WECARE យើងអាចសម្រេចបាននូវការផ្តល់សេវាកម្ម ដែលមានស្តង់ដារ និងគុណភាពខ្ពស់ទៅកាន់អតិថិជនរបស់យើង។

### កម្មវិធីពង្រឹងភាពជាអ្នកដឹកនាំ៖

កម្មវិធីភាពជាអ្នកដឹកនាំ ត្រូវបានបង្កើតឡើងដើម្បីបំពេញតាមតម្រូវការអាជីវកម្មដែលកំពុងលូតលាស់របស់ធនាគារ។ ដោយផ្តោតសំខាន់ទៅលើការបណ្តុះបណ្តាលបុគ្គលិកក្នុងការត្រៀមខ្លួនជាស្រេចសម្រាប់តួនាទីជាអ្នកដឹកនាំនាពេលអនាគត។ កម្មវិធីនេះក៏បានរួមបញ្ចូលប្រធានបទទាក់ទងទៅនឹងវិធីសាស្ត្រក្នុងការគិត និងការច្នៃប្រឌិតជាដើម។ កម្មវិធីទាំងនេះ នឹងធានាបានថា អ្នកដឹកនាំជំនាន់ក្រោយរបស់យើងមានភាពរឹងមាំ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការជំរុញឲ្យមានការរីកចម្រើនបន្តនាពេលអនាគត។

### កម្មវិធីដែលមានការទទួលស្គាល់ និងកិច្ចសហការជាមួយវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ៖

យើងបានសហការជាមួយវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ ដើម្បីបំពេញនូវតម្រូវការនៃការចូលរួមកម្មវិធីបណ្តុះបណ្តាលសំខាន់ៗជាច្រើនទាក់ទងទៅនឹងជំនាញផ្នែកធនាគារ។ កម្មវិធីសំខាន់ៗរួមមានកម្មវិធីផ្តល់ឥណទានប្រកបដោយទំនួលខុសត្រូវខ្ពស់ សម្រាប់បុគ្គលិកផ្នែកឥណទាន និងការបណ្តុះបណ្តាលស្តីពីទំនួលខុសត្រូវក្នុងធនាគារ ទៅកាន់សមាជិកក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ ក៏ដូចជាបុគ្គលិកផ្សេងៗទៀតផងដែរ។ កិច្ចសហការនេះអាចធានាបានថា បុគ្គលិករបស់យើងមានចំណេះជំនាញទៅតាមស្តង់ដារ និងយល់ដឹងពីបទប្បញ្ញត្តិបានល្អ ក្នុងគោលបំណងដើម្បីបង្ហាញពីការការប្តេជ្ញាចិត្តក្នុងការផ្តល់នូវសេវាកម្មធនាគារ ដែលល្អ និងទំនួលខុសត្រូវខ្ពស់ទៅកាន់អតិថិជន។

### ការឧបត្ថម្ភកម្មវិធីសិក្សាផ្នែកភាសា៖

ដោយយល់ដឹងអំពីសារៈសំខាន់នៃចំណេះដឹងផ្នែកភាសា យើងបានផ្តល់ការឧបត្ថម្ភទៅកាន់បុគ្គលិករបស់យើង ក្នុងការសិក្សាបន្ថែមទៅលើភាសាអង់គ្លេស ក៏ដូចជាភាសាចិនជាដើម។

### ដំណើរទស្សនកិច្ចសិក្សានៅបរទេស៖

ធនាគារ ហ្វីលីព ជឿជាក់ទៅលើបទពិសោធន៍ និងទំនាក់ទំនង។ ហេតុដូច្នេះ យើងបានផ្តល់ឱកាសទៅកាន់បុគ្គលិកដែលបានជ្រើសរើសមួយចំនួនក្នុងការទៅធ្វើទស្សនកិច្ចសិក្សា និងចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗនៅក្រៅប្រទេស ដើម្បីឲ្យពួកគេយល់ដឹងបន្ថែមអំពីដំណើរការអាជីវកម្មរបស់ធនាគារប្រកបដោយភាពច្នៃប្រឌិត និងល្អប្រសើរ។

ជាចុងក្រោយ នាយកដ្ឋានសិក្សាធិការ និងអភិវឌ្ឍន៍ បានដើរតួនាទីយ៉ាងសំខាន់ជាផ្នែកមួយក្នុងការសម្រេចបាននូវគោលដៅរបស់ធនាគារ ដោយបណ្តុះបណ្តាលបុគ្គលិក នូវចំណេះជំនាញដែលចាំបាច់ទៅកាន់ពួកគេ។ យើងមានគោលដៅក្នុងការបណ្តុះបណ្តាលសមត្ថភាពបុគ្គលិករបស់យើងឲ្យកាន់តែល្អប្រសើរ ដើម្បីត្រៀមខ្លួនជាស្រេចនាពេលអនាគត។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះមិនត្រឹមតែធ្វើអោយដំណើរការបច្ចុប្បន្នប្រសើរឡើងប៉ុណ្ណោះទេ ថែមទាំងបានរក្សានូវភាពជោគជ័យនៅក្នុងវិស័យធនាគារដែលកំពុងរីកចម្រើនជាបន្តបន្ទាប់ទៀតផងដែរ។

# អាទិភាពរបស់អាជីវកម្ម

## ផែនការប្រតិបត្តិការសំខាន់សម្រាប់ឆ្នាំ2024

ដើម្បីផ្តល់ជូនអតិថិជននូវមធ្យោបាយកាន់តែងាយស្រួលក្នុងវិស័យធនាគារ ធនាគារគ្រោងនឹងបន្តកែលម្អផលិតផលដែលមានស្រាប់របស់ខ្លួន ស្របពេលដែលបន្តផ្តល់ជូននូវដំណោះស្រាយថ្មីៗប្រកបដោយភាពច្នៃប្រឌិត នៅក្នុងឆ្នាំ2024។ យើងគ្រោងនឹងដាក់ដំណើរការកំណែថ្មីនៃកម្មវិធីធនាគារចល័ត Phillip Mobile និងសេវាកម្ម Internet Banking របស់យើង ដែលភ្ជាប់មកជាមួយនឹងរូបរាងថ្មី និងបទពិសោធន៍ប្រើប្រាស់កាន់តែល្អប្រសើរ ក៏ដូចជាការពង្រឹងសុវត្ថិភាព និងដំណើរការផងដែរ។ ក្រៅពីការបន្ថែមមុខងារ និងដំណោះស្រាយថ្មីៗនៅលើបណ្តាញឌីជីថល យើងថែមទាំងកែលម្អដំណើរការនៃការបើកគណនី និងការផ្ទេរប្រាក់ទៅក្រៅប្រទេសផងដែរ។ យើងក៏កំពុងធ្វើការជាមួយអាជ្ញាធរនិងរាជរដ្ឋាភិបាលផ្សេងៗ ដើម្បីនាំយកសេវាសាធារណៈបន្ថែមទៀតនៅក្នុងកម្មវិធីធនាគារចល័ត Phillip Mobile របស់យើង។

ម៉ាស្ទ័រកាត (Mastercard) កាតឥណពន្ធ (Debit Card) និងកាតបង់ប្រាក់ជាមុន (Prepaid Card) របស់យើង នឹងមានវត្តមាននៅលើទីផ្សារនៅត្រីមាសទី2 នៃឆ្នាំ2024។ ផលិតផលទាំងអស់នេះបានបង្ហាញពីភាពងាយស្រួលមួយកម្រិតទៀតសម្រាប់អតិថិជនក្នុងការទិញទំនិញតាមប្រព័ន្ធអនឡាញ និងការទូទាត់ផ្សេងៗទៀត។

សេវាកម្មបម្រើអតិថិជនដ៏ល្អឥតខ្ចោះរបស់យើង អាចបញ្ជាក់បានយ៉ាងច្បាស់តាមរយៈការកើនឡើង នៃចំនួនអតិថិជនអាទិភាពរបស់យើង។ ដោយទទួលបានភាពជោគជ័យនៃយុទ្ធនាការដាក់ប្រាក់សន្សំរបស់យើងនៅឆ្នាំ2023 យើងនឹងបន្តផ្តល់ជូនដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតដែលនឹងចំណែកមួយក្នុងការជួយអតិថិជនបុគ្គល និងសាជីវកម្មបង្កើនទ្រព្យធន និងប្រាក់ចំណូលរបស់ពួកគេបន្ថែមទៀត។ លើសពីនេះ យើងនឹងបន្តសម្រេចគោលដៅរបស់យើង ក្នុងការបង្កើននូវអតិថិជនថ្មីៗ ដែលនឹងបង្កើនចំនួនប្រតិបត្តិការជាច្រើនបន្ថែមទៀត តាមរយៈវេទិកាឌីជីថលរបស់យើង។

ទន្ទឹមនឹងនេះផងដែរ ធនាគារក៏នឹងលើកកម្ពស់ផលិតផលធនាគារបុគ្គល រួមមាន ឥណទានបុគ្គល ឥណទានខ្នាតតូច ឥណទានម៉ូតូ ឥណទានរថយន្ត និងឥណទានគេហដ្ឋាន ដើម្បីបង្កើនអតិថិជនរបស់ធនាគារនៅក្នុងផ្នែកធនាគារបុគ្គល។

# អនុសាសន៍របស់អតិថិជន



លោក លាក់ ចន្ទ្រា

“ខ្ញុំជាអតិថិជនរបស់ធនាគារ ហ្វីលីព អស់រយៈពេលជាច្រើនឆ្នាំមកហើយ។ សេវាកម្មដែលផ្តល់ដោយធនាគារ ពិតជាមានភាពលេចធ្លោខ្លាំងណាស់។ បុគ្គលិករបស់ធនាគារ តែងតែព្យាយាមស្វែងយល់ពីគោលដៅហិរញ្ញវត្ថុរបស់ខ្ញុំ មុននឹងឈានទៅណែនាំជំហាននីមួយៗដោយហ្មត់ចត់ និងលម្អិត ដើម្បីធានាថា ឯកសារដាក់ពាក្យស្នើសុំដែលចាំបាច់ទាំងអស់ត្រូវបានរៀបចំជាស្រេច ហើយតម្រូវការហិរញ្ញវត្ថុរបស់ខ្ញុំត្រូវបានឆ្លើយតបយ៉ាងត្រឹមត្រូវ។”



លោកស្រី ស៊ា ស្រីនាត

“ខ្ញុំសូមអរគុណយ៉ាងជ្រាលជ្រៅចំពោះធនាគារដែលបានផ្តល់ប្រាក់កម្ចីដល់ខ្ញុំ សម្រាប់ជំរុញដល់ការពង្រីកអាជីវកម្ម។ ការគាំទ្រផ្នែកហិរញ្ញវត្ថុពីធនាគារ បានអនុញ្ញាតឲ្យខ្ញុំវិនិយោគលើធនធានថ្មី ទទួលបានអតិថិជនកាន់តែច្រើន ដែលជាកត្តាធ្វើឲ្យអាជីវកម្មរបស់ខ្ញុំអភិវឌ្ឍទៅមុខមួយកម្រិតទៀត។ ទំនុកចិត្ត និងជំនួយផ្នែកហិរញ្ញវត្ថុរបស់ធនាគារ បានក្លាយជាបង្គោលដ៏រឹងមាំមួយរបស់ខ្ញុំ ក្នុងការជំរុញឲ្យមានការផ្តួចផ្តើម និងយុទ្ធសាស្រ្តថ្មីៗនៅក្នុងអាជីវកម្មដែលទទួលបានមកវិញនូវសមិទ្ធិផលដ៏ល្អប្រសើរ។ សូមអរគុណដល់ធនាគារ ដែលបានធ្វើឲ្យក្តីប្រាថ្នារបស់ខ្ញុំក្លាយជាការពិត។”

# អនុសាសន៍របស់អតិថិជន



## លោកស្រី សួន សុប៊ិន

“ខ្ញុំសូមយកពេលវេលានេះ ដើម្បីបង្ហាញការស្ងើចសរសើរដល់បុគ្គលិករបស់ធនាគារ ចំពោះជំនាញវិជ្ជាជីវៈ ភាពរួសរាយរាក់ទាក់ និងភាពស្និតស្នាញក្នុងការបម្រើសេវាកម្មដល់អតិថិជន។ អាកប្បកិរិយាល្អ និងភាពរួសរាយរាក់ទាក់របស់បុគ្គលិកធនាគារ ពិតជាធ្វើឲ្យខ្ញុំមានអារម្មណ៍ថា ខ្ញុំទទួលបានការផ្តល់តម្លៃក្នុងនាមជាអតិថិជនម្នាក់។ ជាចុងក្រោយ ខ្ញុំគ្មានអ្វីក្រៅពាក្យជូនពរទៅកាន់ធនាគារឲ្យមានអតិថិជនកាន់តែច្រើន និងបន្តរីកចម្រើនទៅមុខកាន់តែខ្លាំងឡើង។”



## លោកស្រី ឡាំ ស៊ីវហ្មុង

“ធនាគារ ហ្វីលីព នាំយកមកឲខ្ញុំនូវទំនុកចិត្ត និងភាពស្មោះត្រង់ តាមរយៈការផ្តល់នូវអត្រាការប្រាក់ដែលល្អ និងការប្តេជ្ញាចិត្តក្នុងការផ្តល់នូវបទពិសោធន៍ធនាគារប្រកបដោយសុវត្ថិភាព និងទំនុកចិត្តខ្ពស់មកកាន់អតិថិជន។ ធនាគារបានជួយសម្រួលដល់ការគ្រប់គ្រងសាច់ប្រាក់របស់ខ្ញុំឲ្យកាន់តែរលូន និងងាយស្រួល។ ភាពប៉ិនប្រសព្វ និងការប្តេជ្ញាចិត្តចំពោះការផ្តល់នូវសេវាកម្មបម្រើអតិថិជនល្អឥតខ្ចោះគឺពិតជាគួរឲ្យសរសើរ។ ខ្ញុំសូមកោតសរសើរចំពោះការកែលម្អជាបន្តបន្ទាប់ និងការយកចិត្តទុកដាក់ក្នុងការផ្តល់នូវបទពិសោធន៍កាន់តែល្អប្រសើរទៅកាន់អតិថិជន។”

# អនុសាសន៍របស់អតិថិជន




**លោកស្រី ហង់ ថារិន**

“កម្មវិធីប្រូម៉ូសិនដាក់ប្រាក់បញ្ញើរបស់ធនាគារ ហ្វីលីព គឺជាគំនិតផ្តួចផ្តើមដ៏ឆ្លាតវៃ និងទាក់ទាញមួយ។ អត្រាការប្រាក់ល្អ គួបផ្សំនឹងរង្វាន់ជាច្រើន បានក្លាយជាកត្តាជំរុញឲ្យខ្ញុំមានកម្លាំងចិត្តបង្កើនការសន្សំរបស់ខ្ញុំកាន់តែច្រើនជាងមុន។ កម្មវិធីប្រូម៉ូសិនបែបនេះ មិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដល់អតិថិជនប៉ុណ្ណោះទេ តែក៏បានលើកទឹកចិត្តដល់អតិថិជនក្នុងការកសាងនូវទម្លាប់សន្សំប្រាក់ប្រកបដោយទំនួលខុសត្រូវផងដែរ។ សូមអរគុណដល់ធនាគារ ហ្វីលីព ដែលខ្នះខ្នែងក្នុងការផ្តល់នូវអ្វីដែលជាប្រយោជន៍សម្បូរបែបដល់អតិថិជន។”



**លោកស្រី កែវ សំឡី**

“ខ្ញុំសូមសម្តែងនូវការកោតសរសើរទៅកាន់បុគ្គលិករបស់ធនាគារ ហ្វីលីព សម្រាប់សេវាកម្មអតិថិជនដ៏ឆ្នើមរបស់ពួកគេ។ រាល់ការប្រាស្រ័យទាក់ទងគ្នា មិនថាតាមទូរស័ព្ទ ឬការជួបមុខផ្ទាល់ បុគ្គលិកធនាគារ តែងតែសម្តែងចេញនូវភាពរួសរាយរាក់ទាក់ និងទំនួលខុសត្រូវខ្ពស់មកកាន់អតិថជន។ បុគ្គលិកម្នាក់ៗ តែងតែដោះស្រាយបញ្ហានីមួយៗដោយប្រុងប្រយ័ត្ន និងស្វាហាប់ មិនថាក្នុងថ្ងៃធ្វើការ ឬចុងសប្តាហ៍ឡើយ ដោយទង្វើទាំងនេះជាការបង្ហាញពីការយកចិត្តទុកដាក់ខ្ពស់មកលើអតិថិជន។”

# អនុសាសន៍របស់អតិថិជន



**លោក សឹង សាលីន**

“សូមអរគុណដល់ធនាគារ ហ្វីលីព ដែលធ្វើឲ្យមានការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងស្ថានភាពហិរញ្ញវត្ថុរបស់ខ្ញុំ។ ចាប់តាំងពីទទួលបានកម្ចីពីធនាគារ ប្រាក់ចំណូលពីអាជីវកម្មរបស់ខ្ញុំមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ដែលអាចឲ្យខ្ញុំសម្រេចបាននូវស្ថិរភាពហិរញ្ញវត្ថុ និងទទួលបានឱកាសថ្មីៗកាន់តែច្រើន។ ជំនួយហិរញ្ញវត្ថុរបស់ធនាគារ មិនត្រឹមតែបានជំរុញកំណើនអាជីវកម្មរបស់ខ្ញុំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានរួមចំណែកក្នុងការកាត់បន្ថយអត្រាគ្មានការងារធ្វើរបស់ប្រជាជននៅក្នុងសហគមន៍របស់ខ្ញុំផងដែរ។”

# ទំនួលខុសត្រូវសង្គម

ធនាគារ ហ្វីលីព ជឿជាក់ថា កិច្ចការទំនួលខុសត្រូវសង្គម (CSR) មិនមែនត្រឹមជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនប៉ុណ្ណោះទេ តែវាស្ថិតនៅក្នុង DNA របស់យើង ក្នុងការធ្វើល្អ និងប្រគល់ត្រលប់ទៅសហគមន៍ដែលយើងកំពុងធ្វើប្រតិបត្តិការ។

យើងបានបែងចែកសកម្មភាពទំនួលខុសត្រូវសង្គមជា 2 ផ្នែក គឺ៖

- ទំនួលខុសត្រូវសង្គមជាយុទ្ធសាស្ត្រ៖ ជាការកំណត់ចេញនូវតំបន់ ឬក្រុមជាក់លាក់ណាមួយ ដែលធនាគារបានជ្រើសរើសដើម្បីជួយជ្រោមជ្រែងក្នុងរយៈពេលវែង។ សម្រាប់ធនាគារ ហ្វីលីព ទំនួលខុសត្រូវសង្គមជាលក្ខណៈយុទ្ធសាស្ត្រ រួមបញ្ចូលទាំងការផ្តល់ប្រយោជន៍ដល់ការអប់រំ និងសិល្បៈនៃពិការភាព។

- ទំនួលខុសត្រូវសង្គមតាមតម្រូវការ៖ ជាគម្រោងរយៈពេលខ្លីសម្រាប់ក្រុមជាក់លាក់ណាមួយក្នុងសហគមន៍ ដើម្បីឆ្លើយតបទៅនឹងព្រឹត្តិការណ៍ដូចជាគ្រោះមហន្តរាយ ទឹកជំនន់ សាលារៀន និងយុទ្ធនាការអប់រំ កម្មវិធីលើកកម្ពស់សិទ្ធិកុមារ សុខភាព ជាដើម។

ក្នុងឆ្នាំ2023 ធនាគារ ហ្វីលីព បានគាំទ្រសហគមន៍ និងសកម្មភាពសប្បុរសធម៌ក្នុងប្រទេសតាមរយៈសកម្មភាពខាងក្រោម៖





**អង្គការគាំពារភូមិយើង (KPY)**

អង្គការគាំពារភូមិយើង (KPY) គឺជាអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការជាមួយធនាគារ ហ្វីលីព និងជាផ្នែកមួយនៃទំនួលខុសត្រូវសង្គមរបស់ធនាគារដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ក្រុមងាយរងគ្រោះនៅកម្ពុជា។ ធនាគារ ហ្វីលីព បានគាំទ្រអង្គការនេះអស់រយៈពេលជាង 10 ឆ្នាំចាប់តាំងពីគម្រោងនេះស្ថិតនៅក្រោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌីត ដើម្បីជួយដល់កុមារ ក្រុមគ្រួសារ និងសហគមន៍ដែលជួបប្រទះភាពខ្វះខាតនៅក្នុងប្រទេសកម្ពុជា ដោយផ្តល់នូវការបណ្តុះបណ្តាល និងផ្តល់ប្រឹក្សាទៅប្រាំសកម្មភាពរួមមាន ចំណេះដឹងហិរញ្ញវត្ថុ កសិកម្ម សិទ្ធិកុមារ សុខភាព និងការអប់រំ។

# ទំនួលខុសត្រូវសង្គម



**អង្គការ Epic Arts កម្ពុជា**

ធនាគារ ហ្វីលីព បានឧបត្ថម្ភដល់សិល្បៈជនពិការ នៅប្រទេសកម្ពុជា និងបានចូលរួមចំណែក ចំពោះការសម្តែងរបស់ Epic Arts ដែលជាអង្គការសង្គម និងការអប់រំ មានមូលដ្ឋានស្ថិតនៅខេត្តកំពត។



**E2STEM កម្ពុជា**

ធនាគារ ហ្វីលីព តែងតែជាម្ចាស់ជំនួយ ចំពោះការផ្តួចផ្តើមផ្នែកអប់រំដ៏សំខាន់មួយដែលត្រូវបានហៅកាត់ថា E2STEM។ នៅឆ្នាំ2023 ធនាគារ ហ្វីលីព បានផ្តល់ជាជំនួយឧបត្ថម្ភទៅកាន់សិស្សថ្នាក់ទី7 ចំនួន 12នាក់ ដើម្បីចូលរួមក្នុងការប្រកួតជាសាកលលើកដំបូងនៅប្រទេសសិង្ហបុរី ដែលជាការបង្ហាញអំពីវិធីសាស្ត្រសិក្សាបែប STEM ដែលអាចជួយឱ្យពួកគេអភិវឌ្ឍសមត្ថភាពរបស់ខ្លួនក្នុងការដោះស្រាយបញ្ហាតាមរយៈកម្មវិធី STEMបានយ៉ាងល្អ។ បន្ថែមពីនេះផងដែរ ធនាគារ ហ្វីលីព ក៏បានផ្តល់ជូនឱកាសហ្វឹកហាត់ការងារ សម្រាប់និស្សិតមួយចំនួននៅ E2STEM ដើម្បីប្រើប្រាស់ជំនាញរបស់ពួកគេនៅក្នុងបរិយាកាសការងារជាក់ស្តែង។

# ទំនួលខុសត្រូវសង្គម





**កម្មវិធីជិះកង់សប្បុរសធម៌នៅខេត្តកំពត**

ធនាគារ ហ្វីលីព បានចាប់ដៃគូជាមួយ r+ ដើម្បីរៀបចំកម្មវិធីជិះកង់សប្បុរសធម៌នៅខេត្តកំពត នៅថ្ងៃទី23 ខែមេសា ឆ្នាំ2023។ បុគ្គលិកធនាគារ ហ្វីលីព ជាង 50នាក់ បានចូលរួមក្នុងព្រឹត្តិការណ៍នេះ ដើម្បីស្វែងយល់ពីកសិដ្ឋានផ្សេងៗក្នុងខេត្តកំពត និងលើកកម្ពស់ការយល់ដឹងអំពីវិស័យកសិកម្មនៅក្នុងប្រទេសកម្ពុជា។

r+ និងធនាគារ ហ្វីលីព បានបរិច្ចាគទឹកប្រាក់ចំនួន 2 ដុល្លារ រៀងរាល់គីឡូម៉ែត្រនៃការជិះកង់របស់អ្នកចូលរួម ទៅកាន់អង្គការ Smile Cambodia។





**ការឧបត្ថម្ភអាហារូបករណ៍ទៅកាន់សាលារៀន ទ្រូ វីហ្សិន កម្ពុជា**

ធនាគារ ហ្វីលីព បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាមួយ សាលារៀនអន្តរជាតិ ទ្រូ វីហ្សិនកម្ពុជាទៅលើការផ្តល់អាហារូបករណ៍ 50% លើការសិក្សាប្រចាំឆ្នាំ សម្រាប់សិស្សពូកែថ្នាក់វិទ្យាល័យចំនួន 12នាក់។

# ទំនួលខុសត្រូវសង្គម




**ព្រឹត្តិការណ៍រត់ប្រណាំងអន្តរជាតិពាក់កណ្តាលម៉ារ៉ាតុង**

ធនាគារ ហ្វីលីព បានបរិច្ចាគទឹកប្រាក់ជិត 2,000ដុល្លារអាមេរិក តាមរយៈការចូលរួមក្នុងព្រឹត្តិការណ៍រត់ប្រណាំងអន្តរជាតិពាក់កណ្តាលម៉ារ៉ាតុង លើកទី28 នៅអង្គរវត្ត ដោយមានបុគ្គលិកជាង 100នាក់បានចុះឈ្មោះចូលរួម។ ទឹកប្រាក់ដែលចំណាយលើការចុះឈ្មោះ ត្រូវបានប្រគល់ជូនដល់អ្នករៀបចំកម្មវិធីដើម្បីធ្វើការបរិច្ចាគទៅមន្ទីរពេទ្យកុមារគន្ធបុប្ផា។





**សាលា Green Bethel Community School**

ធនាគារ ហ្វីលីព គឺជាអ្នកឧបត្ថម្ភប្រចាំឆ្នាំមួយរូប ទៅកាន់សាលា Green Bethel Community School (GBC) ក្នុងប្រទេសកម្ពុជា។

បង្កើតឡើងដោយអង្គការក្រៅរដ្ឋាភិបាលកូរ៉េ សហការជាមួយរដ្ឋាភិបាលក្នុងតំបន់ GBC គឺជាសញ្ញានៃក្តីសង្ឃឹមសម្រាប់កុមារក្រីក្រ ដែលរស់នៅក្នុងទីលានចាក់សំរាម។ ការឧបត្ថម្ភនេះបានផ្តល់ឱ្យពួកគេនូវលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព ផ្តល់ការគាំទ្រដល់ពួកគេក្នុងការចេញពីរង្វង់នៃភាពក្រីក្រ និងឈានទៅការបង្កើតអនាគតដ៏ល្អប្រសើរសម្រាប់ខ្លួនឯង។

# សេចក្តីសង្ខេបផ្នែកហិរញ្ញវត្ថុ

| | 2023 | 2022 |
|---|---|---|
| **លទ្ធផលប្រតិបត្តិការ (ពាន់ដុល្លារអាមេរិក)** | | |
| ចំណូលប្រតិបត្តិការ | 79,308 | 76,261 |
| ប្រាក់ចំណេញមុនបង់ពន្ធ | 6,664 | 13,783 |
| ចំណេញប្រចាំឆ្នាំ | 5,195 | 10,526 |
| **តារាងតុល្យការគន្លឹះ (ពាន់ដុល្លារអាមេរិក)** | | |
| ទ្រព្យសកម្មសរុប | 793,449 | 721,079 |
| ឥណទាន និងបុរេប្រទាន | 582,248 | 582,611 |
| បំណុលសរុប | 636,363 | 569,188 |
| ប្រាក់បញ្ញើ | 601,027 | 507,879 |
| ដើមទុន និងទុនបម្រុងបន្ថែម | 75,000 | 75,000 |
| មូលនិធិម្ចាស់ក្រុមហ៊ុន | 157,086 | 151,891 |
| **អនុបាតហិរញ្ញវត្ថុ** | | |
| ចំណេញក្នុងមួយភាគហ៊ុន (ដុល្លារអាមេរិក) | 0.07 | 0.14 |
| ទ្រព្យសកម្មសុទ្ធក្នុងមួយភាគហ៊ុន (ដុល្លារអាមេរិក) | 2.09 | 2.03 |
| ផលចំណូលពីមូលធន (%) | 3.31 | 6.93 |
| ផលចំណូលពីទ្រព្យសកម្ម (%) | 0.65 | 1.46 |
| អនុបាតសន្ទនីយភាព (%) | 282 | 154 |
| អនុបាតឥណទានដុលធៀបនឹងប្រាក់បញ្ញើ (%) | 98.74 | 116.37 |
| អនុបាតឥណទានមិនដំណើរការធៀបនឹងឥណទានសរុប (%) | 6.18 | 4.04 |
| **ការគ្រប់គ្រងប្រាក់ដើមទុន** | | |
| មូលនិធិផ្ទាល់សុទ្ធ (ពាន់ដុល្លារអាមេរិក) | 137,570 | 144,730 |
| អនុបាតសោធនភាព (%) | 21.07 | 22.60 |

# សេចក្តីសង្ខេបផ្នែកហិរញ្ញវត្ថុ រយៈពេល 2 ឆ្នាំ

### ទ្រព្យសកម្មសរុប
(លានដុល្លារអាមេរិក)

| | |
|---|---|
| 2023 | 793.45 |
| 2022 | 721.08 |

### ឥណទាន និង បុរេប្រទាន
(លានដុល្លារអាមេរិក)

| | |
|---|---|
| 2023 | 582.25 |
| 2022 | 582.61 |

### ប្រាក់បញ្ញើ
(លានដុល្លារអាមេរិក)

| | |
|---|---|
| 2023 | 601.03 |
| 2022 | 507.88 |

### មូលនិធិម្ចាស់ភាគហ៊ុន
(លានដុល្លារអាមេរិក)

| | |
|---|---|
| 2023 | 157.09 |
| 2022 | 151.89 |

### ចំណូលប្រតិបត្តិការ
(លានដុល្លារអាមេរិក)

| | |
|---|---|
| 2023 | 79.31 |
| 2022 | 76.26 |

### ចំណេញមុនបង់ពន្ធ
(លានដុល្លារអាមេរិក)

| | |
|---|---|
| 2023 | 6.66 |
| 2022 | 13.78 |

# ការវិភាគលើលទ្ធផលហិរញ្ញវត្ថុ

## ចំណូលប្រតិបត្តិការ

ចំណូលប្រតិបត្តិការរបស់ធនាគារគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 មានចំនួន 79.31 លានដុល្លារអាមេរិក ដែលបានកើនឡើងចំនួន 4% បើប្រៀបធៀបជាមួយចំនួន 76.26 លានដុល្លារអាមេរិក កាលពីឆ្នាំកន្លងទៅដែលគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022។ម៉្យាងទៀត សមិទ្ធផលនេះគឺដោយសារកំណើនចំណូលការប្រាក់ពីឥណទាន និងប្រាក់បុរេប្រទានផ្តល់ឲ្យអតិថិជន ព្រមជាមួយនឹងការកើនឡើងនៃផលឥណទានរបស់ធនាគារ និងប្រាក់ចំណូលពីថ្លៃសេវាផងដែរ។ ប្រភពសំខាន់នៃចំណូលប្រតិបត្តិការរបស់ធនាគារសម្រាប់ឆ្នាំ2023 គឺការប្រាក់ពីឥណទាន និងប្រាក់បុរេប្រទាន ផ្តល់ដល់អតិថិជន និងការដាក់ប្រាក់ពីបញ្ញើតាមគ្រឹះស្ថានហិរញ្ញវត្ថុ (94.89%) និងការប្រមូលបានមកវិញនូវឥណទានដែលបានលុបចោលពីបញ្ជីពីមុន និងចំណូលពីការប្តូររូបិយប័ណ្ណបរទេស (1.25%) និងកម្រៃជើងសារ និងចំណូលពីសន្យាលើឥណទាន (3.86%)។

## ចំណេញមុនបង់ពន្ធ និងចំណេញក្នុងមួយភាគហ៊ុន

ធនាគារ បានប្រកាសចំណេញមុនបង់ពន្ធ 6.66 លានដុល្លារអាមេរិក នាដំណាច់ឆ្នាំត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ដោយមានការថយចុះតិចតួច បើប្រៀបធៀបនឹងចំនួនទឹកប្រាក់ចំណេញ 13.78 លានដុល្លារអាមេរិក សម្រាប់ឆ្នាំ2022 កន្លងទៅ។ អនុបាត (ផលធៀប) ចំណូលរបស់ធនាគារសម្រាប់ឆ្នាំ2023 មានកម្រិតខ្ពស់ជាង គឺ 0.76:1 ធៀបនឹង 0.70:1 កាលពីឆ្នាំកន្លងទៅ។ សមាសភាគចំណាយប្រតិបត្តិការរបស់ធនាគារសម្រាប់ឆ្នាំបច្ចុប្បន្ន ក្រោមការត្រួតពិនិត្យគឺប្រាក់ចំណាយលើបុគ្គលិក (54%) ចំណាយរំលស់ (15%) ចំណាយលើការផ្សព្វផ្សាយ និងទីផ្សារ (6%) ព្រមទាំងចំណាយផ្នែករដ្ឋបាល និងចំណាយប្រតិបត្តិការផ្សេងៗទៀត (25%)។

ធនាគារ ប្រកាសចំណេញសុទ្ធសម្រាប់ឆ្នាំនេះចំនួន 5.2 លានដុល្លារអាមេរិក បើធៀបនឹងចំណេញសុទ្ធចំនួន 10.53លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 នេះក៏ដោយសារតែការកើនឡើងនៃថ្លៃដើមមូលនិធិនៅលើទីផ្សារ បានធ្វើឲ្យចំណេញក្នុងមួយភាគហ៊ុនរបស់ធនាគារ សម្រាប់ឆ្នាំ2023 គឺ 0.07 ដុល្លារអាមេរិកធៀបនឹងចំណេញក្នុងមួយភាគហ៊ុន ចំនួន 0.14 ដុល្លារអាមេរិកសម្រាប់ឆ្នាំកន្លងទៅ។

## ពន្ធដារ

ពន្ធដារ រួមមាន ពន្ធលើប្រាក់ចំណូល និងពន្ធពន្យារ។ ដោយសារធនាគារទទួលបានចំណេញមុនបង់ពន្ធនាអំឡុងពេលបច្ចុប្បន្ន ដូច្នេះពន្ធលើប្រាក់ចំណូលរបស់ធនាគារ គឺត្រូវបង់ពន្ធប្រាក់ចំណេញចំនួន 20% ដោយអនុលោមតាមច្បាប់សារពើពន្ធរបស់ប្រទេសកម្ពុជា។ ធនាគារ ក៏ទទួលស្គាល់ពន្ធពន្យារជាទ្រព្យអកម្មចំនួន 1.43 លានដុល្លារអាមេរិក នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2023។

## បំណុលសរុប

ទ្រព្យអកម្មសរុបរបស់ធនាគារ បានកើនឡើងដល់ 636.36 លានដុល្លារអាមេរិក ក្នុងកាលបរិច្ឆេទត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ពី 569.19 លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022។

ប្រាក់កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអតិថិជន និងកម្ចីនៅតែជាសមាសភាគ សំខាន់នៃទ្រព្យអកម្មសរុបរបស់ធនាគារ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ដែលមានចំនួន 97.80% នៃទ្រព្យអកម្មសរុបរបស់ធនាគារ។

## ទ្រព្យសកម្មសរុប

ទ្រព្យសកម្មសរុបរបស់ធនាគារមានចំនួន 793.45 លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ដោយគិតជាភាគរយមានចំនួន 10.04% គឺមានការកើនឡើងពីចំនួន 721.08 លានដុល្លារអាមេរិក សម្រាប់ឆ្នាំ2022 កន្លងទៅ។ ទ្រព្យសកម្មរបស់ធនាគារ គឺផ្អែកជាចម្បងលើឥណទាន និងបុរេប្រទានដល់អតិថិជន (73.38%) សាច់ប្រាក់ និងសាច់ប្រាក់សមមូល (17.24%) ប្រាក់បញ្ញើនៅស្ថាប័នហិរញ្ញវត្ថុផ្សេងៗ (0.44%) ប្រាក់បញ្ញើនៅធនាគារកណ្តាល (ប្រាក់តម្កល់តាមច្បាប់ 6.10%) និងទ្រព្យសកម្មផ្សេងៗ (2.84%)។

## ប្រាក់បញ្ញើ កម្ចី និងអនុបំណុល

ប្រាក់បញ្ញើពីគ្រឹះស្ថានហិរញ្ញវត្ថុ និងអតិថិជនមានទំហំ 94.45% នៃទ្រព្យអកម្មសរុបត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ដែលរួមមាន ប្រាក់បញ្ញើរយៈពេលវែង

# ការវិភាគលើលទ្ធផលហិរញ្ញវត្ថុ

(82.62%) គណនីចរន្ត (6.82%) គណនីសន្សំ (10.56%)។ កម្ចី និងអនុបំណុលជាផ្នែកមួយដ៏សំខាន់ វាមានទំហំ 3.35% នៃទ្រព្យអកម្មសរុប។

## ឥណទាន និងបុរេប្រទាន

ឥណទាន និងបុរេប្រទាន ជាសំខាន់រួមមានលើឥណទានរយៈពេលវែងដល់អតិថិជន។ ឥណទាន និងបុរេប្រទានសរុបដុលដល់អតិថិជនបានកើនឡើង 0.41% គិតជាទឹកប្រាក់គឺ 593.45 លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ពីចំនួន 591.01 លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022។

## ដើមទុនលក្ខន្តិកៈ

ដើមទុនលក្ខន្តិកៈរបស់ធនាគារ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 មានចំនួន 75 លានដុល្លារអាមេរិក។

## មូលនិធិម្ចាស់ភាគហ៊ុន និងទ្រព្យសកម្មសុទ្ធក្នុងមួយហ៊ុន

គិតត្រឹមកាលបរិច្ឆេទថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 មូលនិធិម្ចាស់ភាគហ៊ុនរបស់ធនគារមានការកើនឡើងពី 151.89 លានដុល្លារអាមេរិកដល់ 157.09 ដុល្លារអាមេរិក។ ទ្រព្យសកម្មសុទ្ធក្នុងមួយហ៊ុនរបស់ធនាគារ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 មានចំនួន 2.09 ដុល្លារអាមេរិក (ក្នុងឆ្នាំ2022 ៖ 2.03 ដុល្លារអាមេរិក)។

## ចំណូលម្ចាស់ភាគហ៊ុន និងចំណូលទ្រព្យសកម្ម

ធនាគារបានកត់ត្រាចំណូល លើមូលនិធិម្ចាស់ភាគហ៊ុន និងទ្រព្យសកម្មមានភាពវិជ្ជមានសម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ដោយក្នុងនោះចំណូលម្ចាស់ 3.31% (ក្នុងឆ្នាំ2022 ៖ 6.93%) និងចំណូលទ្រព្យសកម្ម គឺ 0.65% (ក្នុងឆ្នាំ2022 ៖ 1.46%) ជាបន្តបន្ទាប់។

## អនុបាតឥណទានមិនដំណើរការធៀបនឹងឥណទានសរុប(%)

អនុបាតឥណទានមិនដំណើរការ ធៀបនឹងឥណទានសរុបគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 បានកើនឡើងដល់ 6.18% បើប្រៀបធៀបគិតត្រឹមកាលបរិច្ឆេទថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 មានចំនួន 4.04%។ ឥណទានមិនដំណើរការ ភាគច្រើនមានទ្រព្យតម្កល់ធានា ហើយធនាគារកំពុងស្ថិតក្នុងដំណើរការប្រមូលឥណទានមកវិញ។

## អនុបាតសាច់ប្រាក់ងាយស្រួល

អនុបាតផលធៀបងាយស្រួល គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 បានកើនឡើងដល់ 282% បើធៀបជាមួយនឹងចំនួន 154% គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ដែលការកើនឡើងនេះដោយសារលំហូរចូលនៃសាច់ប្រាក់ក្នុងរយៈពេលខ្លីច្រើនជាងលំហូរចេញ។ ធនាគារអនុវត្តទៅតាមប្រកាសលេខ B7-015-349 របស់ធនាគារកណ្តាលដែលតម្រូវឲ្យមានអនុបាតសាច់ប្រាក់ងាយស្រួលចំនួន 100%។ អនុបាតសាច់ប្រាក់ងាយស្រួលបង្ហាញថាធនាគារមានសមត្ថភាពក្នុងការផ្តល់ជូននូវការដកប្រាក់បញ្ញើដល់អតិថិជនរបស់ខ្លួន។

## មូលនិធិផ្ទាល់សុទ្ធ

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 មូលនិធិផ្ទាល់សុទ្ធរបស់ធនាគារមានចំនួន 137.57 លានដុល្លារអាមេរិក (2022៖ 144.73 លានដុល្លារអាមេរិក) គឺជាចំនួនលើសពីដើមទុនអប្បបរមាដែលតម្រូវឲ្យមានត្រឹម 75 លានដុល្លារអាមេរិក។

## អនុបាតឥណទានធៀបប្រាក់បញ្ញើ

អនុបាតឥណទានធៀបប្រាក់បញ្ញើរបស់ធនាគារគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 បានធ្លាក់ចុះបន្តិច 98.74% បើធៀបនឹង 116.37% គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ដែលភាគច្រើនដោយសារតែកំណើន នៃសមតុល្យប្រាក់បញ្ញើ ពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ និងពីអតិថិជន ដែលមួយផ្នែកត្រូវបានទូទាត់ជាមួយនឹង ការកើនឡើងនៃឥណទាន។

## អនុបាតសោធនភាព

អនុបាតសោធនភាព ផ្តល់នូវការវាស់ស្ទង់នៃមូលនិធិផ្ទាល់សុទ្ធ របស់ធនាគារ គិតជាភាគរយនៃកម្រិតហានិភ័យឥណទានដែលបានកើតឡើង។ គិតត្រឹមកាលបរិច្ឆេទត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 អនុបាតសោធនភាពរបស់ធនាគារចំនួន 21.07% (ឆ្នាំ2022៖ 22.60%) គឺអនុលោមទៅតាមប្រកាសលេខ B7-04-6 ធនាគារកណ្តាល ដែលតម្រូវឲ្យមានអនុបាតសោធនភាពយ៉ាងតិច 15%។

# គោលនយោបាយ និងគោលការណ៍អនុវត្តន៍សម្រាប់អភិបាលកិច្ចក្រុមហ៊ុន

## ការត្រួតពិនិត្យ និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ("ក្រុមប្រឹក្សា") ប្តេជ្ញាចិត្តគោរពតាមគោលការណ៍អភិបាលកិច្ចក្រុមហ៊ុន និងត្រួតពិនិត្យលើរាល់តម្រូវការ និងការអនុវត្តន៍អភិបាលកិច្ចរបស់ក្រុមហ៊ុន។ ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សារួមមាន៖

- ត្រួតពិនិត្យ និងតាមដានទៅលើប្រតិបត្តិការធ្វើអាជីវកម្មរបស់ធនាគារ
- ដាក់ចេញនូវទិសដៅ ផែនការយុទ្ធសាស្ត្រអាជីវកម្ម និងផែនការថវិកាប្រចាំឆ្នាំរបស់ធនាគារសម្រាប់អនុវត្ត
- ត្រួតពិនិត្យឡើងវិញ និងធានារាល់លើផែនការសកម្មភាព ដែលបានអនុវត្តដោយគណៈគ្រប់គ្រងដើម្បីសម្រេចបានតាមយុទ្ធសាស្ត្រ និងគោលដៅអាជីវកម្មដែលកំណត់ដោយដោយក្រុមប្រឹក្សាភិបាល
- កំណត់អត្តសញ្ញាណហានិភ័យចម្បង ដែលធនាគារអាចនឹងប្រឈម និងធានានូវរាល់ការអនុវត្តន៍ទៅលើប្រព័ន្ធគ្រប់គ្រង ហានិភ័យទាំងនោះបានទាន់ពេលវេលា
- ពិនិត្យលើសុច្ចរិតភាព និងភាពគ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់ធនាគារ ដែលរួមមានប្រព័ន្ធសម្រាប់អនុលោមច្បាប់ វិន័យ និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

## សមាសភាពរបស់ក្រុមប្រឹក្សាភិបាល

ធនាគារត្រូវបានដឹកនាំ និងគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល និងសមាជិកដែលពោរពេញដោយបទពិសោធន៍ទូលំទូលាយក្នុងវិស័យធនាគារពាណិជ្ជ និងធនាគារវិនិយោគ ក៏ដូចជាចំណេះដឹងផ្នែកសវនកម្ម។ គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ2023 ក្រុមប្រឹក្សាភិបាលរួមមាន អភិបាលប្រឹក្សាចំនួន 07រូប ដែល 1រូបជាប្រធានក្រុមប្រឹក្សាភិបាល 02រូប ជាអភិបាលប្រឹក្សាមិនឯករាជ្យ (ប្រតិបត្តិតាម) និង 04រូប ជាអភិបាលប្រឹក្សាឯករាជ្យ (មិនប្រតិបត្តិតាម)។

មុខងាររបស់អភិបាលប្រតិបត្តិ និងអភិបាលប្រឹក្សាមិនប្រតិបត្តិ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា។ អភិបាលប្រឹក្សា( មិនប្រតិបត្តិ) មានតួនាទីបំពេញជំនាញ និងបទពិសោធន៍ និងជួយបង្កើតយុទ្ធសាស្ត្រ និងគោលនយោបាយរបស់ធនាគារ ជាមួយនឹងអភិបាលប្រតិបត្តិ ដើម្បីពិនិត្យ និងធានាតុល្យភាពថា ធនាគារដំណើរការក្នុងក្រុមខណ្ឌអភិបាលកិច្ចត្រឹមត្រូវស្របតាមប្រព័ន្ធ និងការត្រួតពិនិត្យផ្ទៃក្នុងដែលបានដាក់ឲ្យអនុវត្ត។ អភិបាលប្រតិបត្តិទទួលខុសត្រូវក្នុងការផ្តល់ការ សម្រេចចិត្តប្រតិបត្តិ និងការអនុវត្តន៍សកម្មភាពយុទ្ធសាស្ត្ររបស់ធនាគារ។ អភិបាលប្រឹក្សាឯករាជ្យនៅក្នុងក្រុមប្រឹក្សាភិបាល ជាអ្នកផ្តល់នូវការវិនិច្ឆ័យឯករាជ្យ និងចូលរួមក្នុងដំណើរការនីតិវិធី នៃការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល។

ក្រុមប្រឹក្សាភិបាលបានទទួលស្គាល់សមាសភាព នៃក្រុមប្រឹក្សាភិបាលអាណត្តិថ្មី សម្រាប់ឆ្នាំ2023-2025 នៅក្នុងកំឡុងពេលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនាខែធ្នូ ឆ្នាំ2022 ហើយធនាគារជាតិ នៃកម្ពុជាបានអនុម័ត និងទទួលស្គាល់ចំពោះបទពិសោធន៍ពាក់ព័ន្ធនឹងមុខងាររៀងៗខ្លួន របស់សមាជិកក្រុមប្រឹក្សាភិបាល។

សមាសភាព នៃក្រុមប្រឹក្សាភិបាល ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ក្រុមប្រឹក្សាភិបាលដើម្បីរក្សានូវតុល្យភាព នៃហិរញ្ញវត្ថុ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព ដើម្បីធានាឲ្យបាននូវការដឹកនាំ និងការគ្រប់គ្រងធនាគារ ឱ្យមានប្រសិទ្ធភាពខ្ពស់។

ក្រុមប្រឹក្សាភិបាល បានបង្កើតគណៈកម្មការចំនួន 04 ដើម្បីជាជំនួយដល់ក្រុមប្រឹក្សាភិបាលក្នុងការគ្រប់គ្រងអាជីវកម្ម និងបំពេញភារកិច្ចតាមតួនាទីរបស់ខ្លួន។ តួនាទី និងក្របខណ្ឌនៃគណៈកម្មាធិការ ក៏ដូចជាសិទ្ធិអំណាចផ្តល់ដោយក្រុមប្រឹក្សា ដល់គណៈកម្មាធិការទាំងនេះត្រូវបានកំណត់យ៉ាងជាក់លាក់ដោយក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការទាំង 04 រួមមាន៖

| គណៈកម្មាធិការ | ទទួលបន្ទុក |
|---|---|
| គណៈកម្មាធិការសវនកម្ម | អភិបាលឯករាជ្យ-មិនប្រតិបត្តិ |
| គណៈកម្មាធិការគ្រប់គ្រងហានិភ័យ | អភិបាលឯករាជ្យ-មិនប្រតិបត្តិ |
| គណៈកម្មាធិការតែងតាំងនិងវាយតម្លៃ | អភិបាលឯករាជ្យ-មិនប្រតិបត្តិ |
| គណៈកម្មាធិការព័ត៌មានវិទ្យា | អភិបាលឯករាជ្យ-មិនប្រតិបត្តិ |

# គោលនយោបាយ និងគោលការណ៍អនុវត្តន៍សម្រាប់អភិបាលកិច្ចក្រុមហ៊ុន

## (I) គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្ម ផ្តល់នូវការត្រួតពិនិត្យឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុ និងត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ និងធានានូវការត្រួតពិនិត្យ និងគុណភាពក្នុងធនាគារ។

គណៈកម្មាធិការសវនកម្មរួមមានសមាជិកចំនួន 03រូប ពីក្រុមប្រឹក្សាភិបាល ដូចខាងក្រោម៖

1. លោកស្រី Seah Yen Goon (ប្រធាន)
2. លោក Paul Gwee Choon Guan
3. លោក Ong Teong Hoon

គណៈកម្មាធិការសវនកម្មបានទទួលសិទ្ធិពីក្រុមប្រឹក្សាភិបាលដើម្បីបំពេញកិច្ចការដូចខាងក្រោម៖

### គ្រប់គ្រងទៅលើការប្រតិបត្តិទូទៅ

- ពិនិត្យមើលប្រតិបត្តិតាមការវាយតម្លៃហានិភ័យរបស់ថ្នាក់គ្រប់គ្រង។
- បង្កើត និងតាមដានការប្រតិបត្តិតាមក្រមប្រតិបត្តិរបស់ក្រុមហ៊ុន។
- តាមដាននីតិវិធីសម្រាប់ការប្រតិបត្តិតាមបទប្បញ្ញត្តិ របស់រាជរដ្ឋាភិបាល។
- ពិនិត្យមើលលទ្ធផលនៃការធ្វើសវនកម្ម ឬការពិនិត្យដែលភ្នាក់ងារផ្សេងទៀតដែលបានអនុវត្ត។
- ពិភាក្សាអំពីភាពមិនស្របគ្នារវាងសវនករខាងក្នុង ឬខាងក្រៅ និងការគ្រប់គ្រង។

### គ្រប់គ្រងរចនាសម្ព័ន្ធគ្រប់គ្រងផ្ទៃក្នុង

- ពិនិត្យមើលភាពគ្រប់គ្រាន់នៃរចនាសម្ព័ន្ធគ្រប់គ្រងផ្ទៃក្នុងពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុ។
- គ្រប់គ្រងការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន ដើម្បីការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន។

### គ្រប់គ្រងសវនករផ្ទៃក្នុង

- វាយតម្លៃភាពមិនលម្អៀងរបស់សវនករផ្ទៃក្នុង។
- ត្រួតពិនិត្យការងារ និងវាយតម្លៃលទ្ធផលការងាររបស់សវនករផ្ទៃក្នុង។
- ត្រូវធានាថា សវនករផ្ទៃក្នុងចូលរួម និងសម្របសម្រួលក្នុងដំណើរការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុជាមួយសវនករខាងក្រៅ (ឯករាជ្យ)។

### គ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុ

- ជួយថ្នាក់គ្រប់គ្រងក្នុងការពិនិត្យមើលលក្ខខណ្ឌយោង សម្រាប់ការធ្វើសវនកម្មឯករាជ្យ។
- ផ្តល់ការណែនាំសម្រាប់ការតែងតាំងសវនករឯករាជ្យ។
- ជួយអ្នកគ្រប់គ្រងនិងពិនិត្យមើលលទ្ធផលសវនកម្មជាមួយសវនករឯករាជ្យ និងអ្នកគ្រប់គ្រង។
- ពិនិត្យមើលលិខិតគ្រប់គ្រង ដែលរៀបចំដោយសវនករខាងក្រៅ (ឯករាជ្យ)។

## (II) គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

គណៈកម្មាធិការគ្រប់គ្រងហានិភ័យមានមុខងារត្រួតពិនិត្យឡើងវិញនិងផ្តល់អនុសាសន៍គោលម្ខទៅលើសកម្មភាពគ្រប់គ្រងហានិភ័យឥណទាន ហានិភ័យទីផ្សារ ហានិភ័យអត្រាការប្រាក់ ហានិភ័យសន្ទនីយភាព ហានិភ័យប្រតិបត្តិការ ហានិភ័យប្រតិបត្តិតាម និងហានិភ័យផ្សេងៗ ដើម្បីធានាថាដំណើរការគ្រប់គ្រងត្រូវបានរៀបចំឡើង និងដំណើរការបានល្អ។

សមាសភាពគណៈកម្មាធិការគ្រប់គ្រងហានិភ័យ រួមមាន សមាជិក 3 រូប ពីក្រុមប្រឹក្សាភិបាលរួមមាន៖

1. លោក Paul Gwee Choon Guan (ប្រធាន)
2. លោក Ong Teong Hoon
3. លោកស្រី Seah Yen Goon

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ត្រូវបានផ្តល់សិទ្ធិអំណាចដោយក្រុមប្រឹក្សាភិបាលដើម្បី៖

- ពិនិត្យ និងណែនាំយុទ្ធសាស្រ្តគ្រប់គ្រងហានិភ័យគោលនយោបាយនិងរឹសអាប់តែថាយ (Risk Appetite) និងរឹថលើរែន (Risk Tolerance) ដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សាភិបាល។ ហានិភ័យទាំងនេះ នឹងគ្របដណ្តប់លើហានិភ័យយុទ្ធសាស្រ្តរបស់សហគ្រាសរួមមាន៖ ហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ ហានិភ័យសុវត្ថិភាពព័ត៌មានវិទ្យា ហានិភ័យអត្រាការប្រាក់ ហានិភ័យសន្ទនីយភាព និងហានិភ័យអត្រាប្តូរប្រាក់។

# គោលនយោបាយ និងគោលការណ៍អនុវត្តន៍សម្រាប់អភិបាលកិច្ចក្រុមហ៊ុន

- ពិនិត្យផលិតផលថ្មីៗ បន្ទាប់មកធានាថា ផលិតផលថ្មីបានឆ្លងកាត់ដំណើរការវាយតម្លៃត្រឹមត្រូវ និងណែនាំទៅកាន់ក្រុមប្រឹក្សាភិបាលដើម្បីធ្វើការអនុម័ត ប្រសិនបើដែលផលិតផលហិរញ្ញវត្ថុនោះលើសពីសញ្ញាបណ្ណធម្មតា។
- ពិនិត្យលើការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល និងមុខងារ នៃការបែងចែកដើមទុន ដោយរួមបញ្ចូលទាំងការផ្ទេរថ្លៃ (fund transfer pricing) ទៅតាមករណីពាក់ព័ន្ធនីមួយៗ។
- កំណត់ដើមទុនសម្រាប់រីសអាប់ភែថាយ (risk appetite) ដើម្បីផ្ទេរសិទ្ធិទៅគណៈកម្មាធិការទ្រព្យ និងបំណុល។
- ពិនិត្យ និងវាយតម្លៃភាពគ្រប់គ្រាន់នៃគោលនយោបាយ និងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ ក្នុងការស្វែងរក វាស់វែង តាមដាន និងត្រួតពិនិត្យហានិភ័យ និងវិសាលភាព ដែលគោលនយោបាយទាំងនេះមានភាពគ្រប់គ្រាន់ និងធ្វើប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងឯករាជ្យ។
- ធានាថាធនាគារមានហេដ្ឋារចនាសម្ព័ន្ធ ធនធាន និងប្រព័ន្ធសម្រាប់គ្រប់គ្រងហានិភ័យ ពោលគឺធានាថា បុគ្គលិកធនាគារត្រូវមានទំនួលខុសត្រូវក្នុងការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងហានិភ័យ និងបំពេញភារកិច្ចទាំងនោះដោយឯករាជ្យតាមទំហំហានិភ័យ ដែលក្រុមហ៊ុនសម្រេចទទួល ។
- ពិនិត្យមើលរបាយការណ៍តាមកាលកំណត់របស់អ្នកគ្រប់គ្រងអំពីការប្រឈមនឹងហានិភ័យសមាសភាពផតហ្វូលីអូរីស (risk portfolio composition) និងសកម្មភាពគ្រប់គ្រងហានិភ័យ។
- ពិនិត្យ និងអនុម័តផ្ទាំងគ្រប់គ្រងហានិភ័យប្រចាំឆ្នាំ (សូចនាករហានិភ័យសំខាន់ៗ) ចំពោះហានិភ័យដែលធនាគារបានជួបប្រទះ និងគោលនយោបាយក្របខ័ណ្ឌត្រួតពិនិត្យផ្ទៃក្នុងទាំងមូល។
- ពិនិត្យឡើងវិញទៅលើបញ្ជីប្រតិបត្តិតាមរបស់ធនាគាររៀងរាល់6ខែម្តង។
- ពិនិត្យ និងផ្តល់អនុសាសន៍ ទៅលើគោលនយោបាយប្រតិបត្តិតាម និង គោលនយោបាយហានិភ័យ ដើម្បីសុំការអនុម័តពីក្រុមប្រឹក្សាភិបាល
- មើលការខុសត្រូវ និងត្រួតពិនិត្យនាយកដ្ឋានហានិភ័យ និងនាយកដ្ឋានប្រតិបត្តិតាម
- ធ្វើការវាយតម្លៃប្រចាំឆ្នាំ លើការអនុវត្តន៍ការងាររបស់ប្រធាននាយកដ្ឋានប្រតិបត្តិតាម និងការគ្រប់គ្រងហានិភ័យ។

## (III) គណៈកម្មការតែងតាំង និងវាយតម្លៃ

គណៈកម្មាធិការតែងតាំង និងវាយតម្លៃ គឺជាអ្នករៀបចំទម្រង់ និងបង្កើតនីតិវិធីតម្លាភាពនៅក្នុងការតែងតាំងអភិបាល, សមាជិកគណៈកម្មាធិការ និងមន្ត្រីគ្រប់គ្រងជាន់ខ្ពស់សំខាន់ៗ ក៏ដូចជាការវាយតម្លៃប្រសិទ្ធភាពការងាររបស់អភិបាលម្នាក់ៗ ក្រុមប្រឹក្សាភិបាលទាំងមូល និងការអនុវត្តន៍ការងាររបស់មន្ត្រីគ្រប់គ្រងជាន់ខ្ពស់សំខាន់ៗ។ គណៈកម្មាធិការនេះ ក៏ជាអ្នករៀបចំនូវទម្រង់ និងនីតិវិធីផ្លូវការ និងតម្លាភាព សម្រាប់គោលនយោបាយតម្លើងប្រាក់ឈ្នួលដល់អភិបាល និងមន្ត្រីគ្រប់គ្រងជាន់ខ្ពស់សំខាន់ៗ និងធានាថាការផ្តល់ឱ្យនេះសមស្របទៅតាមវប្បធម៌ គោលបំណង និងយុត្តិសាស្ត្រក្រុម។

គណៈកម្មាធិការតែងតាំង និងវាយតម្លៃ រួមមានសមាជិកចំនួន 03រូប ពីក្រុមប្រឹក្សាភិបាលដូចខាងក្រោម៖

1. លោក Koh Yong Guan (ប្រធាន)
2. លោក Lim Hua Min
3. លោក Ong Teong Hoon

គណៈកម្មាធិការតែងតាំង និងវាយតម្លៃ ទទួលសិទ្ធិអំណាចពីក្រុមប្រឹក្សាភិបាលដើម្បីបំពេញកិច្ចការដូចខាងក្រោម៖

- ពិនិត្យអំពីទំហំ និងសមាសភាពនៃក្រុមប្រឹក្សាភិបាល និងកំណត់អំពីសមតុល្យរបស់ក្រុមប្រឹក្សាភិបាល រវាងក្រុមប្រឹក្សាប្រតិបត្តិ ក្រុមប្រឹក្សាមិនប្រតិបត្តិ និងអភិបាលឯករាជ្យ។
- ពិនិត្យ និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលនូវតម្រូវការជំនាញចម្រុះ បទពិសោធន៍ គុណវុឌ្ឍិ និងសមត្ថភាពស្នូលផ្សេងទៀតដែលត្រូវមានសម្រាប់អភិបាល។ លក្ខខណ្ឌតម្រូវ និងលក្ខណៈវិនិច្ឆ័យបែបនេះគួរតែមានការអនុម័តពីក្រុមប្រឹក្សាភិបាល។
- ណែនាំ និងវាយតម្លៃបេក្ខជនសម្រាប់តំណែងអភិបាល សមាជិកគណៈកម្មាធិការក្រុមប្រឹក្សាភិបាល ក៏ដូចជាបេក្ខជនសម្រាប់តំណែងមន្ត្រីគ្រប់គ្រងជាន់ខ្ពស់សំខាន់ៗ។ ការសម្រេចអំពីថាអ្នកដែលត្រូវតែងតាំងគឺជាការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល។

- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលក្នុងការដកតំណែងអភិបាល ឬមន្ត្រីគ្រប់គ្រងជាន់ខ្ពស់សំខាន់ៗ ប្រសិនបើពួកគាត់ធ្វើការមិនមានប្រសិទ្ធភាព ខុសឆ្គង និងធ្វេសប្រហែសក្នុងការអនុវត្តន៍ទំនួលខុសត្រូវការងាររបស់ខ្លួន។
- បង្កើតយន្តការសម្រាប់ការវាយតម្លៃជាផ្លូវការលើប្រសិទ្ធភាព នៃក្រុមប្រឹក្សាភិបាលទាំងមូល និងការរួមចំណែករបស់អភិបាលនីមួយៗ ចំពោះប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាភិបាល ការរួមចំណែករបស់គណៈកម្មាធិការផ្សេងៗរបស់ក្រុមប្រឹក្សាភិបាល និងការអនុវត្តន៍ការងាររបស់មន្ត្រីគ្រប់គ្រងជាន់ខ្ពស់សំខាន់ៗ។
- ត្រួតពិនិត្យការតែងតាំង ការធ្វើផែនការបន្តតំណែងគ្រប់គ្រង និងការវាយតម្លៃការអនុវត្តន៍ការងាររបស់មន្ត្រីគ្រប់គ្រងជាន់ខ្ពស់សំខាន់ៗ និង
- ណែនាំក្របខណ្ឌសម្រាប់ប្រាក់បំណាច់របស់សមាជិកក្រុមប្រឹក្សាអភិបាល និងមន្ត្រីគ្រប់គ្រងជាន់ខ្ពស់សំខាន់ៗ។ ក្របខណ្ឌបែបនេះគួរតែឆ្លុះបញ្ចាំងពីការទទួលខុសត្រូវ បទពិសោធន៍ និងការប្តេជ្ញាចិត្តរបស់អភិបាល និងមន្ត្រីគ្រប់គ្រងជាន់ខ្ពស់ពាក់ព័ន្ធសំខាន់ៗទាំងអស់។ កញ្ចប់ប្រាក់បំណាច់គួរតែមានការរៀបចំឱ្យមានភាពប្រកួតប្រជែង និងស្របតាមវប្បធម៌ គោលបំណង និងយុទ្ធសាស្ត្ររបស់ធនាគារ និងស្តង់ដារទីផ្សារ។ ប្រាក់បៀវត្សគួរស្ថិតនៅក្នុងវិសាលភាពនៃគោលនយោបាយអាជីវកម្មទូទៅ និងមិនអាស្រ័យលើការអនុវត្តន៍ការងាររយៈពេលខ្លី ដើម្បីជៀសវាងការផ្តល់ប្រាក់លើកទឹកចិត្តសម្រាប់ការទទួលយកហានិភ័យលើសកម្រិត។

## (IV) គណៈកម្មាធិការព័ត៌មានវិទ្យា

តួនាទីរបស់គណៈកម្មាធិការព័ត៌មានវិទ្យា គឺដើម្បីជួយសម្រួលដល់គណកម្មាធិការប្រតិបត្តិ ក្នុងការអនុវត្តន៍យុទ្ធសាស្ត្រព័ត៌មានវិទ្យា ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ តួនាទីនេះរួមបញ្ចូលទាំងការកំណត់អាទិភាពលើការវិនិយោគផ្នែកព័ត៌មានវិទ្យា ការពិនិត្យមើលស្ថានភាពនៃគម្រោង (រួមបញ្ចូលទាំងទំនាស់ក្នុងការបែងចែកធនធាន) ការត្រួតពិនិត្យកម្រិតសេវាកម្ម និងការកែលម្អ ការបញ្ជូនសេវាកម្មព័ត៌មានវិទ្យា និងគម្រោងនានា។

សមាជិក នៃគណៈកម្មាធិការព័ត៌មានវិទ្យារួមមាន៖

| | |
|---|---|
| ■ អភិបាលឯករាជ្យ | ប្រធាន |
| ■ នាយកប្រតិបត្តិ ឌីជីថល | ប្រធានស្តីទី |
| ■ អគ្គនាយក | សមាជិក |
| ■ អគ្គនាយករង | សមាជិក |
| ■ នាយកប្រតិបត្តិ ប្រព័ន្ធធនាគារអេឡិចត្រូនិក ឬ តំណែងសមមូល | សមាជិក |
| ■ នាយកប្រតិបត្តិ បច្ចេកវិទ្យា ឬតំណែងសមមូល | សមាជិក |
| ■ នាយិកាប្រតិបត្តិ ហិរញ្ញវត្ថុ ឬតំណែងសមមូល | សមាជិក |
| ■ នាយិកាប្រតិបត្តិ ធនធានមនុស្ស ឬ តំណែងសមមូល | សមាជិក |
| ■ នាយក នាយកដ្ឋានសុវត្ថិភាពព័ត៌មានវិទ្យា ឬ តំណែងសមមូល | សមាជិក |
| ■ នាយក នាយកដ្ឋានហានិភ័យ ឬតំណែងសមមូល | សមាជិក |
| ■ នាយក នាយកដ្ឋានប្រតិបត្តិតាម ឬតំណែងសមមូល | សមាជិក |
| ■ នាយក នាយកដ្ឋានព័ត៌មានវិទ្យាដែលពាក់ព័ន្ធ ឬ តំណែងសមមូល | សមាជិក |
| ■ លេខាធិការធនាគារ | លេខាធិការ |

គណៈកម្មាធិការព័ត៌មានវិទ្យាបានទទួលសិទ្ធិពីក្រុមប្រឹក្សាភិបាលដើម្បី៖

- ត្រួតពិនិត្យការអភិវឌ្ឍន៍ និងអនុវត្តយុទ្ធសាស្ត្រព័ត៌មានវិទ្យារបស់ធនាគារ ស្របតាមយុទ្ធសាស្ត្រអាជីវកម្មទាំងមូល។
- ពិនិត្យឡើងវិញ និងអនុម័តគោលនយោបាយ ស្តង់ដារ និងនីតិវិធីព័ត៌មានវិទ្យា ដើម្បីធានាគោលនយោបាយ ស្តង់ដារ និងនីតិវិធីទាំងអស់នេះគ្រប់ជ្រុងជ្រោយ មានបច្ចុប្បន្នភាព និងអនុលោម តាមបទប្បញ្ញត្តិពាក់ព័ន្ធ។
- តាមដានហានិភ័យរបស់ព័ត៌មានវិទ្យា និងធានាថាមានយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យដែលសមស្រប។
- ពិនិត្យ និងអនុម័តកញ្ចប់ថវិកាព័ត៌មានវិទ្យា ដើម្បីធានាថាមានមូលនិធិគ្រប់គ្រាន់សម្រាប់ផ្តួចផ្តើម និងរៀបគម្រោងព័ត៌មានវិទ្យា។
- វាយតម្លៃ និងផ្តល់ការណែនាំអំពីគម្រោងព័ត៌មានវិទ្យាសំខាន់ៗ រួមបញ្ចូលទាំងការកំណត់អាទិភាពនៃគម្រោង ការបែងចែកធនធាន និងការតាមដានវឌ្ឍនភាពគម្រោង។
- តាមដានការវាស់វែងការអនុវត្តន៍ការងារព័ត៌មានវិទ្យា និងធានាមានដំណោះស្រាយទាន់ពេលវេលាចំពោះ បញ្ហាដែលទាក់ទងនឹងព័ត៌មានវិទ្យា។

# គោលនយោបាយ និងគោលការណ៍អនុវត្តន៍សម្រាប់អភិបាលកិច្ចក្រុមហ៊ុន

- ពិនិត្យ និងវាយតម្លៃវិធានការសុវត្ថិភាពព័ត៌មានវិទ្យា រួមបញ្ចូលទាំងសាយបឺសេខ្ញីធី ប្រូថូខូល (Cybersecurity protocols) ផែនការឆ្លើយតបនឹងបញ្ហា និងនីតិវិធីសង្គ្រោះគ្រោះនៅពេលមានបញ្ហា។
- តាមដានជាប្រចាំទៅលើបច្ចេកវិទ្យាដែលកំពុងរីកចម្រើន និងនិន្នាការក្នុងវិស័យធនាគារ ដោយផ្តល់ អនុសាសន៍លើការទទួលយក ឬការដាក់បញ្ចូលបច្ចេកវិទ្យាថ្មីៗដែលសមស្រប។
- ផ្តល់ការត្រួតពិនិត្យ និងការណែនាំទៅលើការគ្រប់គ្រងអ្នកផ្គត់ផ្គង់សេវាផ្នែកព័ត៌មានវិទ្យា រួមបញ្ចូលទាំងការជ្រើសរើសអ្នកផ្គត់ផ្គង់ ការចរចាកិច្ចសន្យា និងការវាយតម្លៃការអនុវត្តន៍។
- សហការជាមួយមុខងារសវនកម្មផ្ទៃក្នុង និងអនុលោមភាព ដើម្បីធានាថាបានបំពេញតាមលក្ខខណ្ឌនៃការធ្វើសវនកម្ម និងបទប្បញ្ញត្តិទាក់ទងនឹងព័ត៌មានវិទ្យា ។
- ធានាឱ្យបាននូវការអនុវត្តន៍គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហានិភ័យផ្នែកបច្ចេកវិទ្យាតាមលក្ខខណ្ឌកំណត់ដោយធនាគារជាតិនៃកម្ពុជា (NBC)។

## ដំណើរការនៃការតែងតាំងក្រុមប្រឹក្សាភិបាល

បេក្ខជនឈរឈ្មោះទាំងអស់សម្រាប់តែងតាំងចូលក្នុងក្រុមប្រឹក្សាភិបាលជាដំបូងត្រូវឆ្លងកាត់ការវាយតម្លៃដោយគណៈកម្មាធិការតែងតាំង និងវាយតម្លៃ ហើយគណៈកម្មាធិការនេះនឹងដាក់សំណើរទៅក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលនឹងធ្វើការសម្រេចចិត្តជាផ្លូវការក្នុងការតែងតាំងបេក្ខជននោះធ្វើជាសមាជិកក្រុមប្រឹក្សាភិបាល។ នៅពេលវាយតម្លៃបេក្ខជនឈរឈ្មោះសម្រាប់តែងតាំងក្នុងក្រុមប្រឹក្សាភិបាល គឺទាមទារនូវលក្ខខណ្ឌពិចារណាមួយចំនួនដូចជាគុណភាព ជំនាញនិងបទពិសោធន៍ភាពសាកសម និងសមត្ថភាពប្រកួតប្រជែងជាមូលដ្ឋាន ដែលទាមទារឲ្យមានសម្រាប់មុខតំណែង និងតុល្យភាពក្រុមប្រឹក្សាភិបាល។

## គោលនយោបាយ និងគោលការណ៍អនុវត្តន៍សម្រាប់អភិបាលកិច្ចក្រុមហ៊ុន

### កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងយ៉ាងតិចរៀងរាល់ 3ខែម្តង។ ក្នុងឆ្នាំ2023 គិតត្រឹមបំណាច់ឆ្នាំ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ក្រុមប្រឹក្សាភិបាលជួបប្រជុំគ្នា ចំនួន 4លើក។

អភិបាលនីមួយៗ ត្រូវបានផ្តល់ព័ត៌មានអំពីកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងផ្តល់ជូននូវរបៀបវារៈជាមុន នៅរៀងរាល់ការប្រជុំម្តងៗ ដើម្បីឲ្យអភិបាលគ្រប់រូបមានពេលវេលាក្នុងការសិក្សា និងរៀបចំសម្រាប់ការពិភាក្សា។ ក្រុមប្រឹក្សាភិបាល ក៏មានកាលបរិច្ឆេទផ្លូវការ សម្រាប់ការពិចារណា និងសម្រេចចិត្តលើបញ្ហាមួយចំនួនផងដែរ។ រាល់កំណត់ត្រាក្នុងកិច្ចប្រជុំត្រូវបានកត់ត្រា និងរក្សាទុកយ៉ាងល្អ និងប្រគល់ឱ្យទៅកាន់សមាជិកក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំជាន់ខ្ពស់ទាំងអស់របស់ធនាគារ។

គណៈគ្រប់គ្រងធនាគារ បានអនុម័តលើគោលការណ៍រួមរបស់សម្ព័ន្ធក្រុមហ៊ុន ស្តីពីព័ត៌មានសម្រាប់ដាក់ជូនក្រុមប្រឹក្សាភិបាលពិចារណា។ យោងតាមគោលនយោបាយនេះ គ្រប់កំណត់ត្រាព័ត៌មានទាំងអស់ ត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលទៅតាមពេលវេលាកំណត់មួយ ដើម្បីក្រុមប្រឹក្សាភិបាលបានដឹងអំពីដំណើរការការងារ និងសកម្មភាពអាជីវកម្មរបស់ធនាគារ។

អភិបាលអាចស្វែងរកសេវាណែនាំ និងជំនួយពីលេខាររបស់ក្រុមហ៊ុនដែលពួកគេជាអ្នកទទួលខុសត្រូវក្នុងការធានាថា នីតិវិធីក្រុមប្រឹក្សាភិបាលត្រូវបានគេគោរពតាម ហើយរាល់ព័ត៌មានចាំបាច់ដែលនឹងត្រូវទទួលបានពីអភិបាល គឺសម្រាប់កំណត់ត្រាផ្ទាល់របស់ធនាគារផង និងគោលបំណងដើម្បីបំពេញកាតព្វកិច្ចក្នុងលក្ខន្តិកៈផង។

ព័ត៌មានលម្អិតនៃវត្តមានរបស់អភិបាល ដែលបានចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសម្រាប់ឆ្នាំសារពើព័ន្ធថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 មានដូចខាងក្រោម៖

| ឈ្មោះអភិបាល | ចំនួនវត្តមានក្នុងការប្រជុំ |
|---|---|
| លោក Lim Hua Min (Chairman) | 4/4 |
| លោក Koh Yong Guan | 4/4 |
| លោក Ong Teong Hoon | 4/4 |
| លោកស្រី Seah Yen Goon | 4/4 |
| លោក Paul Gwee Choon Guan | 4/4 |
| លោក Chan Mach | 4/4 |
| លោក Pen Chanda | 4/4 |

# គោលនយោបាយ និងគោលការណ៍អនុវត្តន៍សម្រាប់អភិបាលកិច្ចក្រុមហ៊ុន

## ការទទួលខុសត្រូវ

ក្រុមប្រឹក្សាទទួលស្គាល់ពីសារៈសំខាន់នៃការថែរក្សាកំណត់ត្រាគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់ភាគហ៊ុន និងទ្រព្យសម្បត្តិរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាលធានាអះអាងពីការទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ ដែលក្នុងនោះរួមបញ្ចូលទាំងការបង្កើតបរិយាកាសត្រួតពិនិត្យសមស្រប និងក្របខណ្ឌគ្រប់គ្រងហានិភ័យក៏ដូចជាការត្រួតពិនិត្យលើភាពត្រឹមត្រូវ និងគ្រប់គ្រាន់របស់វា។ ទាក់ទងនឹងការកំណត់មូលដ្ឋាននៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងផ្សេងៗ ប្រព័ន្ធគឺត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងហានិភ័យ និងធានាថាហានិភ័យត្រូវបានរកឃើញ និងគ្រប់គ្រងនៅក្នុងកម្រិតមួយ ដែលគេអាចទទួលយកបានជាជាងមើលរំលងហានិភ័យទាំងនោះ ដើម្បីសម្រេចគោលដៅអាជីវកម្ម។ ប្រព័ន្ធនេះអាចត្រឹមតែផ្តល់ការធានាដ៏សមហេតុផលមួយតែប៉ុណ្ណោះ តែមិនមែនជាការធានាពេញលេញ ដើម្បីទប់ទល់នឹងហានិភ័យ នៃកំហុសធំៗនៃព័ត៌មានក្នុងការគ្រប់គ្រងកំហុសធំនៃព័ត៌មានហិរញ្ញវត្ថុ ឬការបាត់បង់ហិរញ្ញវត្ថុ ឬការក្លែងបន្លំហិរញ្ញវត្ថុឡើយ។

## គន្លឹះក្នុងការត្រួតពិនិត្យផ្ទៃក្នុង

គន្លឹះដំណើរការដែលបានបង្កើតឡើងដើម្បីត្រួតពិនិត្យភាពត្រឹមត្រូវ និងសុចរិតភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ត្រូវបានរៀបរា ប់បង្ហាញដូចខាងក្រោម៖

## រចនាសម្ព័ន្ធអង្គភាពចាត់តាំង

រចនាសម្ព័ន្ធអង្គភាពចាត់តាំង ជាមួយនឹងគំនូសបង្ហាញបន្ទាត់នៃការទទួលខុសត្រូវ ការរាយការណ៍ ការផ្ទេរអំណាច និងគណនេយ្យភាពក្នុងធនាគារនឹងជួយធានាប្រសិទ្ធភាពទំនាក់ទំនង នៃគោលដៅត្រួតពិនិត្យហានិភ័យក៏ដូចជាការរៀបចំបង្កើតអំណាច និងគណនេយ្យភាពដែលសមស្របទៅតាមលក្ខណវិនិច្ឆ័យនៃការគ្រប់គ្រង។

## គោលនយោបាយ និងនីតិវិធីផ្ទៃក្នុង

សៀវភៅណែនាំស្តីពីនីតិវិធី និងគោលការណ៍ផ្ទៃក្នុងលម្អិតពីអាជីវកម្ម និងផ្នែកគាំទ្រមួយចំនួនត្រូវបានបង្កើតឡើងសម្រាប់ផ្តល់ការណែនាំ ដើម្បីធានាការអនុលោមទៅតាមគោលការណ៍ត្រួតពិនិត្យផ្ទៃក្នុង ក៏ដូចជាច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។ ធនាគារ ក៏បានចងក្រងឯកសារអំពីដែនកំណត់នៃសិទ្ធិអំណាចដែលបានផ្តល់ឲ្យសម្រាប់ទិសដៅគន្លឹះនៃអាជីវកម្ម ដោយបានទទួលការយល់ស្របពីក្រុមប្រឹក្សាភិបាល។ ឯកសារនេះបញ្ជាក់ពីក្របខណ្ឌអំណាច និងទំនួលខុសត្រូវ ព្រមទាំងសម្រួលដល់ការធ្វើការសម្រេចចិត្ត ឲ្យបានត្រឹមត្រូវក្នុងកម្រិតមួយដែលសាកសមទៅតាមឋានានុក្រមរបស់អង្គភាព។ ការផ្តល់ព្រំដែនកំណត់នេះ ធ្វើឡើងផ្អែកទៅលើការត្រួតពិនិត្យជាទៀងទាត់ទៅតាមការអនុវត្តន៍ និងភាពសមស្របរបស់វាដើម្បីសម្រេចទិសដៅ និងតម្រូវការប្រតិបត្តិការនៃអាជីវកម្មរបស់ធនាគារ។

## ការត្រួតពិនិត្យលើលទ្ធផលហិរញ្ញវត្ថុ

ស្ថិតក្នុងមូលដ្ឋានទៀងទាត់ គណៈគ្រប់គ្រងផ្តល់ព័ត៌មានលម្អិតពីហិរញ្ញវត្ថុបម្រែបម្រួលសំខាន់ៗនិងការវិភាគទិន្នន័យហិរញ្ញវត្ថុជូនក្រុមប្រឹក្សាភិបាលក្នុងគោលបំណងពិនិត្យមើល និងធ្វើការសម្រេចចិត្ត។

## មុខងារប្រតិបត្តិតាម

ការប្រតិបត្តិតាមធ្វើឡើងតាមការវាយតម្លៃជាទៀងទាត់ ចំពោះដំណើរការប្រតិបត្តិនានារបស់ធនាគារ ដើម្បីធានាឲ្យមានអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិ ជាពិសេសបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ក៏ដូចជាគោលការណ៍ និងនីតិវិធីផ្សេងៗដែលតម្រូវ។ រាល់ការប្រែប្រួល ឬភាពខុសឆ្គងណាមួយ គឺត្រូវរាយការណ៍ជូនទៅគណៈកម្មការធិការគ្រប់គ្រងហានិភ័យ ហើយក្រុមប្រឹក្សាភិបាលនឹងត្រូវបានផ្តល់ព័ត៌មាននូវមូលហេតុបង្ក និងវិធានការបង្ការដែលត្រូវបានអនុវត្ត។

## មុខងារសវនកម្មផ្ទៃក្នុង

សវនកម្មផ្ទៃក្នុងពិនិត្យនឹងធ្វើការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ ដើម្បីអនុលោមតាមតម្រូវការត្រួតពិនិត្យទាមទារដោយធនាគារ។ សវនកររបស់ធនាគារ ធ្វើការត្រួតពិនិត្យ និងប្រតិបត្តិការត្រួតពិនិត្យខាងក្នុងរបស់ធនាគារយ៉ាងទៀតទាត់។ គណៈកម្មការសវនកម្មរាយការណ៍អំពីសវនកម្មផ្ទៃក្នុងជូនទៅក្រុមប្រឹក្សាភិបាល។

# គោលនយោបាយ និងគោលការណ៍អនុវត្តន៍សម្រាប់អភិបាលកិច្ចក្រុមហ៊ុន

អំឡុងឆ្នាំ2023 កិច្ចការរបស់សវនកម្មផ្ទៃក្នុងផ្តោតសំខាន់ លើចំណុចអាទិភាព ដោយយោងទៅលើការវាយតម្លៃហានិភ័យប្រចាំឆ្នាំ និងយោងតាមផែនការសវនកម្មប្រចាំឆ្នាំដែលបានអនុម័ត ដោយគណៈកម្មការសវនកម្មរបស់ធនាគារ។ លទ្ធផលត្រួតពិនិត្យរួមគ្នា ជាមួយអនុសាសន៍សម្រាប់អភិវឌ្ឍកែលម្អ ត្រូវបានរាយការណ៍ជូនគណៈកម្មការសវនកម្មរបស់ធនាគារ។ គណៈកម្មការសវនកម្មរបស់ធនាគារកោះប្រជុំទៀតទាត់ដើម្បីពិនិត្យលទ្ធផលរកឃើញដោយសវនកម្មផ្ទៃក្នុង និងអនុសាសន៍សម្រាប់អភិវឌ្ឍកែលម្អ មើលលើវិធានការដែលបានធ្វើឡើងដើម្បីកែតម្រូវការរកឃើញអោយទាន់ពេលវេលា ដើម្បីវាយតម្លៃប្រសិទ្ធភាព និងភាពគ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ក្រុមប្រឹក្សាភិបាលអះអាងថាដំណើរការនេះ នៅតែបន្តធ្វើជាប់ជានិច្ចក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ដើម្បីកំណត់វាយតម្លៃនិងគ្រប់គ្រងហានិភ័យ ហើយផ្តល់ការធានាមួយដ៏សមស្រប ដែលទ្រព្យសកម្មរបស់ធនាគារត្រូវបានមើលការខុសត្រូវដោយសុវត្ថិភាព មិនឲ្យមានការបាត់បង់ពីការប្រើប្រាស់ដោយគ្មានការអនុញ្ញាតណាមួយឡើយ និងម្យ៉ាងវិញទៀតរាល់ប្រតិបត្តិការនីមួយៗរបស់ធនាគារ គឺត្រូវបានកត់ត្រាទុក និងទទួលបានការអនុញ្ញាតយ៉ាងត្រឹមត្រូវ។

## ការគ្រប់គ្រងហានិភ័យ

ធនាគារនៅតែបន្តយន្តការពង្រឹងការអនុវត្តន៍ការគ្រប់គ្រងហានិភ័យដោយតែងតាំងនាយកនាយកដ្ឋានហានិភ័យ ជាអ្នកតាមដាន និងត្រួតពិនិត្យលើការគ្រប់គ្រងក្របខណ្ឌហានិភ័យដែលមានវិសាលភាពដូចខាងក្រោម៖

### ■ ហានិភ័យផ្នែកយុទ្ធសាស្រ្ត

ហានិភ័យផ្នែកយុទ្ធសាស្រ្ត ដែលកើតឡើងមកពីការអនុវត្តន៍មិនបានពេញលេញទៅលើ ផែនការយុទ្ធសាស្រ្តអាជីវកម្ម ការសម្រេចចិត្ត ការបែងចែកធនធានឲ្យបានសមស្របទៅតាម បរិយាកាសអាជីវកម្ម។

### ■ ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាហានិភ័យនៃ ការរងគ្រោះដោយការខាតបង់ផ្នែកហិរញ្ញវត្ថុ របស់អតិថិជនធនាគារមួយចំនួនដែលអតិថិជន ឬភាគីទីផ្សារម្ខាងទៀតមិនអាចបំពេញកាតព្វកិច្ចទៅតាមកិច្ចសន្យារបស់ពួកគេចំពោះធនាគារ។ ហានិភ័យឥណទានជាហានិភ័យធំជាងគេតែមួយគត់សម្រាប់អាជីវកម្មធនាគារ។

### ■ ហានិភ័យហិរញ្ញវត្ថុ

សកម្មភាពចំណាយរបស់ធនាគារ ដែលអាចនឹងងាយបណ្តាលនាំឲ្យធនាគារប្រឈមនឹងហានិភ័យហិរញ្ញវត្ថុជាច្រើន រួមមានហានិភ័យសន្ទនីយភាព ហានិភ័យរូបិយប័ណ្ណបរទេស និងហានិភ័យអត្រាការប្រាក់។

- ហានិភ័យសន្ទនីយភាព ជាហានិភ័យដែលធនាគារមិនអាចបំពេញកាតព្វកិច្ចពួកគេ បានដែលបណ្តាលមកពីប្រាក់បញ្ញើរបស់អតិថិជនត្រូវបានដកចេញតម្រូវការសាច់ប្រាក់ពីប្រាក់ ដែលនៅជំពាក់តាមកិច្ចសន្យា ឬលំហូរសាច់ប្រាក់ចេញផ្សេងទៀត។
- ហានិភ័យរូបិយប័ណ្ណបរទេស ជាផលប៉ះពាល់ដ៏ធំទាក់ទងនឹងការប្រែប្រួលអត្រារូបិយប័ណ្ណជាអវិជ្ជមានលើប្រាក់ចំណូល និងតម្លៃសេដ្ឋកិច្ច។
- ហានិភ័យអត្រាការប្រាក់ គឺជាហានិភ័យដែលលំហូរសាច់ប្រាក់នាពេលខាងមុខនៃ ឧបករណ៍ហិរញ្ញវត្ថុកើតឡើងដោយសារការប្រែប្រួលអត្រាការប្រាក់នៅលើទីផ្សារ។ កម្រិតការប្រាក់កើនឡើង ឬថយចុះដោយសារការប្រែប្រួលមិនរំពឹងទុកក្នុងអត្រាការប្រាក់។

### ■ ហានិភ័យផ្នែកប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការជាហានិភ័យ ដែលខាតបង់បណ្តាលមកពីកង្វះខាត ឬបរាជ័យនៃ ដំណើរការត្រួតពិនិត្យផ្ទៃក្នុង មនុស្ស ប្រព័ន្ធ និងមកពីកត្តាខាងក្រៅនានា។ ទាំងនេះរួមមាន៖ ហានិភ័យខាងផ្នែកបច្ចេកវិទ្យា និងហានិភ័យខាងកេរ្តិ៍ឈ្មោះ។

### ■ ហានិភ័យផ្នែកប្រតិបត្តិតាម

ហានិភ័យផ្នែកប្រតិបត្តិតាម គឺជាហានិភ័យទាក់ទងនឹងផ្នែកច្បាប់ ឬបទប្បញ្ញត្តិហាមឃាត់ ការខាតបង់ផ្នែកហិរញ្ញវត្ថុ ឬការបាត់បង់កិត្តិសព្ទ ដែលស្ថាប័នអាចនឹងទទួលរងពីលទ្ធផលនៃការអាក់ខានមិនបានអនុវត្តតាមច្បាប់បទប្បញ្ញត្តិ បទដ្ឋានគតិយុត្តិ បទប្បញ្ញត្តិផ្ទៃក្នុង និងក្រមសីលធម៌ដែលអនុវត្តលើសកម្មភាពធនាគារ។

ធនាគារនៅតែបន្តយកចិត្តទុកដាក់ពង្រឹងចំណេះដឹងផ្នែកហានិភ័យដល់និយោជិកគ្រប់ជាន់ថ្នាក់នៅក្នុងធនាគារ។ កម្មវិធីបណ្តុះបណ្តាលនៅតែបន្តធ្វើឡើងដោយផ្នែកហានិភ័យ ដើម្បីអប់រំនិយោជិត អំពីការសម្គាល់

# គោលនយោបាយ និងគោលការណ៍អនុវត្តន៍សម្រាប់អភិបាលកិច្ចក្រុមហ៊ុន

ហានិភ័យ ការវាយតម្លៃ និង វាស់វែងហានិភ័យ ព្រមទាំងបង្កើតវិធីសាស្រ្ដដើម្បីការគ្រប់គ្រងហានិភ័យ និងរក្សាការប្រតិបត្តិតាមគោលនយោបាយ និងបទប្បញ្ញត្តិ ទាំងក្នុង និងក្រៅ។ ធនាគារបានបន្ដអនុវត្ដដំណើរការវាយតម្លៃគ្រប់គ្រងហានិភ័យ (CSA) ដែលផ្នែកទាំងអស់នឹងបន្ដធ្វើការសម្គាល់ វាយតម្លៃ និងកាត់បន្ថយហានិភ័យផ្នែកប្រតិបត្ដិការ។ គណៈកម្មការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម (ALCO) ពង្រឹងការត្រួតពិនិត្យផ្នែកអនុវត្ដហិរញ្ញវត្ថុរបស់ធនាគារគោលកំណត់ហានិភ័យត្រឡប់ និងដំណើរការគ្រប់គ្រងសន្ទនីយភាព និងទុនវិនិយោគ។ គណៈកម្មការគ្រប់គ្រងហានិភ័យរបស់ក្រុមប្រឹក្សាភិបាលផ្ដល់ការណែនាំលើបញ្ហានានាដែលពាក់ព័ន្ធ ដើម្បីធានានូវការទទួលយកហានិភ័យរបស់ធនាគារមានភាពសមស្រប ក្នុងការជួយសម្រេចគោលដៅហិរញ្ញវត្ថុរបស់ធនាគារ។

ធនាគារបាននឹងកំពុងតែបន្ដការគ្រប់គ្រងក្របខណ្ឌហានិភ័យ ដោយជឿជាក់ថា ការគ្រប់គ្រងក្របខណ្ឌហានិភ័យ នឹងជួយធានាបន្ដនិរន្ដភាពអាជីវកម្ម របស់ខ្លួនដើម្បីសម្រេចបាន តាមទីផ្សារគោលដៅរបស់ខ្លួន។

## ក្រមសីលធម៌

ក្រមសីលធម៌របស់ធនាគារត្រូវបានដាក់ជាគោលការណ៍ណែនាំ ចំពោះឥរិយាបថរបស់និយោជិតដែលអាចទទួលយកបានជាពិសេស នៅពេលពួកគេដោះស្រាយបញ្ហារសើប ដូចជាវិនិយោគទំនាក់ទំនងគ្នាជាមួយអ្នកដទៃ និងដោះស្រាយបណ្ដឹងសារទុក្ខទាំងក្នុង និងក្រៅអង្គភាព។ ក្រមសីលធម៌បានចែងអំពីបទដ្ឋាន នៃឥរិយាបថជាក់លាក់សម្រាប់និយោជិត របស់យើងដើម្បីដោះស្រាយបញ្ហាសីលធម៌ចម្បងនានាដូចជាការរក្សាការសម្ងាត់ និងការប្រើប្រាស់ព័ត៌មានក្នុងកាលៈទេសៈមិនសមរម្យ។

ការមានក្រមសីលធម៌ជួយបង្កើនទំនុកចិត្តនៅក្នុងធនាគារ ក្នុងនាមជាគ្រឹះស្ថានមួយដោយបង្ហាញដល់អតិថិជន និងអ្នកវិនិយោគថាធនាគារមានការតាំងចិត្តក្នុងការថែរក្សាភាពសុចរិតរបស់ខ្លួន ដោយគោរពតាមគោលការណ៍ណែនាំ អំពីសីលធម៌កម្រិតខ្ពស់ និងអនុវត្តសកម្មភាពអាជីវកម្មរបស់ខ្លួនប្រកបដោយទំនួលខុសត្រូវ ។

និយោជិតថ្មីទាំងអស់ត្រូវបានផ្ដល់នូវព័ត៌មាន និងតម្រូវឲ្យធ្វើការចុះហត្ថលេខាទទួលយល់ព្រមលើក្រមសីលធម៌ ជាការដឹកនាំលើឥរិយាបទរបស់ពួកគេក្នុងពេលចាប់ផ្ដើមធ្វើការ។

## ឯករាជ្យភាព និងតម្លាភាព

ធនាគារ ត្រូវបានគ្រប់គ្រងយ៉ាងឯករាជ្យ ដោយក្រុមអ្នកគ្រប់គ្រងមានបទពិសោធន៍ជាមួយនឹងការត្រួតពិនិត្យតាមដានក្រុមប្រឹក្សាភិបាល។

ធនាគារ ប្រកាន់ភ្ជាប់នូវតម្លាភាពក្នុងការទំនាក់ទំនង ជាមួយអតិថិជន ក៏ដូចជាប្រកាន់ភ្ជាប់នូវតម្លាភាពក្នុងរបាយការណ៍ និងទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុ។

# ធនាគារ ហ្វីលីព ក្នុងព័ត៌មាន




PhillipBank
KHMERLOAD
Telegram

# អភិបាលកិច្ចធនាគារ


- ប្រវត្តិរូបក្រុមប្រឹក្សាភិបាល ........ 34
- ប្រវត្តិរូបគណៈគ្រប់គ្រង ........ 38
- រចនាសម្ព័ន្ធរបស់ធនាគារ ហ្វីលីព ........ 45

# ប្រវត្តិរូបក្រុមប្រឹក្សាភិបាល



## លោក LIM HUA MIN

ប្រធានក្រុមប្រឹក្សាភិបាល

លោក Lim ជាប្រធានក្រុមប្រឹក្សាភិបាលនៃ Phillip Capital Group of Companies និងត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលនៃ IFS Capital Limited ផងដែរនាថ្ងៃទី20 ខែឧសភា ឆ្នាំ2003។ គាត់បានចាប់ផ្តើមអាជីពរបស់គាត់ ដោយកាន់មុខតំណែងជាន់ខ្ពស់នៅក្នុងផ្សារភាគហ៊ុននៃប្រទេសសិង្ហបុរី (SES) និងវិទ្យាស្ថានស្រាវជ្រាវមូលប័ត្រ។ គាត់បានបម្រើការងារនៅក្នុងគណៈកម្មការ និងអនុគណៈកម្មការមួយចំនួន នៃផ្សារភាគហ៊ុន នៃប្រទេសសិង្ហបុរី។ ក្នុងឆ្នាំ1997 គាត់ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលនៃគណៈកម្មការត្រួតពិនិត្យផ្សារភាគហ៊ុននៃប្រទេសសិង្ហបុរី (SES) ដែលទទួលខុសត្រូវលើការបង្កើតក្របខណ្ឌទស្សនាទាន ដើម្បីធ្វើឲ្យទីផ្សារមូលធននៃប្រទេសសិង្ហបុរីកាន់តែមានលក្ខណៈសកល ប្រកួតប្រជែង និងរឹងមាំ។ សម្រាប់ការងារ នេះ គាត់បានទទួលមេដាយសេវាសាធារណៈ (PBM) ក្នុងឆ្នាំ 1999 ពីរដ្ឋាភិបាលសិង្ហបុរី។ នៅឆ្នាំ2014 គាត់ទទួលបានវិញ្ញាបនបត្រសរសើរពី IBF Distinguished Fellow ដែលជាវិញ្ញាបនបត្រខ្ពស់បំផុតដែលផ្តល់ដោយវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ (IBF) សម្រាប់អ្នកដឹកនាំជំនួញដែលផ្តល់ជាគំរូល្អផ្នែកវិជ្ជាជីវៈ ភាពស្មោះត្រង់ និងសមិទ្ធិផល។ នៅឆ្នាំ2018 គាត់បានទទួលងារជាអ្នកជំនួញប្រចាំឆ្នាំ2017 ក្នុងកម្មវិធីពានរង្វាន់ធុរកិច្ចសិង្ហបុរីប្រចាំឆ្នាំ ដែលជាកិត្តិនាមដ៏ល្បីល្បាញបំផុតនៅក្នុងប្រទេសសិង្ហបុរី។ លោក Lim ក៏ធ្លាប់បម្រើការជាសមាជិកក្រុមប្រឹក្សាភិបាលមួយរូបនៅក្នុងអាជ្ញាធរប្រចាំចំណូលនៃប្រទេសសិង្ហបុរីពីឆ្នាំ2004 ដល់ឆ្នាំ2010។

លោក Lim មានបរិញ្ញាបត្រវិទ្យាសាស្ត្រ (កិត្តិយស) ផ្នែកវិស្វកម្មគីមីពីសាកលវិទ្យាល័យ The University of Surrey និងទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកស្រាវជ្រាវប្រតិបត្តិការ និងសិក្សាការគ្រប់គ្រង ពីសាកលវិទ្យាល័យ Imperial College London។



## លោក PAUL GWEE CHOON GUAN

អភិបាលឯករាជ្យ

អាជីពធនាគាររបស់លោក Gwee មានរយៈពេលជាង 25ឆ្នាំ ពោរពេញដោយបទពិសោធន៍ផ្នែកធនាគារសកល និងរតនាគារ/វិនិយោគ ជាមួយនឹងឧស្សាហកម្ម គ្រប់គ្រង ទ្រព្យសកម្ម/មូលនិធិ និងទ្រព្យធន នៅទូទាំងអាស៊ីប៉ាស៊ីហ្វិក។ ជំនាញឯកទេសរបស់គាត់ រួមមាន វិស័យគ្រប់គ្រងហានិភ័យសហគ្រាស (ឥណទាន ទីផ្សារ សន្ទនីយភាព និងប្រតិបត្តិការ) ការត្រួតពិនិត្យ និងប្រតិបត្តិ និងប្រតិបត្តិការសម្ងាត់ ជាមួយនឹងការរួម បញ្ចូលគ្នាដ៏រឹងមាំនៃរបាយការណ៍ហិរញ្ញវត្ថុ និងគណនេយ្យអាជីវកម្មជាយុទ្ធសាស្ត្រ ការច្របាច់បញ្ចូលគ្នានិងការធ្វើលទ្ធកម្មនិងការគ្រប់គ្រងមូលធន។គាត់ធ្លាប់ធ្វើជាប្រធានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិ នៅក្នុងក្រុមហ៊ុន United Overseas Bank Group បន្ទាប់មកជាប្រធាននាយកហិរញ្ញវត្ថុប្រចាំប្រទេសនៅ Hong Kong និង Shanghai Bank ប្រចាំប្រទេសឥណ្ឌូនេស៊ី និងជាប្រធាននាយកប្រតិបត្តិនៅ Bank of East Asia ប្រចាំប្រទេសសិង្ហបុរី។ បច្ចុប្បន្ន គាត់គឺជាអគ្គលេខាធិការនៃសមាគមធនាគារិកអាស៊ាន (ASEAN Bankers Association)។ លោក Gwee មានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្មពីសាកលវិទ្យាល័យឈីកាហ្គោ បានបញ្ចប់ការសិក្សាពីសាលាពាណិជ្ជកម្មជំនាញផ្នែកហិរញ្ញវត្ថុ និងទទួលបានបរិញ្ញាបត្រពាណិជ្ជកម្មពីសាកលវិទ្យាល័យញូវខាសល។

គាត់ត្រូវបានទទួលស្គាល់ជាគណនេយ្យករជំនាញក្នុងឆ្នាំ1984 និងជាសមាជិកនៃវិទ្យាស្ថានគណនេយ្យករ ជំនាញ នៅក្នុងប្រទេសអូស្ត្រាលី និងវិទ្យាស្ថានគណនេយ្យករជំនាញសិង្ហបុរី។

# ប្រវត្តិរូបក្រុមប្រឹក្សាភិបាល



## លោក KOH YONG GUAN

**អភិបាលឯករាជ្យ**

លោក Koh បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រ ផ្នែកវិស្វករមេកានិចក្នុងឆ្នាំ1970 និងថ្នាក់អនុបណ្ឌិតវិទ្យាសាស្ត្រ ផ្នែកវិស្វករមេកានិច និងវិស្វករឱសថក្នុងឆ្នាំ1972 ពីសាកលវិទ្យាល័យតូរ៉ុនតូ (Toronto) ដែលលោកទទួលអាហារូបករណ៍ពីគម្រោងកូឡុមបូ (Colombo)។ លោកបានទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែករដ្ឋបាលពាណិជ្ជកម្ម ពីសកលវិទ្យាល័យកាតូលិកលីវិន (Catholic University of Leuven) ប្រទេសបេលហ្សិកក្នុងឆ្នាំ1981។ លោកត្រូវបានទទួលស្គាល់ថា ជាបណ្ឌិតពីសាកលវិទ្យាល័យតូរ៉ុនតូ ក្នុងឆ្នាំ2011។

លោក Koh បានចូលរួមជាមួយផ្នែកស៊ីវិលប្រទេសសិង្ហបុរី ក្នុងតួនាទីជាវិស្វករជីវឱសថ នៃក្រសួងសុខាភិបាលក្នុងឆ្នាំ1972 បន្ទាប់មកបានបន្តជាមួយផ្នែករដ្ឋបាលក្នុងឆ្នាំ1979។ លោកបានបន្តការងារក្នុងក្រសួងហិរញ្ញវត្ថុ (នាយកដ្ឋានប្រមូលពន្ធ) ក្រសួងអប់រំ និងក្រសួងការពារជាតិ មុននឹងត្រូវបានតែងតាំងជារដ្ឋលេខាធិការអចិន្ត្រៃយ៍ នៃក្រសួងការពារជាតិក្នុងឆ្នាំ1989។

លោកបានធ្វើជាប្រមុខផ្នែកប្រមូលពន្ធពីឆ្នាំ1991 ដល់ឆ្នាំ1997។ ក្នុងឆ្នាំ1998 លោកត្រូវបានតែងតាំង ជាអគ្គនាយកនៃ អាជ្ញាធររូបិយវត្ថុសិង្ហបុរី (ទេសាភិបាលធនាគារជាតិ)។ លោកក៏បានកាន់តួនាទីជារដ្ឋលេខាធិការអចិន្ត្រៃយ៍នៃក្រសួងហិរញ្ញវត្ថុ (ថវិកា និងប្រមូលពន្ធ) ផងដែរពីឆ្នាំ1998 ដល់ឆ្នាំ2001។ លោកបានចូលនិវត្តន៍ ក្នុងខែមិថុនា ឆ្នាំ2005 ក្នុងតួនាទីជាអគ្គនាយកអាជ្ញាធររូបិយវត្ថុសិង្ហបុរី។ បន្ទាប់ពីចូលនិវត្តន៍ លោកនៅតែបន្តមុខតំណែងជាសមាជិកក្រុមប្រឹក្សាភិបាល នៃស្ថាប័ននេះរហូតដល់ខែមេសា ឆ្នាំ2011។ លោកបានបម្រើការងារជា ប្រធានក្រុមប្រឹក្សាភិបាលមូលនិធិសោធននិវត្តន៍ទទួលបន្ទុកនិយោជិតទាំងអស់ រួមទាំងវិស័យឯកជន និងសាធារណៈ ក្នុងប្រទេសសិង្ហបុរីពីឆ្នាំ2005 រហូតដល់ឆ្នាំ2013។ លោកបានធ្វើជាប្រមុខជាន់ខ្ពស់អនិវាសនជនសិង្ហបុរីប្រចាំនៅប្រទេសកាណាដាពីខែឧសភា ឆ្នាំ2008 ដល់ ខែមីនា ឆ្នាំ2013 ហើយលោកបានធ្វើជាឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅប្រទេសក្រិចពីខែឧសភា ឆ្នាំ2013 ដល់ខែឧសភា ឆ្នាំ2020។

លោកក៏បានបម្រើការងារជាប្រធានក្រុមប្រឹក្សាភិបាលនៃសាជីវកម្ម SMRT ដែលផ្តល់សេវារថភ្លើងក្រោមដី រថយន្តក្រុងនិងតាក់ស៊ី ក្នុងប្រទេសសិង្ហបុរី និងជាប្រធានវិទ្យាស្ថានវិទ្យាសាស្ត្រជំងឺមហារីក នៅសិង្ហបុរីផងដែរ។

បច្ចុប្បន្ននេះ លោកជាប្រធានសាជីវកម្មធានារ៉ាប់រងលើប្រាក់បញ្ញើប្រចាំនៅប្រទេសសិង្ហបុរី។

# ប្រវត្តិរូបក្រុមប្រឹក្សាភិបាល



## លោកស្រី SEAH YEN GOON

**អភិបាលឯករាជ្យ**

លោកស្រី Seah មានបទពិសោធន៍ការងារជាង30ឆ្នាំ នៅក្នុងស្ថាប័នហិរញ្ញវត្ថុ រួមទាំង ហិរញ្ញវត្ថុពាណិជ្ជកម្ម GE ដែលជំនាញខាងផ្តល់ហិរញ្ញវត្ថុដល់សហគ្រាសខ្នាតតូច និង មធ្យម។ គាត់កាន់មុខតំណែងជាន់ខ្ពស់នៅក្នុងផ្នែកហិរញ្ញវត្ថុ ប្រតិបត្តិការ បច្ចេកវិទ្យាព័ត៌មាន ប្រតិបត្តិការត្រួតពិនិត្យ នៅក្នុងប្រទេសសិង្ហបុរី ថៃ និងហុងកុង។ គាត់គឺជាប្រធាននាយកហិរញ្ញវត្ថុទទួលបន្ទុកហិរញ្ញវត្ថុ និងការត្រួតពិនិត្យ ការធ្វើផែនការយុទ្ធសាស្ត្រ និងហិរញ្ញវត្ថុ ការផ្តល់មូលនិធិ និងប្រតិបត្តិ។

គាត់រៀបចំសិក្ខាសាលាបណ្តុះបណ្តាលនៅស្ថាប័នជាច្រើន និងបម្រើការងារនៅក្នុង អនុគណៈកម្មការធនធានមនុស្សនៃមន្ទីរពេទ្យ St. Luke និងផ្ទះគ្រីស្ទាន សិង្ហបុរី (Singapore Christian Home)។

លោកស្រី Seah គឺជាគណនេយ្យករជំនាញ (សិង្ហបុរី) ដែលមានបរិញ្ញាបត្រគណនេយ្យពីសាកលវិទ្យាល័យសិង្ហបុរីបច្ចុប្បន្នហៅថាសាកលវិទ្យាល័យជាតិសិង្ហបុរី និងមានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម (ច្បាប់អាជីវកម្ម) ពីសាកលវិទ្យាល័យបច្ចេកវិទ្យាណានយ៉ាង (Nanyang Technological University)។



## លោក ONG TEONG HOON

**អភិបាល**

លោក Ong បានចាប់ផ្តើមធ្វើការនៅក្នុងវិស័យហិរញ្ញវត្ថុក្នុងឆ្នាំ1977 ដំបូងជាភ្នាក់ងារជើងសាររូបិយប័ណ្ណរួចមួយឆ្នាំក្រោយមកបានបម្រើការងារជាមួយធនាគារ Standard Chartered Bank ក្នុងតំណែងជាកម្មសិក្សាការី។ ដោយធ្វើការជាមួយធនាគារនេះអស់រយៈពេល 25ឆ្នាំ គាត់បានឆ្លងកាត់គ្រប់ទិដ្ឋភាពទាំងអស់នៃធនាគារពាណិជ្ជក្រៅពីមុខងារជាហេរញ្ញិក ហើយគាត់បានបញ្ចប់អាជីពធនាគាររបស់គាត់ក្នុងតំណែងជានាយកប្រចាំប្រទេសឲ្យធនាគារក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ2002។ ការបញ្ចប់នេះ គឺក្រោយពីលោកធ្វើជានាយកប្រចាំប្រទេសរបស់ធនាគារនៅក្នុងប្រទេសមីយ៉ាន់ម៉ា ហើយមុននោះ ជាអ្នកគ្រប់គ្រងប្រចាំតំបន់នៃតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលគ្របដណ្តប់លើស្ថាប័នហិរញ្ញវត្ថុនានា។

បន្ទាប់ពីពេលនោះ គាត់បានចូលរួមជាមួយ Phillip Securities Pte Ltd និងបានកាន់មុខងារជាច្រើន រួមទាំងការងាររយៈពេលមួយឆ្នាំនៅក្នុង Phillip Securities Thailand PLC ក្នុងតំណែងជានាយកប្រតិបត្តិស្តីទីរបស់ក្រុមហ៊ុន ហើយចុងក្រោយជាអភិបាល នៃ OTC Capital មុនពេលត្រូវបានតែងតាំងឲ្យចូលបម្រើការងារនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រេឌីត ភីអិលស៊ី ក្នុងឆ្នាំ2012។ សព្វថ្ងៃនេះ គាត់កំពុងបម្រើការជា ប្រធានក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុន Phillip General Insurance (Cambodia) Plc ព្រមទាំងជាអ្នកតំណាងភាគទុនិករបស់ក្រុមហ៊ុន Phillip General Insurance (Cambodia) Plc ក្រុមហ៊ុន Phillip Life Assurance (Cambodia) Plc និងធនាគារ ហ្វីលីព។ សព្វថ្ងៃនេះ លោក Ong ក៏ជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន Phillip Trustee (Cambodia) Co., Ltd. ផងដែរ។

លោក Ong បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យសិង្ហបុរី ដោយទទួលបានបរិញ្ញាបត្រផ្នែកគ្រប់គ្រងអាជីវកម្ម និងបរិញ្ញាបត្ររងពីវិទ្យាស្ថាន Associate of the Chartered Institute of Bankers ចាប់តាំងពីឆ្នាំ1978។

# ប្រវត្តិរូបក្រុមប្រឹក្សាភិបាល



**លោក ប៉ែន ចិន្តា**

**អភិបាលឯករាជ្យ**

លោក ប៉ែន ចិន្តា ជាអ្នកដែលស្រលាញ់ចូលចិត្តបច្ចេកវិទ្យា ការទូទាត់តាមអេឡិចត្រូនិក និងប្រព័ន្ធអេកូឡូស៊ីនៃការចាប់ផ្តើមពាណិជកម្មផ្សេងៗ។ គាត់បានចំណាយពេល 20ឆ្នាំនៃអាជីពបង្កើតផលិតផល និងរចនាប្រព័ន្ធផ្សេងៗ។ លោកជាប្រធានគ្រប់គ្រងជាន់ខ្ពស់ផ្នែកគំនិតផ្តួចផ្តើមអភិវឌ្ឍន៍កម្លាំងពលកម្មឌីជីថលរបស់អង្គការ USAID ដែលមានភារកិច្ចកែលម្អការអប់រំផ្នែកបច្ចេកទេសសម្រាប់អ្នកជំនាញការងារ និងនិស្សិតសាកលវិទ្យាល័យក្នុងប្រទេសកម្ពុជា ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមដែលកើតឡើងដោយសេដ្ឋកិច្ចពិភពលោក ដែលពឹងផ្អែកលើបច្ចេកវិទ្យាខ្ពស់។

មុនពេលបម្រើការជាប្រធានគ្រប់គ្រងជាន់ខ្ពស់ លោក Chanda គឺជាសហស្ថាបនិក/នាយកប្រតិបត្តិ នៃ Bongloy ជាក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុដែលមានមូលដ្ឋាននៅអាស៊ីអាគ្នេយ៍ ផ្តោតលើ API សម្រាប់ការចេញកាត និងហេដ្ឋារចនាសម្ព័ន្ធទូទាត់ឌីជីថល។ គាត់បានចាកចេញពីមុខដំណែងកាលពីខែមិថុនា ឆ្នាំ2021។ គាត់បានបម្រើការជាសមាជិកក្រុមប្រឹក្សានៃសមាគមធនាគារកម្ពុជា (ABC) ជាប្រធានគណៈកម្មាធិការជាតិនៃក្រុមការងារ QR Code និងជាក្រុមប្រឹក្សាភិបាលនៃសមាគមហិរញ្ញវត្ថុនិងបច្ចេកវិទ្យាកម្ពុជា (CAFT)។ គាត់ក៏បានបម្រើការជាសាស្ត្រាចារ្យផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង (NUM) ផងដែរ។

លោក ចិន្តា បានទទួលបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រពីសាកលវិទ្យាល័យ Barry និងអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រផ្នែកគ្រប់គ្រងបច្ចេកវិទ្យាពីសាកលវិទ្យាល័យ Columbia ក្នុងទីក្រុងញូវយ៉ក។

# ប្រវត្តិរូបគណៈគ្រប់គ្រង



## លោក ចាន់ ម៉ាច

**អភិបាល និងអគ្គនាយក**



## លោក LEE YONG MAN (MARK)

**សមាជិកគណៈគ្រប់គ្រងជាន់ខ្ពស់**

លោក ម៉ាច មានបទពិសោធន៍ជាង 25ឆ្នាំមកហើយ ក្នុងវិស័យហិរញ្ញវត្ថុ។ លោកជាអគ្គនាយក ក៏ដូចជាអភិបាលប្រឹក្សានៃ ធនាគារ ហ្វីលីព ភីអិលស៊ី នាពេលបច្ចុប្បន្នផងដែរ។ លោកបានទទួលមុខតំណែងជាអគ្គនាយក ចាប់តាំងពីការរួមបញ្ចូលគ្នារវាងធនាគារ ហ្វីលីព និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌីត ក្នុងឆ្នាំ2020។ មុនការរួមបញ្ចូលគ្នា លោកមានមុខតំណែង ជាអគ្គនាយក នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌីតនៅឆ្នាំ2006។ បន្ថែមពីនេះ លោកក៏បានបម្រើការជាអភិបាលប្រឹក្សានៃក្រុមហ៊ុនធានារ៉ាប់រងហ្វីលីព និងក្រុមហ៊ុន ហ្វីលីព ត្រាស់ធី ក៏ដូចជា អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយមានឈ្មោះ គាំពារភូមិយើង (KPY)។

នៅក្នុងដំណើរនៃអាជីពការងាររបស់លោក លោក ម៉ាច បានដឹកនាំឲ្យមានការផ្លាស់ប្តូរគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌីត ពីគម្រោងផ្តល់ប្រាក់កម្ចីពីអង្គការក្រៅរដ្ឋាភិបាលទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ (MFI) រហូតក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្នែកប្រាក់បញ្ញើសន្សំ (MDI)។ លោកជាបុគ្គលដ៏សំខាន់ក្នុងការដឹកនាំដំណើរការនៃការរួមបញ្ចូលគ្នាជាមួយធនាគារ ហ្វីលីព ក្នុងនាមជាសមាជិកនៃគណៈកម្មាធិការដឹកនាំមួយរូប។ លោក ម៉ាច ក៏បានទទួលរង្វាន់ជាធនាគារិកដែលមានសមត្ថភាពខ្ពស់ ពីវិទ្យាស្ថាន Chartered Banker (ចក្រភពអង់គ្លេស)។ លោក ម៉ាច បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន2៖ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម (MBA) និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ និងធនាគារ (MFB)។

លោកក៏បានបញ្ចប់វគ្គសិក្សាកម្រិតខ្ពស់ និងវិញ្ញាបនប័ត្រផ្នែកក្រមសីលធម៌ធុរកិច្ច (សិង្ហបុរី) កម្ចីពាណិជ្ជខាងជំនួញពី Omega Performance (USA) Advance Bank Risk Qualification ពី Moody Analytics និងអភិបាលកិច្ចល្អពី IFC។ លោកបានចូលរួមក្នុងវគ្គសិក្សាជាច្រើនទាំងថ្នាក់ជាតិ និងអន្តរជាតិ ទាក់ទងនឹងមីក្រូហិរញ្ញវត្ថុ និងធនាគារ។

លោក Lee ជាធនាគារិកដែលមានបទពិសោធន៍ច្រើនជាង 40ឆ្នាំមកហើយ នៅក្នុងវិស័យធនាគារ។ បទពិសោធន៍របស់គាត់គ្របដណ្តប់លើគ្រប់ផ្នែកនៃវិស័យធនាគាររួមមានធនាគារសាជីវកម្ម ធនាគារបុគ្គល ការវិនិយោគ និងធនាគារឌីជីថល។ ក្នុងនាមជា ធនាគារិកអន្តរជាតិម្នាក់ លោក Lee ធ្លាប់បានបម្រើការនៅប្រទេសកូរ៉េខាងត្បូង សិង្ហបុរី ហុងកុង និងកម្ពុជា។ គាត់បានកសាងធនាគារ PPCBank នៃប្រទេសកម្ពុជា នៅឆ្នាំ2008 និងធនាគារ DGB នៃប្រទេសកម្ពុជា នៅឆ្នាំ2009 មិនត្រឹមតែប៉ុណ្ណោះលោកក៏បានកាន់តួនាទីជាអគ្គនាយកធនាគារ DGB រហូតដល់ឆ្នាំ2021។ នៅក្នុងខែមីនា ឆ្នាំ2021 គាត់បានចូលបម្រើការក្នុងធនាគារ ហ្វីលីព ជាសមាជិកគណៈគ្រប់គ្រងជាន់ខ្ពស់។ ក្រៅពីអាជីពជាធនាគារិកមួយរូប សព្វថ្ងៃនេះ លោក Lee ជាប្រធានក្រុមប្រឹក្សាភិបាលនៃសភាពាណិជ្ជកម្មប្រទេសកូរ៉េ តាំងពីឆ្នាំ2018 ហើយឥឡូវនេះ ជាអាណត្តិទី៣ ដែលលោកបម្រើការក្នុងមុខតំណែងនេះ។

លោក Lee បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកសេដ្ឋកិច្ចពី School of Business Administration ពីសាកលវិទ្យាល័យ Yonsei នៅរដ្ឋធានីសេអ៊ូល ប្រទេសកូរ៉េ។ ជាចំណែកនៃការអភិវឌ្ឍន៍អាជីពរបស់គាត់ លោក Lee បានទទួលជោគជ័យ ក្នុងកម្មវិធីសិក្សា Accelerated Development Program of Booth School ពីសាកលវិទ្យាល័យ The University of Chicago ក្នុងឆ្នាំ2016។

លោក Lee បានលាលែងពីមុខតំណែងរបស់ខ្លួននៅធនាគារ ហ្វីលីព នៅថ្ងៃទី 15 ខែមីនា ឆ្នាំ2024។

# ប្រវត្តិរូបគណៈគ្រប់គ្រង



## លោកស្រី សុខ ចាន់ធារ៉ា

**នាយិកាប្រតិបត្តិ ហិរញ្ញវត្ថុ**

លោកស្រី ចាន់ធារ៉ា មានបទពិសោធន៍ផ្នែកហិរញ្ញវត្ថុ និងធនាគាររយៈពេលជាង 10ឆ្នាំ មកហើយ។ នៅមុនពេលរួមបញ្ចូលគ្នា លោកស្រីជានាយិកាប្រតិបត្តិផ្នែកហិរញ្ញវត្ថុនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រេឌីត។ លោកស្រីក៏ធ្លាប់បម្រើការជា

សវនករឯករាជ្យជាមួយក្រុមហ៊ុនសវនកម្មឯករាជ្យធំៗចំនួន 4 ហើយបានបម្រើការក្នុងវិស័យជាច្រើនរួមមានទំនាក់ទំនងអតិថិជន សេវាហិញ្ញវត្ថុ សាជីវកម្មរោងចក្រសម្លៀកបំពាក់ ព្រមទាំងអង្គការជាតិ និងអន្តរជាតិមួយចំនួនផងដែរ។ លោកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគណនេយ្យ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងបរិញ្ញាបត្រអក្សរសាស្រ្តអង់គ្លេសពីវិទ្យាស្ថានភាសាបរទេសក្នុងឆ្នាំ2006។ នៅខែមិថុនា ឆ្នាំ2013 លោកស្រីបានបញ្ចប់វគ្គសិក្សាផ្នែក ACCA ពីចក្រភពអង់គ្លេស និងបានចូលជាសមាជិក ACCA ក្នុងឆ្នាំដំណាលគ្នានោះផងដែរ។ នៅខែកញ្ញា ឆ្នាំ2018 អ្នកស្រីបានក្លាយជាសមាជិក FCCA។



## លោកស្រី ស្រ៊ិន ស្រីនាង

**នាយិកានៃអគ្គនាយកដ្ឋានរតនាភិបាល**

លោកស្រី ស្រីនាង បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យពីសាកលវិទ្យាល័យនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច (RULE) នាឆ្នាំ2006 និង បញ្ចប់ការសិក្សាផ្នែកគណនេយ្យករជំនាញ (ACCA) នាឆ្នាំ2019។ លោកស្រី បានចាប់ផ្តើមការងារក្នុងឆ្នាំ2006 ក្នុងតួនាទីជាសវនករអស់រយៈពេលប្រាំមួយឆ្នាំកន្លះ។ លោកស្រីមានបទពិសោធន៍ធ្វើសវនកម្មជាមួយស្ថាប័នជាច្រើនដូចជា៖ សាជីវកម្ម ធនាគារ និង អង្គការក្រៅរដ្ឋាភិបាល។ លោកស្រី ត្រូវបានបញ្ជូនទៅធ្វើការនៅក្រុមហ៊ុនសវនកម្ម PwC នៅប្រទេសម៉ាឡេស៊ីរយៈពេល14ខែ ក្នុងកម្មវិធី Secondment។ លោកស្រី ស្រីនាង បានចូលបម្រើការងារនៅធនាគារ ហ្វីលីព ក្នុងខែមេសា ឆ្នាំ2015 ក្នុងតួនាទីជាប្រធានផ្នែកហិរញ្ញវត្ថុ បន្ទាប់មកត្រូវបានតម្លើងឋានៈជានាយិកានៃអគ្គនាយកដ្ឋានរតនាភិបាលរបស់ធនាគារ ។

# ប្រវត្តិរូបគណៈគ្រប់គ្រង



## លោកស្រី LILY SABRINA

**នាយិកាប្រតិបត្តិ ធនធានមនុស្ស**

លោកស្រី Lily បានចូលរួមជាមួយធនាគារ ហ្វីលីព កាលពីខែឧសភា ឆ្នាំ 2020 ក្នុងតំណែងជា នាយិកាប្រតិបត្តិផ្នែកធនធានមនុស្ស។ លោកស្រីទទួលខុសត្រូវផ្នែកធនធានមនុស្ស និងបណ្តុះបណ្តាលរបស់ធនាគារ។ លោកស្រី Lily មានបទពិសោធន៍ក្នុងប្រទេស និងក្រៅប្រទេសជាង25ឆ្នាំ លើផ្នែកផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិការធនធានមនុស្ស ក៏ដូចជាវិស័យផ្សេងៗទៀតរួមមានសេវាកម្មធនាគារ អភិវឌ្ឍ និងវិនិយោគអចលនទ្រព្យ ខ្សែសង្វាក់ផលិតកម្ម និងតំហែទាំសុខុមាលភាព។

លោកស្រី Lily អាចនិយាយភាសាអង់គ្លេស ម៉ាឡេ (បាហាសា) ចិនកុកងឺ ហុកកៀន និងកាតូនីស(គ្រាមភាសាចិន) ហើយលោកស្រីក៏មានជំនាញពេញលេញក្នុងការកំណែ ទម្រង់ការគ្រប់គ្រង ការគ្រប់គ្រងទេព្យកោសល្យ និងរៀបចំស្ថាប័ន ព្រមទាំងវិស័យពាក់ព័ន្ធមួយចំនួនទៀត។

លោកស្រី ទទួលបានសញ្ញាប័ត្រ ផ្នែកគ្រប់គ្រងធនធានមនុស្ស ពីសកលវិទ្យាល័យ Glasgow និងបានបញ្ចប់អនុបណ្ឌិតផ្នែកគ្រប់គ្រងធនធានមនុស្ស ពីសកលវិទ្យាល័យ Open ប្រទេសម៉ាឡេស៊ី។



## លោកស្រី ម៉ៅ សុឃឿន

**នាយិកាប្រតិបត្តិកាត និងប្រតិបត្តិការអេឡិចត្រូនិក**

លោកស្រី សុឃឿន បានចូលបម្រើការងារនៅធនាគារ ហ្វីលីព ក្នុងតួនាទីជានាយិកាប្រតិបត្តិកាត និងប្រតិបត្តិការអេឡិចត្រូនិក នៅខែមិថុនា ឆ្នាំ2022។ មុនពេលចូលបម្រើការងារនៅធនាគារ ហ្វីលីព លោកស្រីមាន បទពិសោធន៍ជាង21ឆ្នាំ ជាមួយនឹងមុខតំណែងផ្សេងៗគ្នា នៅតាមបណ្តាធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDI) ជាច្រើនផ្សេងទៀត។ លោកស្រីក៏ធ្លាប់មានបទពិសោធន៍ ជាអ្នកគ្រប់គ្រងផ្នែកប្រតិបត្តិការ និងហិរញ្ញវត្ថុនាយិកាផ្នែកប័ណ្ណឥណទាន នាយិកាផ្នែកអភិវឌ្ឍន៍ផលិតផល នាយិកាគ្រប់គ្រងផ្នែកគម្រោងឌីជីថល ក៏ដូចជានាយិកាផ្នែកកាត និងការទូទាត់តាមអេឡិចត្រូនិកផងដែរ។

លោកស្រី សុឃឿន បានបញ្ចប់បរិញ្ញាបត្រផ្នែកគណនេយ្យ និងហិរញ្ញវត្ថុពីវិទ្យាស្ថានជាតិគ្រប់គ្រង។ បន្ថែមពីនេះផងដែរ លោកស្រីក៏ទទួលបានការបណ្តុះបណ្តាល និងវិញ្ញាបនបត្រជំនាញផ្សេងៗទៀតពីវគ្គសិក្សាទាំងថ្នាក់ជាតិ និងអន្តរជាតិទាក់ទងទៅនឹងជំនាញមីក្រូហិរញ្ញវត្ថុ ធនាគារ ប្រព័ន្ធសុវត្ថិភាព និងផ្នែកប្រតិបត្តិតាម។

# ប្រវត្តិរូបគណៈគ្រប់គ្រង



## លោក សុខ គឹមឆាយ
**នាយកប្រតិបត្តិ ឌីជីថល**



## លោក ប៊ុន សុភក្រ្តា
**នាយកប្រតិបត្តិ ឥណទាន**

លោក គឹមឆាយ ជាប្រធាននាយកប្រតិបត្តិ ឌីជីថល នៅធនាគារ ហ្វីលីព ដែលបានផ្លាស់ប្តូរមុខតំណែងពីនាយកប្រតិបត្តិផ្នែកព័ត៌មានវិទ្យា។ លោកក៏នៅបន្តមើលការខុសត្រូវនាយកដ្ឋានព័ត៌មានវិទ្យា ដែលផ្តោតទៅលើនវានុវត្តន៍ដំណោះស្រាយផ្នែកបច្ចេកវិទ្យា ដើម្បីធ្វើឲ្យសេវាកម្មហិរញ្ញវត្ថុរួមបញ្ចូលគ្នាយ៉ាងរលូនជាមួយជីវិតរស់នៅប្រចាំថ្ងៃ។ ទំនួលខុសត្រូវរបស់លោក រួមបញ្ចូលការគ្រប់គ្រងផលិតផលបែបឌីជីថល បង្កើនប្រសិទ្ធភាពផលិតផលឌីជីថល និងការបង្កើតឡើងថ្មីនៃផលិតផលឌីជីថល រួមជាមួយនឹងការបន្តគ្រប់គ្រងទៅលើការអភិវឌ្ឍន៍កម្មវិធី ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធស្នូល ការគ្រប់គ្រងគម្រោង ក៏ដូចជាការរចនាផលិតផលឌីជីថល និងការបង្កើនសមត្ថភាពក្រុមការងារឲ្យមានការរីកចម្រើនទៅមុខទាំងអស់គ្នា។ បន្ថែមពីនេះលោកក៏ជាអ្នកគ្រប់គ្រងបុគ្គលិកផ្នែកព័ត៌មានវិទ្យាជាង90 នាក់ ដែលសុទ្ធសឹងតែជាអ្នកជំនាញផ្នែកព័ត៌មានវិទ្យានិងមានទេពកោសល្យខ្ពស់ក្នុងគោលបំណងបង្កើននូវវិធីសាស្ត្រថ្មីៗដើម្បីពង្រឹងនូវវេទិកាឌីជីថលដូចជា មធ្យោបាយទូទាត់ប្រាក់ ការគ្រប់គ្រងដៃគូពាណិជ្ជករ មជ្ឈមណ្ឌលទូទាត់ប្រាក់ ឃ្លាំងផ្ទុកព័ត៌មាន អាជីវកម្មឌីជីថល និងកម្មវិធីទូរស័ព្ទ ដើម្បីធានាបានថាបច្ចេកវិទ្យារបស់ស្ថាប័ន និងធនធានអាចដើរទន្ទឹមគ្នា ស្របនឹងតម្រូវនៃកំណើនលូតលាស់ដ៏រហ័ស ក្នុងទីផ្សារដ៏ប្រកួតប្រជែង។

លោក គឹមឆាយ បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកព័ត៌មានវិទ្យានៅសកលវិទ្យាល័យន័រតុន និងបរិញ្ញាបត្រពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ជំនាញវិទ្យាសាស្ត្រកុំព្យូទ័រ។ ក្រៅពីនេះ លោកក៏បានបញ្ចប់វគ្គសិក្សាជាច្រើន ទាំងក្នុង និងក្រៅប្រទេស ជុំវិញវិស័យមីក្រូហិរញ្ញវត្ថុ សេវាធនាគារ សុវត្ថិភាព និងការប្រតិបត្តិតាម។ ក្រៅពីស្នាដៃជាច្រើន លោក គឹមឆាយ ក៏ទទួលបានពានរង្វាន់ជានាយកប្រតិបត្តិផ្នែកព័ត៌មានវិទ្យាឆ្នើមពីកម្មវិធី ពានរង្វាន់នាយកប្រតិបត្តិផ្នែកព័ត៌មានវិទ្យាប្រចាំអាស៊ាន (ASEAN CIO AWARDS) ក្នុងឆ្នាំ2015 ពី IDG ផងដែរ។

លោក ប៊ុន សុភក្រ្តា ជាថ្នាក់ដឹកនាំដែលមានបទពិសោធន៍ច្បាស់លាស់ជុំវិញផ្នែកឥណទានរបស់ធនាគារ។ លោកមានមុខតំណែងជានាយកប្រតិបត្តិឥណទាន និងជាសមាជិកនៃគណៈកម្មាធិការឥណទាន ដែលទទួលបន្ទុកមើលការទទួលខុសត្រូវលើការត្រួតពិនិត្យមជ្ឈមណ្ឌលដំណើរការឥណទានបុគ្គល នាយកដ្ឋានគ្រប់គ្រងហានិភ័យឥណទាន រដ្ឋបាលឥណទាន និងស្តារបំណុល(សាជីវកម្ម សហគ្រាសខ្នាតតូច និង មធ្យម និងបុគ្គល។)។ លោក សុភក្រ្តា បានចាប់ផ្តើមអាជីពក្នុងវិស័យធនាគារចាប់តាំងពី ឆ្នាំ2005 ហើយលោកបានចូលបម្រើការងារជាមួយធនាគារ ហ្វីលីព ក្នុងខែមីនា ឆ្នាំ2015។

លោក សុភក្រ្តា ជានិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុង ឆ្នាំ2004 និងបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ក្នុងឆ្នាំ2007។ ក្រៅពីបទពិសោធន៍ការងាររបស់លោក លោកក៏បានបញ្ចប់វគ្គសិក្សាមួយចំនួនផ្សេងៗទៀត ទាក់ទងទៅនឹងផ្នែកឥណទាន និងគណនេយ្យករជំនាញ (ACCA) ដែលមានការទទួលស្គាល់ទាំងថ្នាក់ជាតិ និងអន្តរជាតិ។

# ប្រវត្តិរូបគណៈគ្រប់គ្រង



**លោក VINCENT YAP TONG YIN**

នាយកប្រតិបត្តិ អភិវឌ្ឍន៍អាជីវកម្ម

លោក Vincent គឺជាធនាគារិកដ៏ឆ្នើមម្នាក់ ដែលមានបទពិសោធន៍ជាង 30 ឆ្នាំក្នុងវិស័យធនាគារ។ លោក បានកាន់មុខដំណែងជាន់ខ្ពស់ នៅស្ថាប័នហិរញ្ញវត្ថុឈានមុខគេដូចជា ធនាគារនៃប្រទេសអាមេរិក Merrill Lynch ធនាគារ Standard Chartered ធនាគារនៃប្រទេសជប៉ុន Mitsubishi-UFJ ធនាគារ Fleet Boston និងធនាគារ Malayan។ ភាពជាអ្នកដឹកនាំរបស់គាត់បានគ្របដណ្តប់ទៅលើវិស័យធនាគារជាច្រើន រួមមានសហគ្រាសខ្នាតតូច និងមធ្យម និងធនាគារនិម្មិត ដែលគាត់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តន៍យុទ្ធសាស្ត្រអាជីវកម្មទាំងក្នុង និងក្រៅប្រទេស។

មុនពេលចូលបម្រើការជាមួយធនាគារ ហ្វីលីព លោកបានកាន់មុខតំណែងជាអ្នកពិគ្រោះយោបល់ឯករាជ្យផ្នែកហិរញ្ញប្បទានពាណិជ្ជកម្មឌីជីថល និងជាទីប្រឹក្សារបស់ VCargo Cloud Singapore (ទីស្នាក់ការផ្តល់ដំណោះស្រាយ និងជាអ្នកផ្តល់សេវាបច្ចេកវិទ្យាព័ត៌មានឈានមុខគេនៅអាស៊ី) ដោយសហការជាមួយធនាគារពិភពលោកចំនួនប្រាំបួនទៀត ក្រោមគំនិតផ្តួចផ្តើមផតថលកម្មវិធីហិរញ្ញវត្ថុពាណិជ្ជកម្មរបស់អាជ្ញាធររូបិយវត្ថុសិង្ហបុរី ដែលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍កម្មវិធី CamelONE Platform។

លោក Vincent ក៏ជានាយកនៃ APAC to MITIGRAM AB ហើយលោកក៏បានរួមចំណែកក្នុងការបង្កើតឡើងនៃទីផ្សារពាណិជ្ជកម្មឌីជីថល សម្រាប់ហិរញ្ញវត្ថុពាណិជ្ជកម្មផងដែរ។ បន្ទាប់មក លោកក៏បានបញ្ចប់កាតព្វកិច្ចជាទីប្រឹក្សាឯករាជ្យរបស់លោក ដើម្បីចូលរួមជាមួយធនាគារ ហ្វីលីព។ MITIGRAM AB ជាក្រុមហ៊ុនស៊ុយអែតដែលផ្តល់ទីផ្សារឌីជីថល តាមប្រព័ន្ធអ៊ីនធឺណិត សម្រាប់ការគ្របដណ្តប់ហានិភ័យ និងហិរញ្ញប្បទានពាណិជ្ជកម្មពិភពលោក (វេទិកាសម្ព័ន្ធ MITIGRAM) ។

ចាប់តាំងពីលោកបានទទួលយកនូវមុខតំណែង និងតួនាទីថ្មីពេលដែលលោកបានអញ្ជើញចូលបម្រើការងារនៅធនាគារ ហ្វីលីព ក្នុងខែវិច្ឆិកា ឆ្នាំ2019 លោក Vincent បានជួយស្តារឡើងវិញនូវ ផ្នែកធនាគារអេឡិចត្រូនិក (E-Channels Banking) ដោយលោកបាននាំមកនូវជាមួយយុទ្ធសាស្ត្រ ការផ្លាស់ប្តូរថ្មី គំនិតច្នៃប្រឌិត និងឆន្ទៈដ៏មុតមាំ ក្នុងគោលបំណងផ្តល់នូវបទពិសោធន៍ដ៏ល្អបំផុតសម្រាប់អតិថិជនក្នុងការធ្វើប្រតិបត្តិការផ្នែកធនាគារអេឡិចត្រូនិក E-Channels Banking ក្នុងធនាគារ ហ្វីលីព។ កិច្ចខិតខំប្រឹងប្រែងរបស់លោកបានពង្រីកនៃវិស័យធនាគារអេឡិចត្រូនិក (E-Channels Banking) ដែលរួមមានអាជីវកម្មកាត ដៃគូពាណិជ្ជករ ស្ថាប័នអប់រំ សេវាទូទាត់វិក្កយបត្រ និងការគ្រប់គ្រងយុទ្ធនាប្រូម៉ូសិន ពីឆ្នាំ2019 រហូតដល់ឆ្នាំ2023។

នៅឆ្នាំ2024 លោក Vincent បានទទួលយកនៃការចាប់ផ្តើមថ្មីក្នុងនាយកដ្ឋានប្រតិបត្តិការធនាគារ និងផ្តួចផ្តើមក្នុងការបង្កើតនាយកដ្ឋានអភិវឌ្ឍន៍អាជីវកម្ម។ លោកបានផ្តោតសំខាន់ទៅលើឱកាសនៃការបង្កើតអាជីវកម្មថ្មីៗដែលមានសក្តានុពល ក៏ដូចជាការទាក់ទាញអតិថិជនសាជីវកម្មថ្មីៗមកកាន់ធនាគារ ។

លោក Vincent  បានបញ្ចប់បរិញ្ញាបត្រ (កិត្តិយស) ផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យយ៉ក (University of York) ពីចក្រភពអង់គ្លេស នៅក្នុងឆ្នាំ1982។

# ប្រវត្តិរូបគណៈគ្រប់គ្រង



## លោក HASHIM ALKAFF SYED

**នាយកប្រតិបត្តិ ប្រព័ន្ធធនាគារអេឡិចត្រូនិក**

លោក Hashim គឺជាអ្នកពហុជំនាញទូទៅដែលមានបទពិសោធន៍ នៅក្នុងផ្នែកប្រតិបត្តិការ ទីផ្សារ ផែនការហិរញ្ញវត្ថុ ការអភិវឌ្ឍន៍ផលិតផល និងបទពិសោធន៍អតិថិជន។ នៅក្នុងប្រទេសកម្ពុជា លោកក៏ធ្លាប់បម្រើការជាប្រធានតំណាងប្រទេសនៃអាស៊ីអាគ្នេយ៍នៅក្នុងវិស័យដឹកជញ្ជូន និងធ្វើដំណើរ ក៏ដូចជាប្រធានផ្នែកពាណិជ្ជកម្ម នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាជីវកម្មឌីជីថល Start-up ផងដែរ។

ក្នុងនាមជានាយកប្រតិបត្តិ ប្រព័ន្ធធនាគារអេឡិចត្រូនិក លោក Hashim ជាបុគ្គលមានទេព្យកោសល្យមួយរូបដែលចូលរួមផ្តល់នូវគំនិតច្នៃប្រឌិតនិងធ្វើការសម្រេចចិត្តដោយផ្អែកទៅលើការវិភាគនៃទិន្នន័យ។ លោកក៏ទទួលបន្ទុក មើលការខុសត្រូវទៅលើផ្នែកសំខាន់ៗដូចជា អាជីវកម្មជាមួយអាជីវកម្ម (B2B) ដំណោះស្រាយតាមអេឡិចត្រូនិក ការគ្រប់គ្រងដៃគូពាណិជ្ជករ ការអភិវឌ្ឍន៍អាជីវកម្មកាត ទីផ្សារនិងទំនាក់ទំនង ការគ្រប់គ្រងយុទ្ធនាការប្រូម៉ូសិន សេវាធនាគារតាមអ៊ីនធឺណិត ដំណោះស្រាយប្រាក់បៀវត្សរ៍ និងម៉ាស៊ីនស្វ័យប្រវត្តិ។



## លោក ម៉ិច វណ្ណៈ

**នាយក នាយកដ្ឋានព័ត៌មានវិទ្យា**

លោក វណ្ណៈ បានបញ្ចប់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ និងវិស្វកម្ម និងបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម។ លោកមានបទពិសោធន៍ជាង 15ឆ្នាំនៅក្នុងតួនាទីផ្សេងៗ នៃផ្នែកព័ត៌មានវិទ្យា ដែលរួមមានវិស្វករបណ្តាញអ៊ីនធឺណិត ប្រធានផ្នែកប្រព័ន្ធ និងបណ្តាញអ៊ីនធឺណិត ប្រធានផ្នែកបណ្តាញអ៊ីនធឺណិត និងហេដ្ឋារចនាសម្ព័ន្ធ នាយករងផ្នែកព័ត៌មានវិទ្យា និងនាយកផ្នែកហេដ្ឋារចនាសម្ព័ន្ធ។

លោក វណ្ណៈ ត្រូវបានតែងតាំងជាប្រធានផ្នែកព័ត៌មានវិទ្យា នៅធនាគារ ហ្វីលីព នៅថ្ងៃទី 01 ខែមករា ឆ្នាំ2024។ ក្រៅពីនេះ លោកក៏មានវិញ្ញាបនបត្របណ្តុះបណ្តាល និងជំនាញផ្សេងទៀតពីវគ្គសិក្សាទាំងក្នុង និងក្រៅប្រទេស ជុំវិញទៅនឹងផ្នែកព័ត៌មានវិទ្យា។

# ប្រវត្តិរូបគណៈគ្រប់គ្រង



**លោក រុំ វណ្ណារ៉ា**

**នាយកប្រតិបត្តិ ឥណទានអាជីវកម្មខ្នាតតូចមធ្យម និងគ្រប់គ្រងសាខាថ្នាក់ខេត្ត**

លោក វណ្ណារ៉ា មានបទពិសោធន៍ជាង 20ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារ។ បន្ទាប់ពីការរួមបញ្ចូលគ្នា គាត់ត្រូវបានដំឡើងឋានៈជានាយកប្រតិបត្តិឥណទានអាជីវកម្មខ្នាតតូច មធ្យម និងគ្រប់គ្រងសាខាថ្នាក់ខេត្ត។ លោកទទួលបន្ទុកត្រួតពិនិត្យលើការគ្រប់គ្រងអនុវត្តសាខាតាមខេត្ត ក៏ដូចជាការត្រួតពិនិត្យលើនាយកដ្ឋានឥណទានអាជីវកម្មខ្នាតតូច និងមធ្យម នាយកដ្ឋានឥណទានខ្នាតតូច នាយកដ្ឋានស្តារបំណុលសម្រាប់ឥណទានខ្នាតតូចអាជីវកម្មខ្នាតតូច និងមធ្យម ក៏ដូចជានាយកដ្ឋានបណ្តាញសាខាថ្នាក់ខេត្ត ដែលមានតួនាទីបង្កើនការដាក់ប្រាក់បញ្ញើ និងផលិតផលមិនពាក់ព័ន្ធនឹងឥណទាន។

លោកបានបញ្ចប់ការសិក្សា ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ក៏ដូចជាបរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស ពីសកលវិទ្យាល័យបៀលប្រាយ។ នៅឆ្នាំ2010 លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ និងធនាគារ នៅសាកលវិទ្យាល័យបៀលប្រាយ។ លោកបានបញ្ចប់ការសិក្សាកម្មវិធី Omega Performance U.S ផ្នែកឥណទានពាណិជ្ជកម្ម និងអាជីវកម្ម និងទទួលបានវិញ្ញាបនបត្រពី Moody’s Analytics នៅឆ្នាំ2019។ ជាងនេះទៅទៀត លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទាំងថ្នាក់ជាតិ និងអន្តរជាតិទាក់ទងនឹងមីក្រូហិរញ្ញវត្ថុ និងសេវាធនាគារដូចជា ការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ និងធនាគារ ផលិតផល និងសេវាធនាគារ ការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងប្រតិបត្តិការសេវាធនាគារ ការគ្រប់គ្រងហានិភ័យឥណទាន ការគ្រប់គ្រងប្រតិបត្តិការតាមសាខា ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងជាន់ខ្ពស់ ដំណើរការអភិវឌ្ឍន៍អាជីវកម្ម ច្បាប់និងកិច្ចសន្យាពាណិជ្ជកម្ម សេវាធនាគារឌីជីថល ការគ្រប់គ្រងថវិកា និងវិភាគទិន្នន័យ។ល។

# រចនាសម្ព័ន្ធរបស់ធនាគារ ហ្វីលីព




គណៈកម្មាធិការសវនកម្ម
នាយកដ្ឋានសវនកម្ម
គណៈកម្មាធិការតែងតាំង និងវាយតម្លៃ
តំណាងភាគទុនិក
ឥណទាន
ហានិភ័យឥណទាន
រដ្ឋបាលឥណទាន
មជ្ឈមណ្ឌលដំណើរការឥណទានបុគ្គល
កាត និងប្រតិបត្តិការអេឡិចត្រូនិក
គ្រប់គ្រងកាត
អភិវឌ្ឍន៍ផលិតផល
គាំទ្រអាជីវកម្មអេឡិចត្រូនិក
ប្រតិបត្តិការអេឡិចត្រូនិក / សេវាកម្មធនាគារតាមអ៊ីនធឺណិត
មជ្ឈមណ្ឌលទំនាក់ទំនងអតិថិជន
ធនាគារអេឡិចត្រូនិក
ដៃគូធុរកិច្ចតាមភូមិភាគ
ទំនាក់ទំនងដៃគូធុរកិច្ច
ដៃគូទូទាត់ និងសាលារៀន
យុទ្ធនាការ
សេវាកម្មធនាគារតាមអ៊ីនធឺណិត និងដំណោះស្រាយប្រាក់បៀវត្ស
អាជីវកម្មកាត
ទីផ្សារ និងទំនាក់ទំនង
ព័ត៌មានវិទ្យា
អភិវឌ្ឍកម្មវិធី
ហេដ្ឋារចនាសម្ព័ន្ធ
ប្រព័ន្ធធនាគារស្នូល
ការិយាល័យគ្រប់គ្រងគម្រោង
ធនាគារឌីជីថល
នវានុវត្តន៍ផ្នែកឌីជីថល
បទពិសោធន៍អតិថិជន
ប្រតិបត្តិការ
ប្រតិបត្តិការសាខា
ហិរញ្ញប្បទានពាណិជ្ជកម្ម និងប្រតិបត្តិការ
លេខាធិការក្រុមហ៊ុន
ច្បាប់
ស្រាវជ្រាវ
សុវត្ថិភាពព័ត៌មានវិទ្យា
ដោះស្រាយបំណុល

ហិរញ្ញវត្ថុ

# ធនាគារ ហ្វីលីព ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

## របាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 និងរបាយការណ៍របស់សវនករឯករាជ្យ


- ព័ត៌មានអំពីធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ........ 48
- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ........ 49
- របាយការណ៍សវនករឯករាជ្យ ........ 54
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម ........ 58
- របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម ........ 60
- របាយការណ៍បម្រែបម្រួលមូលធនរួម ........ 61
- របាយការណ៍លំហូរទឹកប្រាក់រួម ........ 63
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុដោយឡែក ........ 65
- របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗដោយឡែក ........ 67
- របាយការណ៍បម្រែបម្រួលមូលធនដោយឡែក ........ 68
- របាយការណ៍លំហូរទឹកប្រាក់ដោយឡែក ........ 69
- កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ........ 71

# ព័ត៌មានអំពីធនាគារ និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

| | | |
|---|---|---|
| **ក្រុមហ៊ុន** | ធនាគារ ហ្វីលីព ភីអិលស៊ី | |
| **លេខចុះបញ្ជីពាណិជ្ជកម្ម** | 00000292 | |
| **ទីស្នាក់ការចុះបញ្ជី** | អគារលេខ 27DEFG មហាវិថីព្រះមុន្នីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| **ភាគទុនិក** | Phillip MFIS PTE. LTD. | |
| **ក្រុមប្រឹក្សាភិបាល** | លោក Lim Hua Min | ប្រធានក្រុមប្រឹក្សាភិបាល |
| | លោក Ong Teong Hoon | អភិបាលប្រតិបត្តិ |
| | លោក ចាន់ ម៉ាច | អភិបាលប្រតិបត្តិ |
| | លោក Paul Gwee Choon Guan | អភិបាលឯករាជ្យ |
| | លោកស្រី Seah Yen Goon | អភិបាលឯករាជ្យ |
| | លោក Koh Yong Guan | អភិបាលឯករាជ្យ |
| | លោក Pen Chanda | អភិបាលឯករាជ្យ |
| **អ្នកគ្រប់គ្រង** | លោក ចាន់ ម៉ាច | អគ្គនាយក |
| | លោក Lee Yong Man | អគ្គនាយករង (លាលែងនៅថ្ងៃទី15 ខែមីនា ឆ្នាំ2024) |
| | លោក ប៊ុន សុភក្ត្រា | នាយកប្រតិបត្តិឥណទាន |
| | លោកស្រី សុខ ចាន់ធារ៉ា | នាយិកាប្រតិបត្តិហិរញ្ញវត្ថុ |
| | លោកស្រី ស្រ៊ន ស្រីនាង | នាយិការតនាគារ |
| | លោកស្រី Lily Sabrina Kuang Binti Abdullah | នាយិកាប្រតិបត្តិធនធានមនុស្ស |
| | លោក សុខ គឹមឆាយ | នាយកប្រតិបត្តិព័ត៌មានវិទ្យា |
| | លោក រ៉ុ វណ្ណារ៉ា | នាយកប្រតិបត្តិឥណទានអាជីវកម្មខ្នាតតូចមធ្យម និងគ្រប់គ្រងសាខាថ្នាក់ខេត្ត |
| | លោក Yap Tong Yin | នាយកប្រតិបត្តិអភិវឌ្ឍអាជីវកម្ម |
| | លោកស្រី ម៉ៅ សុឃឿន | នាយិកាប្រតិបត្តិកាត និងប្រតិបត្តិការអេឡិចត្រូនិច |
| | លោក Syed Hashim Alkaff | នាយកប្រតិបត្តិប្រព័ន្ធធនាគារអេឡិចត្រូនិច |
| **សវនករ** | KPMG Cambodia Ltd | |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល បានដាក់ជូនរបាយការណ៍របស់ខ្លួនរួមជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ធនាគារ ហ្វីលីព ភីអិលស៊ី ហៅកាត់ថា (“ធនាគារ”) និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ហៅកាត់ថា (“សម្ព័ន្ធធនាគារ”) និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ធនាគារនៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ (ដែលតទៅនេះ ហៅកាត់ថា “ របាយការណ៍ហិរញ្ញវត្ថុ) ”។

## សកម្មភាពចម្បង

### ធនាគារ

ធនាគារ បានបង្កើតឡើងនៅថ្ងៃទី26 ខែមិថុនា ឆ្នាំ2009 ក្រោមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មកម្ពុជា និងទទួលបានអាជ្ញាប័ណ្ណស្របតាមបទប្បញ្ញត្តិនៃធនាគារជាតិនៃកម្ពុជា។ ធនាគារត្រូវបានកាន់កាប់ទាំងស្រុងដោយ Phillip MFIS Pte Ltd។

ធនាគារ ធ្វើការផ្តល់សេវាកម្មធនាគារ និងសេវាកម្ម ដែលពាក់ព័ន្ធផ្សេងទៀតនឹងហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ពុំមានការផ្លាស់ប្តូរជាសារវន្តនៅក្នុងសកម្មភាពចម្បងរបស់ធនាគារក្នុងអំឡុងការិយបរិច្ឆេទទេ។

### ក្រុមហ៊ុនបុត្រសម្ព័ន្ធ

ក្នុងការិយបរិច្ឆេទ 2022 ធនាគារបានវិនិយោគមូលធន 49% នៅហ្វីលីព គ្រាសធី (ខេមបូឌា) ឯ.ក ជាក្រុមហ៊ុនថ្មីដែលបានបង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី25 ខែកក្កដា ឆ្នាំ2022 នៅក្រោមច្បាប់កម្ពុជាស្តីពីសហគ្រាសពាណិជ្ជកម្ម និងបានទទួលអាជ្ញាប័ណ្ណពីនិយតករបរធនបាលកិច្ចថ្ងៃទី15 ខែធ្នូ ឆ្នាំ 2022។

សកម្មភាពចម្បងរបស់ហ្វីលីព គ្រាសធី (ខេមបូឌា) ឯ.ក គឺផ្តល់សេវាកម្មបរធនបាលកិច្ច រួមមានការកាន់កាប់អចលនទ្រព្យសម្រាប់បរធនបាលកិច្ចពាណិជ្ជកម្ម បរធនបាលកិច្ចសង្គម និងបរធនបាលកិច្ចបុគ្គល និងបរធនបាលកិច្ចផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ។ សូមមើលទំព័រ 12 និង17។

## ភាគលាភ

ពុំមានការប្រកាស ឬការបែងចែកភាគលាភ ហើយក្រុមប្រឹក្សាភិបាលក៏ពុំមានអនុសាសន៍ឲ្យមានការបែងចែកភាគលាភ សម្រាប់ការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

## ដើមទុន

ដើមទុនរបស់ធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 មានចំនួន 75,000,000 ដុល្លារអាមេរិក ឬ 300,765,000 ពាន់រៀល (ឆ្នាំ2022៖ 75,000,000 ដុល្លារអាមេរិក ឬ 300,765,000 ពាន់រៀល) តាមរយៈការចេញផ្សាយភាគហ៊ុន ជាមួយនឹងតម្លៃចារឹកមួយដុល្លារអាមេរិកក្នុងមួយហ៊ុន។

## ទុនបម្រុង និងសំវិធានធន

ពុំមានបម្រែបម្រួលផ្សេងទៀតទៅលើ ឬមកពីទុនបម្រុង និងសំវិធានធនក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុ ក្រៅពីព័ត៌មានដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការខាតបង់ឥណទានដែលបានរំពឹងទុកលើឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារនិងធនាគារ ត្រូវបានរៀបចំឡើងក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានា ដើម្បីធានាថានីតិវិធីពាក់ព័ន្ធជាមួយនឹងការជម្រះបញ្ជីនៃឥណទានអាក្រក់ និងក្នុងការទទួលស្គាល់សំវិធានធនសម្រាប់ ការខាតបង់ឥណទានរំពឹងទុកត្រូវបានយកមកអនុវត្ត ហើយរួមទាំងធានាថារាល់ឥណទានអាក្រក់ដែលបានកត់សម្គាល់ត្រូវបានជម្រះចេញពីបញ្ជី ហើយសំវិធានធនគ្រប់គ្រាន់ ត្រូវបានធ្វើឡើងសម្រាប់ការខាតបង់ឥណទានរំពឹងទុក។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលអាចបណ្តាលឲ្យចំនួនទឹកប្រាក់ជម្រះចេញពីបញ្ជីនៃឥណទានអាក្រក់ ឬចំនួនសំវិធានធនលើការខាតបង់ឥណទានរំពឹងទុកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារនិងធនាគារមានភាពមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

## ទ្រព្យសកម្ម

មុនពេលរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារនិងធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របដើម្បីធានាថា ទ្រព្យសកម្មណាមួយក្រៅពីបំណុល ដែលទំនងជាមិនអាចប្រមូលបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា តាមដែលបានបង្ហាញនៅក្នុងបញ្ជីគណនេយ្យរបស់សម្ព័ន្ធធនាគារនិងធនាគារត្រូវបានកាត់បន្ថយឲ្យទៅស្មើនឹងតម្លៃ ដែលរំពឹងថាអាចនឹងប្រមូលបានជាក់ស្តែង។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារនិងធនាគារថាមានភាពមិនត្រឹមត្រូវ។

## វិធីសាស្ត្រនៃការវាយតម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលកើតឡើង ដែលអាចធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងទ្រព្យអកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារនិងធនាគារមានភាពមិនត្រឹមត្រូវ ឬមិនសមស្របណាមួយនោះទេ។

## ទ្រព្យអកម្មយថាភាព និងទ្រព្យអកម្មផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

(ក) ពុំមានការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់សម្ព័ន្ធធនាគារនិងធនាគារ ដែលកើតមានឡើងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុសម្រាប់ធានាចំពោះទ្រព្យអកម្មរបស់បុគ្គលណាមួយ ឬ

(ខ) ពុំមានទ្រព្យអកម្មយថាភាពណាមួយកើតមានឡើងចំពោះសម្ព័ន្ធធនាគារនិងធនាគារ ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុ ក្រៅពីដំណើរការធម្មតានៃអាជីវកម្មសម្ព័ន្ធធនាគារនិងធនាគារ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេលដប់ពីរខែបន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់សម្ព័ន្ធធនាគារនិងធនាគារក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់នោះទេ ។

## ការផ្លាស់ប្តូរកាលៈទេសៈ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនជាប់ទាក់ទិនជាមួយរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារនិងធនាគារ ដែលអាចបណ្តាលឲ្យចំនួនណាមួយដែលមានចែងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារនិងធនាគារមានភាពមិនត្រឹមត្រូវនោះទេ ។

## ប្រតិបត្តិការមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលប្រតិបត្តិការរបស់សម្ព័ន្ធធនាគារនិងធនាគារសម្រាប់ការិយបរិច្ឆេទនេះ មិនបានរងផលប៉ះពាល់ជាសារវន្ត ដោយធាតុប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈមិនប្រក្រតី និងជាសារវន្តនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់សម្ព័ន្ធធនាគារនិងធនាគារ ក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ពុំមានព្រឹត្តិការណ៍សំខាន់ណាបានកើតឡើងក្នុងអំឡុងពេលរវាង ចុងបញ្ចប់នៃការិយបរិច្ឆេទរាយការណ៍ និងកាលបរិច្ឆេទនៃការអនុម័តចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុ ដែលតម្រូវឲ្យមានការធ្វើនិយ័តកម្ម ឬការបង្ហាញ ដែលនឹងត្រូវធ្វើឡើងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលរបស់សម្ព័ន្ធធនាគារនិងធនាគារដែលបម្រើការងារនៅក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះ រួមមាន៖

| | |
|---|---|
| លោក Lim Hua Min | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Ong Teong Hoon | អភិបាល |
| លោក ចាន់ ម៉ាច | អភិបាល និងអគ្គនាយកប្រតិបត្តិ |
| លោក Paul Gwee Choon Guan | អភិបាលឯករាជ្យ |
| លោកស្រី Diana Seah Yen Goon | អភិបាលឯករាជ្យ |
| លោក Koh Yong Guan | អភិបាលឯករាជ្យ |
| លោក Pen Chanda | អភិបាលឯករាជ្យ |

## ភាគហ៊ុនកាន់កាប់ដោយក្រុមប្រឹក្សាភិបាល

លោក Lim Hua Min ដែលជាប្រធានក្រុមប្រឹក្សាភិបាល កាន់កាប់ភាគហ៊ុន 85% នៅក្នុង Phillip MFIS PTE LTD។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុង និងនាចុងការិយបរិច្ឆេទនេះ ពុំមានការព្រមព្រៀងណាមួយដែលបានកើតមានឡើងមក ដែលសម្ព័ន្ធធនាគារនិងធនាគារ ជាភាគីដែលមានគោលបំណងជួយដល់ក្រុមប្រឹក្សាភិបាលរបស់សម្ព័ន្ធធនាគារនិងធនាគារ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ ដោយការទិញយកភាគហ៊ុន ឬលិខិតបំណុលពីធនាគារ ឬពីអង្គភាពដទៃទៀតទេ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុឆ្នាំកន្លងទៅ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលរបស់សម្ព័ន្ធធនាគារ និងធនាគារណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ ដែលបានរួមបញ្ចូល នៅក្នុងចំនួនបរិលាភសរុបទទួលបាន ឬដល់កំណត់ទទួលបាន ដោយសមាជិកក្រុមប្រឹក្សាភិបាលដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈកិច្ចសន្យាដែលធ្វើឡើងដោយសម្ព័ន្ធធនាគារ និងធនាគារ ដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុន ដែលកុម្រប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅលើរបាយការណ៍ហិរញ្ញវត្ថុ ។

## ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានតួនាទីក្នុងការធានាថារបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុ របស់សម្ព័ន្ធធនាគារនិងធនាគារនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 និងលទ្ធផលហិរញ្ញវត្ថុ ហើយនិងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ អន្តរជាតិនៃកម្ពុជា (“ស.រ.ទ.ហ.អ.ក”) ដែលបានបង្ហាញនៅទំព័រទី11 ដល់ទី154។ ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យមើលការរៀបចំនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះដោយគណៈគ្រប់គ្រងដែលជាអ្នកបានតម្រូវឲ្យ៖

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

(i) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព។

(ii) អនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“ស.រ.ទ.ហ.អ.ក”) ឬបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ គឺត្រូវបង្ហាញ និងពន្យល់ឲ្យបានច្បាស់លាស់ និងកំណត់បរិមាណនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(iii) ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។

(iv) វាយតម្លៃនូវលទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារ ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយ ដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការសម្ព័ន្ធធនាគារ និងធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

(v) គ្រប់គ្រង និងដឹកនាំសម្ព័ន្ធធនាគារនិងធនាគារ ប្រកបដោយប្រសិទ្ធភាពលើការសម្រេចចិត្ត ដែលអាចប៉ះពាល់ជាសារវន្តដល់ប្រតិបត្តិការ និងដំណើរការអាជីវកម្ម ហើយត្រូវប្រាកដថាកិច្ចការទាំងនេះ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា សម្ព័ន្ធធនាគារនិងធនាគារ បានអនុវត្តតាមនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើក្នុងការរៀបចំបាយការណ៍ហិរញ្ញវត្ថុរបស់នេះ។

## សវនករ

ក្រុមហ៊ុន ខេភីអឹមជី ខេមបូឌា គឺជាសវនកររបស់សម្ព័ន្ធធនាគារនិងធនាគារ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ ដែលជាមតិរបស់យើងខ្ញុំបានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ចុះហត្ថលេខាដោយយោងទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល៖

ធនាគារ ភីលីព ភីអិលស៊ី
ការិយាល័យកណ្តាល
Head Office
PHILLIP BANK PLC.

ONG TEONG HOON
អភិបាល
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី29 ខែមីនា ឆ្នាំ2024

# របាយការណ៍របស់សវនករឯករាជ្យ

*( ជូនចំពោះភាគទុនិករបស់ធនាគារ ហ្វីលីព ភីអិលសុី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ )*

## មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ ហ្វីលីព ភីអិលសុី (ហៅកាត់ថា “ធនាគារ”) និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ហៅកាត់ថា (“សម្ព័ន្ធធនាគារ”) ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម និងដោយឡែក នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម និងដោយឡែក របាយការណ៍បម្រែបម្រួលមូលធនរួម និងដោយឡែក និងរបាយការណ៍លំហូរទឹកប្រាក់រួម និងដោយឡែក សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមានគោលនយោបាយគណនេយ្យសារវន្ត ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀត ដូចបានបង្ហាញនៅទំព័រទី11 ដល់ទី154 (ដែលហៅកាត់ថា “របាយការណ៍ហិរញ្ញវត្ថុ”)។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ បានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរួម និងដោយឡែករបស់សម្ព័ន្ធធនាគារនិងធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់សម្ព័ន្ធធនាគារនិងធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“ស.រ.ទ.ហ.អ.ក”)។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដាទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពី ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានភាពឯករាជ្យពីសម្ព័ន្ធធនាគារនិងធនាគារ ដោយស្របទៅតាមលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌វិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវក្រមសីលធម៌វិជ្ជាជីវៈផ្សេងៗទៀតស្របតាមលក្ខខណ្ឌតម្រូវទាំងនេះ។យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមាន របាយការណ៍របស់ក្រុមប្រឹក្សាភិបាលដែលបានបង្ហាញនៅទំព័រទី1 ដល់ទី6 និងរបាយការណ៍ប្រចាំឆ្នាំ ដែលរំពឹងថានឹងរួចរាល់ បន្ទាប់ពីកាលបរិច្ឆេទ នៃរបាយការណ៍សវនកម្មនេះ។ មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មានផ្សេងៗនេះទេ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានការបង្ហាញនូវកំហុសឆ្គងជាសារវន្ត។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឲ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធ នឹងព័ត៌មានផ្សេងៗនេះទេ។

# របាយការណ៍របស់សវនករឯករាជ្យ

*( ជូនចំពោះភាគទុនិករបស់ធនាគារ ហ្វីលីព ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ )*

## បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេង ហើយបានបញ្ចេញមតិនៅថ្ងៃទី29 ខែមីនា ឆ្នាំ2023 ថារបាយការណ៍ហិរញ្ញវត្ថុទាំងនោះមានភាពត្រឹមត្រូវ។

យើងខ្ញុំសូមបញ្ជាក់ថា យើងខ្ញុំមិនបានធ្វើសវនកម្មទៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួមរបស់សម្ព័ន្ធធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម របាយការណ៍បម្រែបម្រួលមូលធនរួម និងរបាយការណ៍លំហូរទឹកប្រាក់រួម សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 និងកំណត់សម្គាល់ពាក់ព័ន្ធនឹងព័ត៌មានពន្យល់ផ្សេងៗដូចមានភ្ជាប់ជាមួយ អាស្រ័យហេតុនេះយើងខ្ញុំមិនបញ្ចេញមតិសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុទាំងនោះទេ។

## ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ចលើរបាយការណ៍ហិរញ្ញវត្ថុ

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហើយទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់សម្ព័ន្ធធនាគារនិងធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀត ក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ព័ត៌មាន ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារនិងធនាគារ។

## ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺទទួលបាននូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូល មិនមានការ បង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករ ដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមួយដែលមានកម្រិតខ្ពស់ ប៉ុន្តែវាមិនអាចធានាបានថា គ្រប់ពេលនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។

ការបង្ហាញខុស អាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាមានលក្ខណៈសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងដោយឡែក ឬក៏រួមបញ្ចូលគ្នា អាចត្រូវបានរំពឹងទុកយ៉ាងសមហេតុផលថានឹងជះឥទ្ធិពលដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍របស់សវនករឯករាជ្យ

*( ជូនចំពោះភាគទុនិករបស់ធនាគារ ហ្វីលីព ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ )*

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយមក្នុងអំឡុងពេលធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការតាក់តែង និងអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យនៃការរកមិនឃើញនូវការបង្ហាញខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសដែលបណ្តាលមកពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចទាក់ទិននឹងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

- ធ្វើការស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីតាក់តែងនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ ធនាគារឡើយ។

- វាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលសម្ព័ន្ធធនាគារ និងធនាគារបានអនុវត្ត និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធនានា ដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។

- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃ គណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតមានឡើង ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចបង្កឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់សម្ព័ន្ធធនាគារនិងធនាគារ ដើម្បីបន្តនិរន្តរភាពអាជីវកម្មដែរ ឬទេ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវទាញចំណាប់អារម្មណ៍ នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបាន ត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឲ្យសម្ព័ន្ធធនាគារនិងធនាគារបញ្ឈប់និរន្តរភាពនៃអាជីវកម្ម។

- ធ្វើការវាយតម្លៃលើការបង្ហាញ ទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដោយរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

- ទទួលបាននូវភស្តុតាងសវនកម្មដែលសមស្រប និងគ្រប់គ្រាន់ពាក់ព័ន្ធនឹងព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនិងសកម្មភាពអាជីវកម្មនៅក្នុងសម្ព័ន្ធធនាគារដើម្បីបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុរួម។ យើងខ្ញុំទទួលខុសត្រូវក្នុងការដឹកនាំការត្រួតត្រាមើល និងការប្រតិបត្តិនៃសវនកម្មរបស់សម្ព័ន្ធធនាគារ។ យើងខ្ញុំរក្សាការទទួលខុសត្រូវលើ មតិសវនកម្មរបស់យើងខ្ញុំ។

# របាយការណ៍របស់សវនករឯករាជ្យ

*( ជូនចំពោះភាគទុនិករបស់ធនាគារ ហ្វីលីព ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ )*

យើងខ្ញុំ ផ្តល់ព័ត៌មាន ក្នុងចំណោមបញ្ហាផ្សេងៗ ជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្ត ដោយរួមបញ្ចូលទាំងចំណុចខ្វះខាតជាសារវន្ត ក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា**

តាំង យុកហ្វុង
*Partner*
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី29 ខែមីនា ឆ្នាំ2024

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម

*(នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

| | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.4.3) |
| | | | | (មិនរងសវនកម្ម) | |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | 5 | 136,796,268 | 558,812,754 | 73,913,894 | 304,303,502 |
| ប្រាក់បញ្ញើនៅស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | 6 | 3,515,843 | 14,362,218 | 262,397 | 1,080,288 |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិ | 7 | 48,527,608 | 198,235,279 | 42,591,664 | 175,349,881 |
| ឥណទាន និងបុរេប្រទានទៅអតិថិជន | 8 | 582,247,771 | 2,378,482,145 | 582,611,307 | 2,398,610,751 |
| ទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្របក្នុងលទ្ធផលផ្សេងៗ | | 42,500 | 173,613 | 42,500 | 174,973 |
| ទ្រព្យសកម្មរក្សាទុកសម្រាប់លក់ | 10 | 1,800,000 | 7,353,000 | - | - |
| ទ្រព្យសកម្មផ្សេងៗ | 11 | 2,687,745 | 10,979,438 | 2,753,675 | 11,336,880 |
| ទ្រព្យ និងបរិក្ខារ | 12 | 6,158,021 | 25,155,516 | 7,209,764 | 29,682,598 |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | 13 | 9,846,490 | 40,222,912 | 10,370,446 | 42,695,126 |
| ទ្រព្យសកម្មអរូបី | 14 | 1,528,897 | 6,245,545 | 1,833,235 | 7,547,428 |
| **ទ្រព្យសកម្មសរុប** | | 793,151,143 | 3,240,022,420 | 721,588,882 | 2,970,781,427 |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | 15 | 63,870,907 | 260,912,655 | 54,790,080 | 225,570,759 |
| ប្រាក់បញ្ញើពីអតិថិជន | 16 | 536,373,537 | 2,191,085,899 | 453,088,610 | 1,865,365,807 |
| ប្រាក់កម្ចី | 17ក | 16,748,255 | 68,416,622 | 40,675,993 | 167,463,063 |
| បំណុលភតិសន្យា | 18 | 9,500,667 | 38,810,225 | 9,860,478 | 40,595,588 |
| បំណុលផ្សេងៗ | 19 | 3,098,137 | 12,655,889 | 3,704,681 | 15,252,172 |
| បំណុលពន្ធលើប្រាក់ចំណេញ | 20.1 | 68,170 | 278,474 | 1,194,668 | 4,918,448 |
| ពន្ធពន្យារជាបំណុល | 20.2 | 1,410,111 | 5,760,304 | 781,315 | 3,216,674 |
| អនុបំណុល | 17ខ | 4,588,881 | 18,745,579 | 5,092,082 | 20,964,102 |
| **បំណុលសរុប** | | 635,658,665 | 2,596,665,647 | 569,187,907 | 2,343,346,613 |
| **មូលធន** | | | | | |
| ដើមទុន | 21.1 | 75,000,000 | 300,765,000 | 75,000,000 | 300,765,000 |
| ទុនបម្រុងផ្សេងៗ | 21.2 | 25,490,274 | 103,923,847 | 25,490,274 | 103,923,847 |

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម

*(នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

| | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.4.3) (មិនរងសវនកម្ម) |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 21.3 | 17,738,393 | 72,411,679 | 13,044,620 | 53,120,272 |
| ប្រាក់ចំណេញរក្សាទុក | | 38,819,211 | 158,103,981 | 38,356,081 | 156,200,517 |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | - | 6,336,075 | - | 11,325,508 |
| **មូលធនរបស់ភាគទុនិក** | | 157,047,878 | 641,540,582 | 151,890,975 | 625,335,144 |
| អប្បភាគភាគកម្ម | 21.4 | 444,600 | 1,771,206 | 510,000 | 2,040,000 |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | - | 44,985 | - | 59,670 |
| **មូលធនសរុប** | | 157,492,478 | 643,356,773 | 152,400,975 | 627,434,814 |
| **បំណុល និងមូលធនសរុប** | | 793,151,143 | 3,240,022,420 | 721,588,882 | 2,970,781,427 |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម

*(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

| | | ឆ្នាំ2023 | | ឆ្នាំ2022 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) | ដុល្លារអាមេរិក (មិនរងសវនកម្ម) | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) |
| ចំណូលការប្រាក់ | 22 | 75,875,904 | 311,849,965 | 73,954,309 | 302,251,261 |
| ចំណាយការប្រាក់ | 23 | (35,127,322) | (144,373,293) | (27,463,014) | (112,241,338) |
| **ចំណូលការប្រាក់សុទ្ធ** | | 40,748,582 | 167,476,672 | 46,491,295 | 190,009,923 |
| ចំណូលសេវា និងកម្រៃជើងសារសុទ្ធ | 24 | 2,442,579 | 10,039,000 | 2,008,806 | 8,209,990 |
| ចំណូលផ្សេងៗ | 25 | 1,013,402 | 4,165,082 | 297,852 | 1,217,321 |
| **ចំណូលប្រតិបត្តិការសរុប** | | 44,204,563 | 181,680,754 | 48,797,953 | 199,437,234 |
| ចំណាយនិយោជិត | 26 | (18,194,383) | (74,778,914) | (18,876,861) | (77,149,731) |
| រំលស់ | 27 | (5,156,979) | (21,195,184) | (4,578,840) | (18,713,719) |
| ចំណាយផ្សព្វផ្សាយ និងទីផ្សារ | 28 | (1,860,883) | (7,648,229) | (2,307,513) | (9,430,806) |
| ចំណាយទូទៅ និងរដ្ឋបាល | 29 | (8,510,159) | (34,976,753) | (8,191,823) | (33,479,981) |
| **ចំណាយប្រតិបត្តិការសរុប** | | (33,722,404) | (138,599,080) | (33,955,037) | (138,774,237) |
| **ចំណេញប្រតិបត្តិការមុនគិតខាតពីឱនភាពនៃតម្លៃ** | | 10,482,159 | 43,081,674 | 14,842,916 | 60,662,997 |
| សំវិធានធនបន្ថែមលើការខាតបង់ឥណទានរំពឹងទុក | 30 | (3,943,765) | (16,208,874) | (1,059,744) | (4,331,174) |
| **ចំណេញមុនដកពន្ធ** | | 6,538,394 | 26,872,800 | 13,783,172 | 56,331,823 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 20.3 | (1,446,891) | (5,946,722) | (3,257,647) | (13,314,003) |
| **ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | 5,091,503 | 20,926,078 | 10,525,525 | 43,017,820 |
| **លទ្ធផលលម្អិតផ្សេងៗ ៖** | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (4,989,433) | - | 6,394,481 |
| **ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | 5,091,503 | 15,936,645 | 10,525,525 | 49,412,301 |
| **ចំណេញសុទ្ធត្រូវបែងចែកជូន ៖** | | | | | |
| ភាគទុនិករបស់ធនាគារ | | 5,156,903 | 16,205,439 | 10,525,525 | 49,412,301 |
| ភាគហ៊ុនអប្បភាគ | | (65,400) | (268,794) | - | - |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | 5,091,503 | 15,936,645 | 10,525,525 | 49,412,301 |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# របាយការណ៍បម្រែបម្រួលមូលធនរួម

*(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

## បែងចែកជូនភាគទុនិករបស់ធនាគារ

| | ដើមទុន | | ទុនបម្រុងផ្សេងៗ | | ទុនបម្រុងតាមបទប្បញ្ញត្តិ | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2023 | 75,000,000 | 300,765,000 | 25,490,274 | 103,923,847 | 13,044,620 | 53,120,272 |
| **ប្រតិបត្តិការត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន** | | | | | | |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | 4,693,773 | 19,291,407 |
| **លទ្ធផលលម្អិតសរុប** | | | | | | |
| ប្រាក់ចំណេញ/(ខាត)សុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | - | - |
| លទ្ធផលលម្អិតផ្សេងៗ - លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023** | 75,000,000 | 300,765,000 | 25,490,274 | 103,923,847 | 17,738,393 | 72,411,679 |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2022 (មិនរងសវនកម្ម) | 75,000,000 | 300,765,000 | 25,490,274 | 103,923,847 | 7,679,453 | 31,192,834 |
| **ប្រតិបត្តិការត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន** | | | | | | |
| អប្បភាគភាគកម្ម (មិនរងសវនកម្ម) | - | - | - | - | - | - |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុង តាមបទប្បញ្ញត្តិ (មិនរងសវនកម្ម) | - | - | - | - | 5,365,167 | 21,927,438 |
| **លទ្ធផលលម្អិតសរុប** | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ (មិនរងសវនកម្ម) | - | - | - | - | - | - |
| លទ្ធផលលម្អិតផ្សេងៗ - លម្អៀងពីការប្តូររូបិយប័ណ្ណ (មិនរងសវនកម្ម) | - | - | - | - | - | - |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 (មិនរងសវនកម្ម)** | 75,000,000 | 300,765,000 | 25,490,274 | 103,923,847 | 13,044,620 | 53,120,272 |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

| ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | សរុប | | អប្បភាគភាគកម្ម | | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | សរុប | |
|---|---|---|---|---|---|---|---|---|---|
| ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) |
| 38,356,081 | 156,200,517 | 11,325,508 | 151,890,975 | 625,335,144 | 510,000 | 2,040,000 | 59,670 | 152,400,975 | 627,434,814 |
| (4,693,773) | (19,291,407) | - | - | - | - | - | - | - | - |
| 5,156,903 | 21,194,871 | - | 5,156,903 | 21,194,871 | (65,400) | (268,794) | - | 5,091,503 | 20,926,077 |
| - | - | (4,989,433) | - | (4,989,433) | - | - | (14,685) | - | (5,004,118) |
| 38,819,211 | 158,103,981 | 6,336,075 | 157,047,878 | 641,540,582 | 444,600 | 1,771,206 | 44,985 | 157,492,478 | 643,356,773 |
| 33,195,723 | 135,110,135 | 4,931,027 | 141,365,450 | 575,922,843 | - | - | - | 141,365,450 | 575,922,843 |
| - | - | - | - | - | 510,000 | 2,040,000 | - | 510,000 | 2,040,000 |
| (5,365,167) | (21,927,438) | - | - | - | - | - | - | - | - |
| 10,525,525 | 43,017,820 | - | 10,525,525 | 43,017,820 | - | - | - | 10,525,525 | 43,017,820 |
| - | - | 6,394,481 | - | 6,394,481 | - | - | 59,670 | - | 6,454,151 |
| 38,356,081 | 156,200,517 | 11,325,508 | 151,890,975 | 625,335,144 | 510,000 | 2,040,000 | 59,670 | 152,400,975 | 627,434,814 |

# របាយការណ៍លំហូរទឹកប្រាក់រួម

*(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

| | | ឆ្នាំ2023 | | ឆ្នាំ2022 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) |
| | | | | (មិនរងសវនកម្ម) | |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណេញមុនដកពន្ធ | | 6,538,394 | 26,872,800 | 13,783,172 | 56,331,823 |
| ការធ្វើនិយ័តកម្មទៅលើ៖ | | | | | |
| ចំណូលការប្រាក់ | | (75,875,904) | (311,849,965) | (73,954,309) | (302,251,261) |
| ចំណាយការប្រាក់ | | 35,127,322 | 144,373,293 | 27,463,014 | 112,241,338 |
| រំលស់ | 27 | 5,156,979 | 21,195,184 | 4,578,840 | 18,713,719 |
| សំវិធានធនលើការខាតបង់ឥណទានរំពឹងទុកខាតលើ៖ | 30 | 3,943,765 | 16,208,874 | 1,059,744 | 4,331,173 |
| ការលុបចោលលើទ្រព្យ និងបរិក្ខារនិងទ្រព្យអរូបី | 12,14 | 51,496 | 211,649 | 19,790 | 80,882 |
| ការបញ្ចប់ភតិសន្យាមុនកាលកំណត់ | 11,18 | 13,510 | 55,526 | 41,723 | 170,522 |
| ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ | 12 | (43,398) | (178,366) | (33,230) | (135,811) |
| | | (25,087,836) | (103,111,005) | (27,041,256) | (110,517,615) |
| បម្រែបម្រួលលើទ្រព្យសកម្មប្រតិបត្តិការនិងបំណុល៖ | | | | | |
| បញ្ញើនៅស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | | (3,117,619) | (12,813,414) | 1,161,192 | 4,745,792 |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិ | | (5,935,944) | (24,396,730) | (6,701,228) | (27,387,919) |
| ឥណទាន និងបុរេប្រទានទៅអតិថិជន | | (4,884,843) | (20,076,705) | (64,800,317) | (264,838,895) |
| ទ្រព្យសកម្មផ្សេងៗ | | 65,930 | 270,972 | (1,116,470) | (4,563,013) |
| បញ្ញើពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | | 8,361,393 | 34,365,325 | (16,501,422) | (67,441,312) |
| បញ្ញើពីអតិថិជន | | 77,444,224 | 318,295,761 | 102,882,390 | 420,480,328 |
| បំណុលផ្សេងៗ | | (670,276) | (2,754,835) | (115,157) | (470,647) |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការ** | | 46,175,029 | 189,779,369 | (12,232,268) | (49,993,281) |
| ការប្រាក់ទទួលបាន | | 75,337,974 | 309,639,073 | 72,312,832 | 295,542,544 |
| ការប្រាក់បានបង់ | | (28,342,049) | (116,485,820) | (23,753,070) | (97,078,797) |
| ពន្ធលើប្រាក់ចំណេញដែលបានបង់ | 20.1 | (1,944,593) | (7,992,277) | (2,789,751) | (11,401,712) |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការសុទ្ធ** | | 91,226,361 | 374,940,345 | 33,537,743 | 137,068,754 |

# របាយការណ៍លំហូរទឹកប្រាក់រួម

*(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

| | | ឆ្នាំ2023 | | ឆ្នាំ2022 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.4.3) |
| | | | | (មិនរងសវនកម្ម) | |
| **សកម្មភាពវិនិយោគ** | | | | | |
| ការទិញនេះ | | | | | |
| ទ្រព្យ និងបរិក្ខារ | 12 | (1,574,003) | (6,469,152) | (4,380,843) | (17,904,505) |
| ទ្រព្យអរូបី | 14 | (312,717) | (1,285,267) | (578,940) | (2,366,128) |
| ចំណូលពីការលក់ទ្រព្យ និងបរិក្ខារ | 12 | 43,398 | 178,366 | 33,230 | 135,811 |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | (1,843,322) | (7,576,053) | (4,926,553) | (20,134,822) |
| **សកម្មភាពហិរញ្ញវត្ថុ** | | | | | |
| សាច់ប្រាក់ដើមទូទាត់លើបំណុលភតិសន្យា | 18 | (2,336,935) | (9,604,803) | (2,176,003) | (8,893,324) |
| សាច់ប្រាក់បានពីកម្ចី | 17ក | 14,728,065 | 60,532,347 | 36,225,956 | 148,055,482 |
| ការទូទាត់សងនៃកម្ចី | 17ក | (38,270,864) | (157,293,251) | (42,127,504) | (172,175,109) |
| សាច់ប្រាក់បានពីអនុបំណុល | 17ខ | 4,000,000 | 16,440,000 | (503,671) | (2,058,503) |
| ការទូទាត់សងនៃអនុបំណុល | 17ខ | (4,517,320) | (18,566,185) | - | - |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញវត្ថុ** | | (26,397,054) | (108,491,892) | (8,581,222) | (35,071,454) |
| **ការកើនឡើងសុទ្ធ ក្នុងសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | 62,985,985 | 258,872,400 | 20,029,968 | 81,862,478 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី1 ខែមករា | | 73,940,164 | 304,411,655 | 53,910,196 | 219,630,139 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (3,940,737) | - | 2,919,038 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី31 ខែធ្នូ** | 5 | 136,926,149 | 559,343,318 | 73,940,164 | 304,411,655 |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុដោយឡែក *(នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

| | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.4.3) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | 5 | 136,796,268 | 558,812,754 | 72,913,894 | 300,186,502 |
| ប្រាក់បញ្ញើនៅស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | 6 | 3,515,843 | 14,362,218 | 262,397 | 1,080,288 |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិ | 7 | 48,380,729 | 197,635,278 | 42,591,664 | 175,349,881 |
| ឥណទាន និងបុរេប្រទានទៅអតិថិជន | 8 | 582,247,771 | 2,378,482,145 | 582,611,307 | 2,398,610,751 |
| ការវិនិយោគលើបុត្រសម្ព័ន្ធធនាគារ | 9 | 490,000 | 2,001,650 | 490,000 | 2,017,330 |
| ទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្របក្នុងលទ្ធភាពលម្អិតផ្សេងៗ | | 42,500 | 173,613 | 42,500 | 174,973 |
| ទ្រព្យសកម្មរក្សាទុកសម្រាប់លក់ | 10 | 1,800,000 | 7,353,000 | - | - |
| ទ្រព្យសកម្មផ្សេងៗ | 11 | 2,681,441 | 10,953,686 | 2,753,675 | 11,336,880 |
| ទ្រព្យ និងបរិក្ខារ | 12 | 6,128,215 | 25,033,758 | 7,209,764 | 29,682,598 |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | 13 | 9,846,490 | 40,222,912 | 10,370,446 | 42,695,126 |
| ទ្រព្យអរូបី | 14 | 1,519,903 | 6,208,804 | 1,833,235 | 7,547,428 |
| **ទ្រព្យសកម្មសរុប** | | 793,449,160 | 3,241,239,818 | 721,078,882 | 2,968,681,757 |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | 15 | 63,870,907 | 260,912,655 | 54,790,080 | 225,570,759 |
| ប្រាក់បញ្ញើពីអតិថិជន | 16 | 537,155,906 | 2,194,281,876 | 453,088,610 | 1,865,365,807 |
| ប្រាក់កម្ចី | 17ក | 16,748,255 | 68,416,622 | 40,675,993 | 167,463,063 |
| បំណុលភតិសន្យា | 18 | 9,500,667 | 38,810,225 | 9,860,478 | 40,595,588 |
| បំណុលផ្សេងៗ | 19 | 2,997,253 | 12,243,777 | 3,704,681 | 15,252,172 |
| បំណុលពន្ធលើប្រាក់ចំណេញ | 20.1 | 67,809 | 277,000 | 1,194,668 | 4,918,448 |
| ពន្ធពន្យារជាបំណុល | 20.2 | 1,433,791 | 5,857,036 | 781,315 | 3,216,674 |
| អនុបំណុល | 17ខ | 4,588,881 | 18,745,579 | 5,092,082 | 20,964,102 |
| **បំណុលសរុប** | | 636,363,469 | 2,599,544,770 | 569,187,907 | 2,343,346,613 |

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដោយឡែក *(នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

| | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) |
| **មូលធនរបស់ភាគទុនិក** | | | | | |
| ដើមទុន | 21.1 | 75,000,000 | 300,765,000 | 75,000,000 | 300,765,000 |
| ទុនបម្រុងផ្សេងៗ | 21.2 | 25,490,274 | 103,923,847 | 25,490,274 | 103,923,847 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 21.3 | 17,738,393 | 72,411,679 | 13,044,620 | 53,120,272 |
| ប្រាក់ចំណេញរក្សាទុក | | 38,857,024 | 158,259,393 | 38,356,081 | 156,200,517 |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | - | 6,335,129 | - | 11,325,508 |
| **មូលធនសរុប** | | 157,085,691 | 641,695,048 | 151,890,975 | 625,335,144 |
| **បំណុលនិងមូលធនសរុប** | | 793,449,160 | 3,241,239,818 | 721,078,882 | 2,968,681,757 |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗដោយឡែក

*(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

| | | ឆ្នាំ2023 | | ឆ្នាំ2022 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.4.3) |
| ចំណូលការប្រាក់ | 22 | 75,875,904 | 311,849,965 | 73,954,309 | 302,251,261 |
| ចំណាយការប្រាក់ | 23 | (35,165,193) | (144,528,943) | (27,463,014) | (112,241,338) |
| **ចំណូលការប្រាក់សុទ្ធ** | | 40,710,711 | 167,321,022 | 46,491,295 | 190,009,923 |
| ចំណូលសេវា និងកម្រៃជើងសារសុទ្ធ | 24 | 2,442,699 | 10,039,493 | 2,008,806 | 8,209,990 |
| ចំណូលផ្សេងៗ | 25 | 989,207 | 4,065,641 | 297,852 | 1,217,321 |
| **ចំណូលប្រតិបត្តិការសរុប** | | 44,142,617 | 181,426,156 | 48,797,953 | 199,437,234 |
| ចំណាយនិយោជិត | 26 | (18,167,160) | (74,667,028) | (18,876,861) | (77,149,731) |
| រំលស់ | 27 | (5,140,002) | (21,125,408) | (4,578,840) | (18,713,719) |
| ចំណាយផ្សព្វផ្សាយ និងទីផ្សារ | 28 | (1,838,868) | (7,557,747) | (2,307,513) | (9,430,806) |
| ចំណាយទូទៅ និងរដ្ឋបាល | 29 | (8,389,306) | (34,480,048) | (8,191,823) | (33,479,981) |
| **ចំណាយប្រតិបត្តិការសរុប** | | (33,535,336) | (137,830,231) | (33,955,037) | (138,774,237) |
| **ចំណេញប្រតិបត្តិការមុនគិតខាតពីឱនភាពនៃតម្លៃ** | | 10,607,281 | 43,595,925 | 14,842,916 | 60,662,997 |
| សំវិធានធនបន្ថែមសម្រាប់ការខាតបង់ឥណទានរំពឹងទុក | 30 | (3,943,765) | (16,208,874) | (1,059,744) | (4,331,174) |
| **ចំណេញមុនដកពន្ធ** | | 6,663,516 | 27,387,051 | 13,783,172 | 56,331,823 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 20.3 | (1,468,800) | (6,036,768) | (3,257,647) | (13,314,003) |
| **ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | 5,194,716 | 21,350,283 | 10,525,525 | 43,017,820 |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (4,990,379) | - | 6,394,481 |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | 5,194,716 | 16,359,904 | 10,525,525 | 49,412,301 |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# របាយការណ៍បម្រែបម្រួលមូលធន ដោយឡែក *(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

| | ដើមទុន | | ទុនបម្រុងផ្សេងៗ | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ 2.4.3) |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2023 | 75,000,000 | 300,765,000 | 25,490,274 | 103,923,847 | 13,044,620 | 53,120,272 | 38,356,081 | 156,200,517 | 11,325,508 | 151,890,975 | 625,335,144 |
| **ប្រតិបត្តិការត្រូវបានទទួលស្គាល់ដោយផ្ទាល់** | | | | | | | | | | | |
| នៅក្នុងមូលធនការផ្ទេរពី ប្រាក់ចំណេញរក្សាទុកទៅ ទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | 4,693,773 | 19,291,407 | (4,693,773) | (19,291,407) | - | - | - |
| **លទ្ធផលលម្អិតសរុប** | | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ ការិយបរិច្ឆេទ | - | - | - | - | - | - | 5,194,716 | 21,350,283 | - | 5,194,716 | 21,350,283 |
| លទ្ធផលលម្អិតផ្សេងៗ - លម្អៀង ពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | (4,990,379) | - | (4,990,379) |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023** | 75,000,000 | 300,765,000 | 25,490,274 | 103,923,847 | 17,738,393 | 72,411,679 | 38,857,024 | 158,259,393 | 6,335,129 | 157,085,691 | 641,695,048 |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2022 | 75,000,000 | 300,765,000 | 25,490,274 | 103,923,847 | 7,679,453 | 31,192,834 | 33,195,723 | 135,110,135 | 4,931,027 | 141,365,450 | 575,922,843 |
| **ប្រតិបត្តិការត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន** | | | | | | | | | | | |
| ការផ្ទេរពីប្រាក់ចំណេញ រក្សាទុកទៅទុនបម្រុង តាមបទប្បញ្ញត្តិ | - | - | - | - | 5,365,167 | 21,927,438 | (5,365,167) | (21,927,438) | - | - | - |
| **លទ្ធផលលម្អិតសរុប** | | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ ការិយបរិច្ឆេទ | - | - | - | - | - | - | 10,525,525 | 43,017,820 | - | 10,525,525 | 43,017,820 |
| លទ្ធផលលម្អិតផ្សេងៗ - លម្អៀង ពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | 6,394,481 | - | 6,394,481 |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022** | 75,000,000 | 300,765,000 | 25,490,274 | 103,923,847 | 13,044,620 | 53,120,272 | 38,356,081 | 156,200,517 | 11,325,508 | 151,890,975 | 625,335,144 |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# របាយការណ៍លំហូរទឹកប្រាក់ដោយឡែក

*(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

| | | ឆ្នាំ2023 | | ឆ្នាំ2022 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.4.3) |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណេញមុនដកពន្ធ | | 6,663,516 | 27,387,051 | 13,783,172 | 56,331,823 |
| ការធ្វើនិយ័តកម្មទៅលើ៖ | | | | | |
| ចំណូលការប្រាក់ | | (75,875,904) | (311,849,965) | (73,954,309) | (302,251,261) |
| ចំណាយការប្រាក់ | | 35,165,193 | 144,528,943 | 27,463,014 | 112,241,338 |
| រំលស់ | 27 | 5,140,002 | 21,125,408 | 4,578,840 | 18,713,719 |
| សំវិធានធនលើការខាតបង់ឥណទានរំពឹងទុក | 30 | 3,943,765 | 16,208,874 | 1,059,744 | 4,331,173 |
| ខាតលើ៖ | | | | | |
| ការលុបចោលលើទ្រព្យ និងបរិក្ខារនិងទ្រព្យអរូបី | 12,14 | 51,496 | 211,650 | 19,790 | 80,882 |
| ការបញ្ចប់ភតិសន្យាមុនកាលកំណត់ | 11,18 | 13,510 | 55,526 | 41,723 | 170,522 |
| ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ | 12 | (43,398) | (178,366) | (33,230) | (135,811) |
| | | (24,941,820) | (102,510,879) | (27,041,256) | (110,517,615) |
| បម្រែបម្រួលលើទ្រព្យសកម្មប្រតិបត្តិការនិងបំណុល៖ | | | | | |
| ប្រាក់បញ្ញើនៅស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | | (3,117,619) | (12,813,414) | 651,192 | 2,661,422 |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិ | | (5,789,065) | (23,793,057) | (6,701,228) | (27,387,919) |
| ឥណទាន និងបុរេប្រទានទៅអតិថិជន | | (4,884,843) | (20,076,705) | (64,800,317) | (264,838,895) |
| ទ្រព្យសកម្មផ្សេងៗ | | 72,234 | 296,882 | (1,116,470) | (4,563,013) |
| បញ្ញើពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | | 8,361,393 | 34,365,325 | (16,501,422) | (67,441,312) |
| បញ្ញើពីអតិថិជន | | 78,226,593 | 321,511,297 | 102,882,390 | 420,480,328 |
| បំណុលផ្សេងៗ | | (771,160) | (3,169,467) | (115,157) | (470,647) |
| **សាច់ប្រាក់សុទ្ធទទួលបានពីប្រតិបត្តិការ** | | 47,155,713 | 193,809,982 | (12,742,268) | (52,077,651) |
| ការប្រាក់ទទួលបាន | | 75,337,974 | 309,639,073 | 72,312,832 | 295,542,544 |
| ការប្រាក់បានបង់ | | (28,379,920) | (116,641,471) | (23,753,070) | (97,078,797) |
| ពន្ធលើប្រាក់ចំណេញដែលបានបង់ | 20.1 | (1,943,183) | (7,986,482) | (2,789,751) | (11,401,712) |
| **សាច់ប្រាក់សុទ្ធទទួលបានពីប្រតិបត្តិការសុទ្ធ** | | 92,170,584 | 378,821,102 | 33,027,743 | 134,984,384 |

# របាយការណ៍លំហូរទឹកប្រាក់ដោយឡែក *(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

| | | ឆ្នាំ2023 | | ឆ្នាំ2022 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.4.3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ 2.4.3) |
| **សកម្មភាពវិនិយោគ** | | | | | |
| ការទិញនេះ | | | | | |
| ទ្រព្យ និងបរិក្ខារ | 12 | (1,536,833) | (6,316,384) | (4,380,843) | (17,904,505) |
| ទ្រព្យអរូបី | 14 | (294,110) | (1,208,792) | (578,940) | (2,366,128) |
| ចំណូលពីការលក់ទ្រព្យ និងបរិក្ខារ | 12 | 43,398 | 178,366 | 33,230 | 135,811 |
| ការវិនិយោគលើបុត្រសម្ព័ន្ធធនាគារ | 9 | - | - | (490,000) | (2,002,630) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | (1,787,545) | (7,346,810) | (5,416,553) | (22,137,452) |
| **សកម្មភាពហិរញ្ញវត្ថុ** | | | | | |
| សាច់ប្រាក់ដើមទូទាត់លើបំណុលភតិសន្យា | 18 | (2,336,935) | (9,604,803) | (2,176,003) | (8,893,324) |
| សាច់ប្រាក់បានពីកម្ចី | 17ក | 14,728,065 | 60,532,347 | 36,225,956 | 148,055,482 |
| ការទូទាត់សងនៃកម្ចី | 17ក | (38,270,864) | (157,293,251) | (42,127,504) | (172,175,109) |
| សាច់ប្រាក់បានពីអនុបំណុល | 17ខ | 4,000,000 | 16,440,000 | (503,671) | (2,058,503) |
| ការទូទាត់សងនៃអនុបំណុល | 17ខ | (4,517,320) | (18,566,185) | - | - |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញវត្ថុ** | | (26,397,054) | (108,491,892) | (8,581,222) | (35,071,454) |
| **ការកើនឡើងសុទ្ធ ក្នុងសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | 63,985,985 | 262,982,400 | 19,029,968 | 77,775,478 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី1 ខែមករា | | 72,940,164 | 300,294,655 | 53,910,196 | 219,630,139 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (3,933,737) | - | 2,889,038 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី31 ខែធ្នូ** | 5 | 136,926,149 | 559,343,318 | 72,940,164 | 300,294,655 |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ *(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

## 1. ព័ត៌មានទូទៅ

### ធនាគារ

ធនាគារ បានបង្កើតឡើងនៅថ្ងៃទី26 ខែមិថុនា ឆ្នាំ2009 ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាស្តីពីសហគ្រាសពាណិជ្ជកម្ម និងទទួលបានអាជ្ញាប័ណ្ណស្ថិតក្រោមបទប្បញ្ញត្តិនៃធនាគារជាតិនៃកម្ពុជា។ ធនាគារបានទទួលអាជ្ញាប័ណ្ណថ្មីមិនមានកាលកំណត់ ដែលចេញដោយធនាគារជាតិនៃកម្ពុជានៅថ្ងៃទី4 ខែមីនា ឆ្នាំ2015។ ធនាគារ ធ្វើការផ្តល់សេវាកម្ម ប្រតិបត្តិការធនាគារពេញលេញ និងសេវាកម្មហិរញ្ញវត្ថុពាក់ព័ន្ធជាច្រើនទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលអនុលោមតាមលេខចុះបញ្ជី 5915/09E ដែលចេញដោយក្រសួងពាណិជ្ជកម្ម។

នៅថ្ងៃទី11 ខែកុម្ភៈ ឆ្នាំ2016 ធនាគារបានទទួលលេខចុះបញ្ជីថ្មី 00000292 ពីក្រសួងពាណិជ្ជកម្ម។

ពុំមានការផ្លាស់ប្តូរជាសារវន្ត នៅក្នុងសកម្មភាពចម្បងរបស់ធនាគារក្នុងអំឡុងការិយបរិច្ឆេទនេះទេ។

ស្នាក់ការចុះបញ្ជីរបស់ធនាគារមានទីតាំងនៅអគារលេខ 27DEFG មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ធនាគារមាននិយោជិតចំនួន 1,755នាក់ (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022៖ 1,966នាក់)។

### សម្ព័ន្ធធនាគារ

ក្នុងការិយបរិច្ឆេទ 2022 ធនាគារបានវិនិយោគមូលធន 49% នៅហ្វីលីព គ្រាសធី (ខេមបូឌា) ឯ.ក ជាក្រុមហ៊ុនថ្មីដែលបានបង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី25 ខែកក្កដា ឆ្នាំ2022 នៅក្រោមច្បាប់កម្ពុជាស្តីពីសហគ្រាសពាណិជ្ជកម្ម និងបានទទួលអាជ្ញាប័ណ្ណពីនិយតករបរធនបាលកិច្ចនៅថ្ងៃទី15 ខែធ្នូ ឆ្នាំ2022។

សកម្មភាពចម្បងរបស់ហ្វីលីព គ្រាសធី (ខេមបូឌា) ឯ.ក គឺផ្តល់សេវាកម្មបរធនបាលកិច្ច រួមមានការកាន់កាប់អចលនទ្រព្យសម្រាប់បរធនបាលកិច្ចពាណិជ្ជកម្ម បរធនបាលកិច្ចសង្គម និងបរធនបាលកិច្ចបុគ្គល និងបរធនបាលកិច្ចផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## 2. មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារនិងធនាគារត្រូវបាន រៀបចំឡើងដោយពឹងផ្អែកទៅលើមូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រ លើកលែងតែទ្រព្យសកម្ម និងទ្រព្យអកម្មហិរញ្ញវត្ថុ ដែលបានវាស់វែងទៅតាមតម្លៃសមស្រប។

### 2.1. មូលដ្ឋានអនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានរៀបចំឡើងដោយផ្អែកតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក")។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ *(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

ព័ត៌មានលម្អិតទាក់ទងនឹងគោលនយោបាយគណនេយ្យរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានបង្ហាញ នៅក្នុងកំណត់សម្គាល់ 3។

របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានអនុញ្ញាតឲ្យចេញដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី29 ខែមីនា ឆ្នាំ2024។

## 2.2. មូលដ្ឋាននៃការរួមបញ្ចូលគ្នា

ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាអង្គភាពដែលគ្រប់គ្រងដោយធនាគារ។ អត្ថិភាពនៃការគ្រប់គ្រងកើតមាននៅពេលដែលធនាគារមានអំណាច (ដោយផ្ទាល់ ឬដោយប្រយោល) ក្នុងការគ្រប់គ្រងគោលនយោបាយហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់អង្គភាព ដើម្បីទទួលបាននូវផលប្រយោជន៍ពីសកម្មភាពទាំងនោះ។ របាយការណ៍ហិរញ្ញវត្ថុនៃសម្ព័ន្ធធនាគារ ត្រូវបានរួមបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមចាប់ពីកាលបរិច្ឆេទដែលការគ្រប់គ្រងបានចាប់ផ្តើម រហូតដល់កាលបរិច្ឆេទដែលការគ្រប់គ្រងនោះត្រូវបានបញ្ឈប់។ ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវរួមបញ្ចូល ដោយប្រើវិធីសាស្ត្រគណនេយ្យទាក់ទិននឹងការទិញ ("Acquisition method of accounting")។

ក្រោមវិធីសាស្ត្រគណនេយ្យទាក់ទិននឹងការទិញ លទ្ធផលពីការទិញ ឬលក់សម្ព័ន្ធធនាគារក្នុងអំឡុងការិយបរិច្ឆេទ ត្រូវបានរាប់បញ្ចូលចាប់ពីកាលបរិច្ឆេទដែលការគ្រប់គ្រងបានចាប់ផ្តើម រហូតដល់កាលបរិច្ឆេទដែលការគ្រប់គ្រងនោះត្រូវបានបញ្ឈប់។ នៅកាលបរិច្ឆេទនៃការទិញ តម្លៃសមស្របនៃទ្រព្យសកម្មសុទ្ធរបស់សម្ព័ន្ធធនាគារ ត្រូវបានកំណត់ ហើយតម្លៃនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម របស់សម្ព័ន្ធធនាគារនិងធនាគារ។

ប្រតិបត្តិការ និងសមតុល្យរួម និងរាល់ចំណេញ ឬខាតមិនទាន់កើតឡើងជាក់ស្តែង ដែលកើតពីប្រតិបត្តិការអន្តររួម ត្រូវបានលុបចោលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម។ ចំណេញមិនទាន់កើតឡើងជាក់ស្តែង ដែលបានកើតឡើងពីប្រតិបត្តិការអន្តររួមត្រូវបានលុបចេញត្រឹមចំនួននៃភាគកម្មរបស់ធនាគារនៅក្នុងសម្ព័ន្ធធនាគារ។ ការខាតបង់មិនទាន់កើតឡើងជាក់ស្តែង ត្រូវបានលុបចោលតាមរបៀបដូចគ្នានឹងចំណេញ មិនទាន់កើតឡើងជាក់ស្តែងដែរ ប៉ុន្តែការលុបចោលនេះ ត្រូវធ្វើឡើងត្រឹមកម្រិតដែល វាមិនមានភស្តុតាងណាមួយថាមានឱនភាពនៃតម្លៃ។

ទោះបីជាធនាគារបានកាន់កាប់សិទ្ធិចំនួន 49% នៃសិទ្ធិបោះឆ្នោតក្នុងហ្វីលីពត្រាស់ធី (កម្ពុជា) ខូអិលធីឌី ក៏ដោយ ធនាគារមានសិទ្ធិគ្រប់គ្រង និងមានឥទ្ធិពលជាសារវន្ត លើប្រតិបត្តិការរបស់ហ្វីលីព ត្រាសធី (ខេមបូឌា) ឯ.ក ដូច្នេះហើយ ហ្វីលីព ត្រាសធី (ខេមបូឌា) ឯ.ក ត្រូវបានចាត់ទុកថាជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ ហ្វីលីព ភីអិលស៊ី។

## 2.3. ការិយបរិច្ឆេទ

ការិយបរិច្ឆេទរបស់សម្ព័ន្ធធនាគារនិងធនាគារចាប់ផ្តើមនៅថ្ងៃទី1 ខែមករា និងបញ្ចប់នៅថ្ងៃទី31 ខែធ្នូ។

## 2.4. ការប្តូររូបិយប័ណ្ណបរទេស

រូបិយប័ណ្ណជាតិរបស់កម្ពុជា គឺប្រាក់រៀល ("រៀល")។ ទោះយ៉ាងណាប្រតិបត្តិការអាជីវកម្មរបស់សម្ព័ន្ធធនាគារនិងធនាគារ រក្សាកំណត់ត្រាគណនេយ្យរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិក ("ដុល្លារអាមេរិក") គណៈគ្រប់គ្រង បានកំណត់ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណមុខងាររបស់សម្ព័ន្ធធនាគារនិងធនាគារ ព្រោះវាឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចនៃព្រឹត្តិការណ៍មូលដ្ឋាន និងកាលៈទេសៈរបស់សម្ព័ន្ធធនាគារនិងធនាគារ។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)

**2.4.1. រូបិយប័ណ្ណបង្ហាញ**

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិកដែលជារូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ការបង្ហាញរបស់សម្ព័ន្ធធនាគារនិងធនាគារ។

**2.4.2. ប្រតិបត្តិការ និងសមតុល្យ**

ប្រតិបត្តិការ ជារូបិយប័ណ្ណផ្សេងទៀតក្រៅពីដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការ។ ទ្រព្យសកម្ម និងទ្រព្យអកម្មរូបិយវត្ថុដែលជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិកដែលមាននាកាលបរិច្ឆេទរបាយការណ៍ ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនោះ។ លម្អៀងកើតពីការប្តូររូបិយប័ណ្ណត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬ ខាត។

**2.4.3. ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល**

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់សម្ព័ន្ធធនាគារនិងធនាគារ។ ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល បានធ្វើបំពេញតាមលក្ខខណ្ឌតម្រូវនៃការបង្ហាញព័ត៌មានដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ហើយការប្តូររូបិយប័ណ្ណនេះធ្វើឡើងដោយអនុលោមទៅតាម ស.គ.អ.ក 21 – ឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូររូបិយប័ណ្ណបរទេស។

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរតាមអត្រានាកាលបរិច្ឆេទរាយការណ៍ ហើយដើមទុន និងគណនីមូលធនផ្សេងៗត្រូវបានប្តូរតាមអត្រាប្រវត្តិសាស្រ្ត។ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ និងរបាយការណ៍លំហូរទឹកប្រាក់ ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើប្រាស់អត្រាមធ្យមនៅក្នុងការិយបរិច្ឆេទ ដែលអត្រានេះត្រូវបានចាត់ទុកថាមានកម្រិតប្រហាក់ប្រហែលទៅនឹងអត្រាប្តូររូបិយប័ណ្ណនាថ្ងៃប្រតិបត្តិការ ពីព្រោះអត្រានេះមិនមានការប្រែប្រួលជាសារវន្តនៅក្នុងការិយបរិច្ឆេទ។ ភាពខុសគ្នាដែលកើតឡើងពីការប្តូររូបិយប័ណ្ណត្រូវបានទទួលស្គាល់ជា "ទុនបម្រុងពីការប្តូររូបិយប័ណ្ណ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

សម្ព័ន្ធធនាគារ និងធនាគារប្រើប្រាស់អត្រាប្តូររូបិយប័ណ្ណដូចខាងក្រោម៖

| | | អត្រានាកាលបរិច្ឆេទរាយការណ៍ | អត្រាជាមធ្យម |
|---|---|---|---|
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | 1 ដុល្លារអាមេរិក = | 4,085 រៀល | 4,110 រៀល |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | 1 ដុល្លារអាមេរិក = | 4,117 រៀល | 4,087 រៀល |

ការប្តូររូបិយប័ណ្ណសាមញ្ញនេះ មិនគួរត្រូវបានយកមកបកស្រាយថា តួលេខប្រាក់រៀលនេះ ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ឬគួរត្រូវបានប្តូរជាប្រាក់ដុល្លារអាមេរិក ឬនឹងត្រូវបានប្តូរជាប្រាក់ដុល្លារអាមេរិក នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

## 3. គោលនយោបាយគណនេយ្យសារវន្ត

គោលនយោបាយគណនេយ្យ ដែលបានអនុវត្ត គឺមានសង្គតិភាពជាមួយនឹងគោលនយោបាយគណនេយ្យនៃការិយបរិច្ឆេទហិរញ្ញវត្ថុមុន លើកលែងតែសម្ព័ន្ធធនាគារនិងធនាគារបានអនុវត្ត នូវសេចក្តីប្រកាសគណនេយ្យថ្មីចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2023ខាងក្រោម។

**ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យសារវន្ត**

**(i) ពន្ធពន្យារពាក់ព័ន្ធនឹងទ្រព្យសកម្ម និងបំណុលដែលកើតចេញពីប្រតិបត្តិការតែមួយ**

សម្ព័ន្ធធនាគារនិងធនាគារបានអនុវត្ត ***ពន្ធពន្យារពាក់ព័ន្ធនឹងទ្រព្យសកម្ម និងបំណុលដែលកើតចេញពីប្រតិបត្តិការតែមួយ (វិសោធនកម្មលើ CIAS 12)*** ចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2023។ វិសោធនកម្មនេះ បង្រួមវិសាលភាពលើការលើកលែងការទទួលស្គាល់ជាលើកដំបូង ដោយមិនរាប់បញ្ចូលនូវប្រតិបត្តិការដែលបង្កើតឲ្យមានភាពខុសគ្នាបណ្តោះអាសន្ន ដែលមានតម្លៃស្មើគ្នា និងកាត់កងគ្នាបាន ឧទាហរណ៍ដូចជាភតិសន្យា។ ចំពោះប្រតិបត្តិការភតិសន្យា ពន្ធពន្យារជាទ្រព្យសកម្ម និងបំណុលដែលពាក់ព័ន្ធ នឹងត្រូវទទួលស្គាល់នៅដើមការិយបរិច្ឆេទមុនបង្អស់សម្រាប់ជាតួលេខប្រៀបធៀប ដែលផលប៉ះពាល់បង្គរនឹងត្រូវបានធ្វើនិយ័តកម្មទៅក្នុងគណនីប្រាក់ចំណេញរក្សាទុក ឬធាតុផ្សេងទៀតគណនីមូលធន នៃកាលបរិច្ឆេទនោះ។ សម្រាប់ប្រតិបត្តិការផ្សេងៗទៀត វិសោធនកម្មនេះ នឹងអនុវត្តចំពោះប្រតិបត្តិការដែលកើតឡើងបន្ទាប់ពីដើមការិយបរិច្ឆេទមុនបង្អស់ដែលបានបង្ហាញ។

សម្ព័ន្ធធនាគារនិងធនាគារ ពីមុនទទួលស្គាល់ពន្ធពន្យារដែលកើតចេញពីភតិសន្យាដោយប្រើប្រាស់វិធី "តភ្ជាប់គ្នា" ដែលមានលទ្ធផលស្រដៀងគ្នានឹងវិសោធនកម្មនេះ លើកលែងតែផលប៉ះពាល់លើតួលេខពន្ធពន្យារ ដែលបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ យោងលើវិសោធនកម្មនេះ សម្ព័ន្ធធនាគារនិងធនាគារ ទទួលស្គាល់ពន្ធពន្យារជាទ្រព្យសកម្ម ដែលពាក់ព័ន្ធនឹងបំណុលភតិសន្យា ដាច់ដោយឡែកពីពន្ធពន្យារជាបំណុល ដែលពាក់ព័ន្ធនឹងសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម។ ពុំមានផលប៉ះពាល់លើគណនីប្រាក់ចំណេញរក្សាទុកនាថ្ងៃទី1 ខែមករា ឆ្នាំ2022 ដែលបណ្តាលមកពីការអនុវត្តវិសោធនកម្មនេះទេ។

**(ii) ព័ត៌មានគោលនយោបាយគណនេយ្យសារវន្ត**

សម្ព័ន្ធធនាគារនិងធនាគារ ក៏អនុវត្តការបង្ហាញនៃគោលនយោបាយគណនេយ្យ ***(វិសោធនកម្មលើ CIAS 1 និងសេចក្តីថ្លែងការណ៍ CIFRS លេខ 2)*** ចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2023។ ទោះបីជាវិសោធនកម្មនេះ មិនមានការផ្លាស់ប្តូរគោលនយោបាយគណនេយ្យក៏ដោយ ក៏ប៉ុន្តែវាប៉ះពាល់ដល់ព័ត៌មានគោលនយោបាយ គណនេយ្យដែលត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

វិសោធនកម្មនេះ តម្រូវឲ្យបង្ហាញគោលនយោបាយគណនេយ្យដែលមានភាពជា "សារវន្ត" ជាជាង "ភាពសំខាន់"។ វិសោធនកម្មនេះ ក៏ណែនាំការប្រើប្រាស់ភាពជាសារវន្ត ក្នុងការបង្ហាញគោលនយោបាយគណនេយ្យ ដែលជួយដល់អង្គភាពឲ្យបង្ហាញនូវព័ត៌មានគោលនយោបាយគណនេយ្យដែលមានប្រយោជន៍ និងជាក់លាក់របស់ខ្លួនទៅកាន់អ្នកប្រើប្រាស់ដែលត្រូវយល់ពីព័ត៌មានផ្សេងៗក្នុងរបាយការណ៍ហិញ្ញវត្ថុ។

គណៈគ្រប់គ្រង បានត្រួតពិនិត្យគោលនយោបាយគណនេយ្យ និងធ្វើបច្ចុប្បន្នភាពព័ត៌មានដែលបានបង្ហាញក្នុង ***កំណត់សម្គាល់ 3 គោលនយោបាយ*** គណនេយ្យសារវន្ត (ឆ្នាំ2022៖ សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ) ដើម្បីឲ្យស្របតាមវិសោធនកម្មនេះ។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ *(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

## 3.1. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសាច់ប្រាក់ និងសមតុល្យនៅធនាគារ ប្រាក់បញ្ញើ និងការវិនិយោគ រយៈពេលខ្លី ដែលងាយស្រួលក្នុងការបម្លែងជាសាច់ប្រាក់បំផុត ជាមួយនឹងកាលកំណត់ដើមរយៈពេលបីខែ ឬតិចជាង នៅពេលទិញ រួមទាំងដែលអាចបម្លែងទៅជាចំនួននៃសាច់ប្រាក់ដែលបានសម្គាល់ និងដែលអាចប្រឈមនឹងហានិភ័យតិចតួចនៃការផ្លាស់ប្តូរតម្លៃ។

## 3.2. ប្រាក់បញ្ញើនៅស្ថាប័នហិរញ្ញវត្ថុផ្សេងៗ

ប្រាក់បញ្ញើនៅស្ថាប័នហិរញ្ញវត្ថុផ្សេងៗ រួមមានបញ្ញើមានកាលកំណត់ដែលមានបំណងកាន់កាប់រយៈពេលច្រើនជាង 3ខែ។ បញ្ញើត្រូវបានបង្ហាញនៅថ្លៃដើមរំលស់ ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពដក ឱនភាពនៃតម្លៃ សម្រាប់ចំនួនដែលមិនអាចប្រមូលបានទាំងឡាយ។

## 3.3. ប្រាក់តម្កល់តាមបទប្បញ្ញត្តិ

ប្រាក់តម្កល់តាមបទប្បញ្ញត្តិដែលមាននៅក្នុងសមតុល្យជាមួយធនាគារជាតិនៃកម្ពុជា ត្រូវបានរក្សាទុកដោយអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងត្រូវបានកំណត់ដោយអត្រានៃដើមទុនអប្បបរមា និងប្រាក់បញ្ញើរបស់អតិថិជន ដូចបានតម្រូវដោយធនាគារជាតិនៃកម្ពុជា។

## 3.4. ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

### 3.4.1. ការទទួលស្គាល់ និងការវាស់វែងដំបូង

សម្ព័ន្ធធនាគារនិងធនាគារទទួលស្គាល់ឥណទាន និងបុរេប្រទានដំបូងនៅថ្ងៃដែលឥណទាន និងបុរេប្រទានទាំងនោះត្រូវបានបង្កើតឡើង។ ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗទៀតទាំងអស់ ត្រូវបានទទួលស្គាល់នៅកាលបរិច្ឆេទដែលសម្ព័ន្ធធនាគារនិងធនាគារក្លាយជាភាគីមួយ ទៅតាមលក្ខខណ្ឌទាំងឡាយដែលមានចែងតាមកិច្ចសន្យានៃឧបករណ៍នោះ។

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដែលមិនវាស់វែងតាមតម្លៃសមស្រប បូកនឹងធាតុនៃទ្រព្យសកម្មដែលមិនវាស់វែងតាមរយៈចំណេញ ឬខាត (FVTPL) បូកនឹងថ្លៃដើមប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់ពីការទិញរហូតដល់ពេលទទួលបាន ឬ បោះផ្សាយ។

### 3.4.2. ការធ្វើចំណាត់ថ្នាក់

*ទ្រព្យសកម្មហិរញ្ញវត្ថុ*

នៅពេលទទួលស្គាល់លើកដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានចាត់ថ្នាក់ និងវាស់វែងនៅរំលស់ថ្លៃដើមសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុនៅតម្លៃសមស្របតាមចំណេញ ឬ ខាត (FVOCI) ឬ FVTPL។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ *(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងនៅរំលស់ថ្លៃដើម ប្រសិនបើទ្រព្យនោះមានលក្ខខណ្ឌដូចខាងក្រោម និងមិនបានកំណត់ជា FVTPL៖

- ទ្រព្យសកម្ម ត្រូវបានកាន់កាប់តាមគម្រូអាជីវកម្មដែលមានគោលបំណងក្នុងការកាន់កាប់ទ្រព្យដើម្បីប្រមូលលំហូរទឹកប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់ឲ្យមានការកើនឡើងនៃលំហូរទឹកប្រាក់ដែលជា SPPI តាមកាលបរិច្ឆេទជាក់លាក់។

ឧបករណ៍បំណុលត្រូវបានវាស់វែងតាម FVOCI ប្រសិនបើឧបករណ៍បំណុលនោះមានលក្ខខណ្ឌដូចខាងក្រោម និងមិនបានកំណត់តាម FVTPL៖

- ទ្រព្យសកម្ម ត្រូវបានកាន់កាប់តាមគម្រូអាជីវកម្មដែលគោលបំណងត្រូវសម្រេចបានដោយទាំងការប្រមូលលំហូរទឹកប្រាក់តាមកិច្ចសន្យា និងលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌកិច្ចសន្យា នៃទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់ឲ្យមានការកើនឡើងនៃលំហូរទឹកប្រាក់ដែលជាSPPI តាមកាលបរិច្ឆេទជាក់លាក់។

នៅពេលទទួលស្គាល់ដំបូងនៃការវិនិយោគមូលធន ដែលមិនបានកាន់កាប់សម្រាប់ជួញដូរ ធនាគារមិនអាចបដិសេធជ្រើសរើសដើម្បីបង្ហាញការប្រែប្រួលបន្ទាប់នៅតម្លៃសមស្របក្នុង OCI។ ការជ្រើសរើសនេះត្រូវបានបង្កើតតាមមូលដ្ឋានវិនិយោគនីមួយៗ។

ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀតទាំងអស់ត្រូវបានចាត់ថ្នាក់ថាត្រូវបានវាស់វែង នៅតម្លៃសមស្របតាមចំណេញ ឬ ខាត FVTPL។

លើសពីនេះ សម្រាប់ការទទួលស្គាល់ជាលើកដំបូង សម្ព័ន្ធធនាគារ និងធនាគារអាចនឹងកំណត់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបំពេញតាមលក្ខខណ្ឌក្នុងការវាស់វែងតាមរំលស់ថ្លៃដើម ឬតាម FVOCI ប្រសិនបើវាស់វែងតាម FVTPL នឹងលុបបំបាត់ ឬកាត់បន្ថយ ជាសារវន្តនូវភាពមិនស្របគ្នានៃគណនេយ្យដែលនឹងកើតឡើង។

*ការវាយតម្លៃគម្រូអាជីវកម្ម*

សម្ព័ន្ធធនាគារនិងធនាគារ ធ្វើការវាយតម្លៃអំពីគោលបំណងនៃគម្រូអាជីវកម្មដែលទ្រព្យសកម្មត្រូវបានកាន់កាប់នៅកម្រិតផលប័ត្រ ពីព្រោះវាឆ្លុះបញ្ចាំងពីរបៀបដែលអាជីវកម្មត្រូវបានគ្រប់គ្រង និងព័ត៌មានត្រូវបានផ្តល់ទៅ គណៈគ្រប់គ្រង។ ព័ត៌មានដែលបានពិចារណារួមមាន៖

- គោលនយោបាយ និងគោលបំណងដែលបានបញ្ជាក់សម្រាប់ផលប័ត្រ និងប្រតិបត្តិការនៃគោលនយោបាយទាំងនោះនៅក្នុងការអនុវត្តជាក់ស្តែង។ ជាពិសេស ថាតើយុទ្ធសាស្ត្ររបស់គណៈគ្រប់គ្រង ផ្តោតលើការរកប្រាក់ចំណូលការប្រាក់តាមកិច្ចសន្យា រក្សាទម្រង់អត្រាការប្រាក់ជាក់លាក់ ផ្គូផ្គងរយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុទៅនឹងរយៈពេលនៃបំណុលដែលកំពុងផ្តល់មូលនិធិដល់ទ្រព្យសកម្មទាំងនោះ ឬការទទួលស្គាល់លំហូរទឹកប្រាក់តាមរយៈការលក់ទ្រព្យសកម្មនោះ។
- របៀបដែលលទ្ធផលនៃផលប័ត្រត្រូវបានវាយតម្លៃ និងរាយការណ៍ទៅគណៈគ្រប់គ្រងសម្ព័ន្ធធនាគារនិងធនាគារ។
- ហានិភ័យដែលប៉ះពាល់ដល់ការអនុវត្តគម្រូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងគម្រូអាជីវកម្មនោះ) និងយុទ្ធសាស្ត្ររបស់វាដើម្បីគ្រប់គ្រងហានិភ័យទាំងនោះ។
- របៀបដែលគណៈគ្រប់គ្រងអាជីវកម្មទទួលបានសំណង (ឧទាហរណ៍ ថាតើសំណង គឺផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬលំហូរទឹកប្រាក់តាមកិច្ចសន្យាដែលបានប្រមូល)។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)

- ភាពញឹកញាប់ បរិមាណ និងពេលវេលានៃការលក់ក្នុងការិយបរិច្ឆេទមុន ហេតុផលសម្រាប់ការលក់បែបនោះ និងការរំពឹងទុករបស់ខ្លួនអំពីសកម្មភាពលក់នាពេលអនាគត។ ទោះយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពលក់ មិនត្រូវបានគេគិតដាច់ដោយឡែកនោះទេ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃជាទូទៅទាំងអស់ ថាតើគោលបំណង ដែលសម្ព័ន្ធធនាគារនិងធនាគារបានចែងសម្រាប់ការគ្រប់គ្រងទ្រព្យសកម្ម ត្រូវបានសម្រេចដោយរបៀបណា និងលំហូរទឹកប្រាក់ជាក់ស្តែង ត្រូវបានទទួលស្គាល់ដោយរបៀបណា។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកាន់កាប់សម្រាប់ការជួញដូរ ឬគ្រប់គ្រង និងលទ្ធផលដែលត្រូវបានវាយតម្លៃតាមមូលដ្ឋានតម្លៃសមស្របត្រូវបានវាស់វែងតាម FVTPL ពីព្រោះទ្រព្យ និងលទ្ធផលទាំងនោះមិនត្រូវបានកាន់កាប់ដើម្បីប្រមូលលំហូរទឹកប្រាក់តាមកិច្ចសន្យា និងក្នុងពេលតែមួយមិនកាន់កាប់ ដើម្បីប្រមូលលំហូរទឹកប្រាក់តាមកិច្ចសន្យាជាមួយនឹងដើម្បីលក់ទ្រព្យសកម្មហិរញ្ញវត្ថុ។

*ការវាយតម្លៃ ថាតើលំហូរទឹកប្រាក់តាមកិច្ចសន្យា គឺជាការទូទាត់នៃប្រាក់ដើម និងការប្រាក់*

សម្រាប់គោលបំណងនៃការវាយតម្លៃនេះ "ប្រាក់ដើម" ត្រូវបានឲ្យនិយមន័យថាជាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលទទួលស្គាល់ដំបូង។ "ការប្រាក់" ត្រូវបានឲ្យនិយមន័យថាជាការទទួលបានមកវិញសម្រាប់តម្លៃទឹកប្រាក់នៃពេលវេលា និងសម្រាប់ហានិភ័យនៃឥណទានដែលទាក់ទងជាមួយចំនួនប្រាក់ដើមនៅសល់នៅក្នុងអំឡុងការិយបរិច្ឆេទជាក់លាក់មួយ និងសម្រាប់ហានិភ័យឥណទាន និងថ្លៃដើមមូលដ្ឋានផ្សេងៗទៀត (ដូចជា ហានិភ័យសន្ទនីយ៍ភាព និងថ្លៃដើមរដ្ឋបាល ក៏ដូចជាកម្រិតប្រាក់ចំណេញ។

នៅក្នុងការវាយតម្លៃថាតើលំហូរទឹកប្រាក់តាមកិច្ចសន្យាគឺជាការទូទាត់នៃប្រាក់ដើម និងការប្រាក់ទាំងស្រុង (SPPI) សម្ព័ន្ធធនាគារនិងធនាគារពិចារណាទៅលើលក្ខខណ្ឌតាមកិច្ចសន្យានៃឧបករណ៍។ នេះគឺរួមបញ្ចូលការវាយតម្លៃថាទ្រព្យសកម្មហិរញ្ញវត្ថុ រួមមាននូវលក្ខខណ្ឌតាមកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬ ចំនួន នៃលំហូរទឹកប្រាក់តាមកិច្ចសន្យា ដែលវានឹងមិនបំពេញលក្ខខណ្ឌនេះ។

នៅក្នុងការបង្កើតការវាយសម្ព័ន្ធធនាគារនិងធនាគារ ពិចារណាលើ៖

- ព្រឹត្តិការណ៍យថាភាព ដែលនឹងធ្វើឲ្យប្រែប្រួលនូវចំនួន និងពេលវេលានៃលំហូរទឹកប្រាក់
- លក្ខណៈពិសេសអានុភាព
- លក្ខខណ្ឌបង់ប្រាក់ជាមុន និងពន្យាពេល
- លក្ខខណ្ឌដែលកម្រិតការអះអាងរបស់សម្ព័ន្ធធនាគារនិងធនាគារ ចំពោះលំហូរទឹកប្រាក់ ពីទ្រព្យសកម្មណាមួយជាក់លាក់ (ដូចជាឥណទានមិនទាមទារសំណង)។
- លក្ខណៈពិសេសដែលកែប្រែការទទួលបាននៃតម្លៃទឹកប្រាក់ពេលវេលា (ដូចជាការកំណត់អត្រាការប្រាក់ ឡើងវិញតាមការិយបរិច្ឆេទ)។

*ឥណទានដែលមិនអាចប្រមូលមកវិញបាន*

ក្នុងករណីខ្លះ ឥណទានដែលផ្តល់ដោយសម្ព័ន្ធធនាគារនិងធនាគារ ដែលត្រូវបានការពារដោយទ្រព្យដាក់ធានារបស់អតិថិជនក៏មានកំហិតសម្ព័ន្ធធនាគារនិងធនាគារក្នុងការទាមទារសាច់ប្រាក់មកវិញដែរ (ឥណទានដែលមិនអាចប្រមូលមកវិញបាន)។ ក្នុងករណីនេះ សម្ព័ន្ធធនាគារ និងធនាគារធ្វើការវិនិច្ឆ័យក្នុងការវាយតម្លៃ ថាតើឥណទាននោះអាចប្រមូលមកវិញបានតែប្រាក់ដើម និងការប្រាក់ឬទេ។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ *(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

ជាទូទៅសម្ព័ន្ធធនាគារនិងធនាគារពិចារណាលើព័ត៌មានខាងក្រោមក្នុងការវិនិច្ឆ័យ៖

- ថាតើកិច្ចសន្យាមានបញ្ជាក់ច្បាស់ពីចំនួន និងកាលបរិច្ឆេទនៃការបង់សងកម្ចីដែរ ឬទេ
- តម្លៃសមស្របនៃទ្រព្យបញ្ចាំពាក់ព័ន្ធនឹងចំនួននៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានការធានាជាធម្មតា សម្ព័ន្ធធនាគារនិងធនាគារពិចារណាលើព័ត៌មានដូចខាងក្រោមនៅពេលធ្វើការវិនិច្ឆ័យ៖
- សមត្ថភាព និងឆន្ទៈរបស់អតិថិជន ក្នុងការទូទាត់សងតាមកិច្ចសន្យា ទោះបីមានឱនភាពនៃតម្លៃទ្រព្យបញ្ចាំក៏ដោយ
- ថាតើអតិថិជនគឺជារូបវន្តបុគ្គល ឬជាអង្គភាពប្រតិបត្តិការសំខាន់ ឬជាអង្គភាពដែលមានគោលបំណងពិសេស
- ហានិភ័យរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការបាត់បង់ទ្រព្យសកម្ម ទាក់ទងនឹងឥណទានដែលមិនអាចប្រមូលមកវិញបាន
- ថាតើទ្រព្យដាក់ធានាគឺជាទ្រព្យទាំងអស់ដែលអតិថិជនមាន ឬជាផ្នែកមួយនៃទ្រព្យសកម្មផ្សេងៗទៀតរបស់អតិថិជន និង
- ថាតើសម្ព័ន្ធធនាគារ និងធនាគារទទួលបានអត្ថប្រយោជន៍ពីទ្រព្យសកម្មនេះ ឬទេ ។

*ការធ្វើចំណាត់ថ្នាក់ឡើងវិញ*

ទ្រព្យសកម្មហិរញ្ញវត្ថុ មិនត្រូវបានធ្វើការចាត់ថ្នាក់ឡើងវិញបន្ទាប់ពីការទទួលស្គាល់ដំបូងឡើយលើកលែងតែក្នុងការិយបរិច្ឆេទបន្ទាប់ពីសម្ព័ន្ធធនាគារនិងធនាគារផ្លាស់ប្តូរគម្រូអាជីវកម្មរបស់ខ្លួន សម្រាប់ការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

**3.4.3. ការឈប់ទទួលស្គាល់**

*ទ្រព្យសកម្មហិរញ្ញវត្ថុ*

សម្ព័ន្ធធនាគារនិងធនាគារ ឈប់ទទួលស្គាល់នូវទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិតាមកិច្ចសន្យាលំហូរទឹកប្រាក់ពី ទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬពេលដែលសម្ព័ន្ធធនាគារនិងធនាគារផ្ទេរសិទ្ធិក្នុងការទទួលលំហូរទឹកប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការ ដែលហានិភ័យ និងផលប្រយោជន៍ទាំងអស់នៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានផ្ទេរ ឬដែលសម្ព័ន្ធធនាគារនិងធនាគារ មិនផ្ទេរ រួមទាំងមិនរក្សាទុកនូវរាល់ហានិភ័យ និងផលប្រយោជន៍នៃភាពជាម្ចាស់កម្មសិទ្ធិ និងធនាគារមិនរក្សាការត្រួតពិនិត្យនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

នៅពេលឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ លម្អៀងរវាងតម្លៃយោងនៃទ្រព្យសកម្ម (ឬ តម្លៃយោងដែលបែងចែកជាចំណែក នៃទ្រព្យសកម្ម ដែលឈប់ទទួលស្គាល់) និងផលបូកនៃ (i) បរិមាណទឹកប្រាក់លើដែលទទួលបាន (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មីដែលទទួលបានដកទ្រព្យអសកម្មថ្មីដែលបានសន្មត) និង (ii) រាល់ចំណេញ ឬខាតបង្គរដែលត្រូវបានទទួលស្គាល់នៅក្នុង OCI ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ និងខាត។

*បំណុលហិរញ្ញវត្ថុ*

សម្ព័ន្ធធនាគារនិងធនាគារឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចតាមកិច្ចសន្យាត្រូវបានរំលាយ លុបចោល ឬផុតកំណត់។

**3.4.4. ការកែប្រែនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ**

*ទ្រព្យសកម្មហិរញ្ញវត្ថុ*

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ នោះសម្ព័ន្ធធនាគារនិងធនាគារវាយតម្លៃថា តើលំហូរទឹកប្រាក់នៃទ្រព្យសកម្ម ដែលបានកែប្រែមានភាពខុសគ្នាជាសារវន្តដែរឬទេ។

ប្រសិនបើលំហូរទឹកប្រាក់មានភាពខុសគ្នាច្រើន នោះសិទ្ធិតាមកិច្ចសន្យាចំពោះលំហូរទឹកប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុដើមត្រូវបានចាត់ទុកថាផុតកំណត់។ ក្នុងករណីនេះ ទ្រព្យសកម្មហិរញ្ញវត្ថុដើមត្រូវបានឈប់ទទួលស្គាល់ ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ត្រូវបានទទួលស្គាល់ក្នុងតម្លៃសមស្របបូករួមនឹងថ្លៃដើមប្រតិបត្តិការដែលមាន។ កម្រៃសេវាទទួលបានដែលជាផ្នែកនៃការកែប្រែ ត្រូវបានកត់ត្រាដូចជាខាងក្រោម៖

- កម្រៃសេវា ដែលត្រូវបានពិចារណានៅក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យសកម្មថ្មី និងកម្រៃសេវាដែលតំណាងឲ្យការទូទាត់ថ្លៃដើមប្រតិបត្តិការដែលអាចទទួលបាន ត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងជាលើដំបូងនៃទ្រព្យសកម្ម និង
- កម្រៃសេវាផ្សេងទៀត ត្រូវបានរាប់បញ្ចូល នៅក្នុងរបាយការណ៍ប្រាក់ចំណេញ និងខាតជាផ្នែកនៃការកើនឡើង និងថយចុះនៅពេលឈប់ទទួលស្គាល់។

ប្រសិនបើលំហូរទឹកប្រាក់ ត្រូវបានកែប្រែនៅពេលដែលអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះគោលបំណងនៃការកែប្រែជាទូទៅ គឺដើម្បីទទួលបានមកវិញជាអតិបរមាលើលក្ខខណ្ឌនៃកិច្ចសន្យាដើម ជាជាងបង្កើតទ្រព្យសកម្មថ្មីដែលមានលក្ខខណ្ឌខុសគ្នាខ្លាំង។ ប្រសិនបើ សម្ព័ន្ធធនាគារនិងធនាគារមានគម្រោងកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយ ដែលអាចនាំឲ្យមានការលើកលែងចំពោះលំហូរទឹកប្រាក់ទ្រព្យសកម្មនោះ ត្រូវបានយកមកពិចារណាជាមុន ថាតើផ្នែកមួយនៃទ្រព្យសកម្មគួរតែត្រូវបាន លុបចេញពីបញ្ជីមុនពេលធ្វើការកែប្រែ ឬទេ (សូមមើលខាងក្រោមសម្រាប់គោលនយោបាយ ការលុបចេញពីបញ្ជី)។ វិធីសាស្ត្រនេះជះឥទ្ធិពលដល់លទ្ធផលនៃការវាយតម្លៃបរិមាណ ហើយក្នុងករណីនេះ មានន័យថា លក្ខណៈវិនិច្ឆ័យនៃការឈប់ទទួលស្គាល់ទ្រព្យជាទូទៅមិនអាចអនុវត្តបាននោះទេ។

ប្រសិនបើការកែតម្រូវទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ឬ FVOCI មិនបណ្តាលឲ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទេ នោះសម្ព័ន្ធធនាគារនិងធនាគារ នឹងគណនាឡើងវិញនូវតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុជាមុន ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្ម និងទទួលស្គាល់លទ្ធផលនៃការកែតម្រូវ ជាចំណេញ ឬខាត។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអត្រាថេរអត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវ ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែតម្រូវ។ រាល់ការចំណាយ ឬថ្លៃសេវាដែលកើតឡើង និងថ្លៃសេវាទទួលបាន ដែលជាផ្នែកមួយនៃការកែតម្រូវទាក់ទងនឹងតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានធ្វើការកែតម្រូវត្រូវបានរំលស់ផ្អែកលើរយៈពេលដែលនៅសល់នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវនោះ។

ប្រសិនបើការកែតម្រូវនេះ ត្រូវបានធ្វើឡើងដោយសារតែអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះចំណេញ ឬខាតត្រូវបានបង្ហាញជាមួយគ្នានឹងការខាតបង់លើឱនភាពនៃតម្លៃ នៃទ្រព្យសកម្ម។ ក្នុងករណីផ្សេងទៀត វាត្រូវបានបង្ហាញជាចំណូលការប្រាក់ ដែលគណនាដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ *(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

*បំណុលហិរញ្ញវត្ថុ*

សម្ព័ន្ធធនាគារនិងធនាគារ ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែតម្រូវ ហើយលំហូរទឹកប្រាក់នៃបំណុលដែលបានកែតម្រូវនោះមានភាពខុសគ្នាខ្លាំង។ ក្នុងករណីនេះ បំណុលហិរញ្ញវត្ថុថ្មី ត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប។ ភាពលម្អៀងរវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដែលមិនត្រូវបានទទួលស្គាល់ និងតម្លៃតបស្នង ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ តម្លៃតបស្នងរួមមាន ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលបានផ្ទេរ ប្រសិនបើមាន និងការទទួលយកបំណុលរួមទាំងបំណុលហិរញ្ញវត្ថុដែលបានកែតម្រូវថ្មី។

ប្រសិនបើការកែតម្រូវបំណុលហិរញ្ញវត្ថុនេះមិនធ្វើឲ្យមានការឈប់ទទួលស្គាល់ទេ នោះរំលស់ថ្លៃដើមនៃបំណុល ត្រូវគណនាឡើងវិញដោយធ្វើអប្បហារលំហូរទឹកប្រាក់ដែលបានកែប្រែ តាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូង ហើយលទ្ធផលនៃការចំណេញ ឬខាត ត្រូវបានទទួលស្គាល់នៅក្នុងបាយការណ៍ចំណេញ ឬខាត។ សម្រាប់បំណុលហិរញ្ញវត្ថុមានអត្រាអថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើដើម្បីគណនាចំណេញ ឬខាត ពីការកែតម្រូវ ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែតម្រូវ។ រាល់ការចំណាយ និងថ្លៃសេវាដែលកើតមាន ត្រូវបានទទួលស្គាល់ជាការកែតម្រូវទៅលើតម្លៃយោងនៃបំណុល និងរំលស់តាមរយៈពេលដែលនៅសល់នៃបំណុលហិរញ្ញវត្ថុ ដែលបានកែតម្រូវដោយគណនាអត្រាការប្រាក់ប្រសិទ្ធភាពឡើងវិញលើឧបករណ៍ហិរញ្ញវត្ថុ។

**3.4.5. ការកាត់កង**

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានកាត់កងគ្នា និងត្រូវបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែសម្ព័ន្ធធនាគារនិងធនាគារមានសិទ្ធិតាមច្បាប់ដើម្បីធ្វើការកាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏ទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

ប្រាក់ចំណូល និងការចំណាយត្រូវបានបង្ហាញនៅលើមូលដ្ឋានសុទ្ធតែនៅពេលដែលត្រូវបានអនុញ្ញាតនៅក្រោមស្តង់ដារគណនេយ្យ (“ស.រ.ទ.ហ.អ.ក”) ឬសម្រាប់ប្រាក់ចំណេញ និងការខាតបង់ដែលកើតឡើងពីក្រុមនៃប្រតិបត្តិការស្រដៀងគ្នា ដូចជានៅក្នុងសកម្មភាពពាណិជ្ជកម្មរបស់សម្ព័ន្ធធនាគារនិងធនាគារ។

**3.4.6. ការវាស់វែងតម្លៃសមស្រប**

តម្លៃសមស្រប គឺជាតម្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬតម្លៃដែលបានទូទាត់ចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារជាអាទិភាពបំផុត ដែលសម្ព័ន្ធធនាគារនិងធនាគារអាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ។ តម្លៃសមស្របរបស់បំណុលឆ្លុះបញ្ចាំងពីហានិភ័យនៃការមិនអនុវត្តកាតព្វកិច្ច។

សម្ព័ន្ធធនាគារនិងធនាគារវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើប្រាស់សម្រង់តម្លៃនៅក្នុងទីផ្សារសកម្ម របស់ឧបករណ៍នោះ ប្រសិនបើមាន។ ទីផ្សារមួយចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬបំណុល កើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានតម្លៃជាទៀងទាត់។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ *(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើស ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណាក្នុងការកំណត់តម្លៃប្រតិបត្តិការមួយ។

ភស្តុតាងដ៏ល្អបំផុតសម្រាប់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ នៅពេលទទួលស្គាល់ជាលើកដំបូង ជាទូទៅគឺជាតម្លៃប្រតិបត្តិការ មានន័យថា ជាតម្លៃសមស្របនៃផលតបស្នងបានផ្តល់ឲ្យ ឬបានទទួល។ ប្រសិនបើសម្ព័ន្ធធនាគារនិងធនាគារកំណត់ថា តម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូងខុសពីតម្លៃប្រតិបត្តិការហើយតម្លៃសមស្របនេះពុំមានភស្តុតាងមកបញ្ជាក់ តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្មចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃ ដែលក្នុងនោះទិន្នន័យដែលមិនអាចអង្កេតបានពាក់ព័ន្ធនឹងការវាស់វែង ត្រូវបានសន្មតថាមិនសារវន្ត ដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្រប ដោយកែតម្រូវតាមរយៈការពន្យារនូវភាពខុសគ្នារវាងតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង និងតម្លៃប្រតិបត្តិការ។ បន្ទាប់មកទៀត ភាពខុសគ្នានោះគឺត្រូវទទួលស្គាល់នៅក្នុងចំណេញ ឬខាត ផ្អែកលើអាយុកាលរបស់ឧបករណ៍នោះ ក៏ប៉ុន្តែមិនឲ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬនៅពេលបញ្ចប់ប្រតិបត្តិការនោះទេ។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុមានលក្ខណៈអាចទាមទារសងតាមតម្រូវការ (ឧទាហរណ៍ ប្រាក់បញ្ញើតាមតម្រូវការ) គឺមិនត្រូវតិចជាងចំនួនទឹកប្រាក់ដែលត្រូវបង់តាមតម្រូវការទេ ដោយត្រូវធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលចំនួនទឹកប្រាក់អាចត្រូវបានបង់។

សម្ព័ន្ធធនាគារនិងធនាគារ ទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទនៃរបាយការណ៍អំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង។

**3.4.7. ឱនភាពនៃតម្លៃ**

សម្ព័ន្ធធនាគារនិងធនាគារទទួលស្គាល់សំវិធានធនលើការខាតបង់សម្រាប់ការខាតបង់ឥណទានរំពឹងទុក នៅលើឧបករណ៍ហិរញ្ញវត្ថុដូចខាងក្រោមដែលមិនត្រូវបានវាស់វែងតាម FVTPL៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលជាឧបករណ៍បំណុល។ និង
- កិច្ចសន្យាឥណទានដែលបានចេញផ្សាយ។

ពុំមានការខាតបង់ឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ចំពោះការវិនិយោគមូលធននោះទេ។

ការខាតបង់ឥណទានរំពឹងទុក (ECL) តំណាងឲ្យការខាតបង់ឥណទានដែលឆ្លុះបញ្ចាំងចំនួនដែលមិនលម្អៀង និងវាស់វែងដោយប្រូបាប៊ីលីតេជាមធ្យមដែលត្រូវបានកំណត់ដោយការវាយតម្លៃចំនួននៃលទ្ធផលដែលអាចកើតមានឡើង តម្លៃពេលវេលានៃសាច់ប្រាក់ និងព័ត៌មានអំពីព្រឹត្តការណ៍អតីតកាលដែលសមហេតុផល និងអាចគាំទ្របាន លក្ខខណ្ឌ និងការព្យាករណ៍នៃលក្ខខណ្ឌសេដ្ឋកិច្ចនាពេលអនាគត។ សំវិធានធន ECL ត្រូវបានវាស់វែងនៅចំនួនស្មើនឹង (i) ECL អាយុកាល12ខែ ឬ ECL ពេញមួយអាយុកាល សម្រាប់ឧបករណ៍ហិរញ្ញវត្ថុទាំងនោះ ដែលធ្លាប់មានបទពិសោធន៍នៃកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន (SICR) ចាប់តាំងពីការទទួលស្គាល់ដំបូង (វិធីសាស្រ្តទូទៅ)។

ECL អាយុកាល 12ខែ គឺជាផ្នែកនៃ ECLពេញមួយអាយុកាល ដែលជាលទ្ធផលពីព្រឹត្តិការណ៍គ្មានលទ្ធភាពសងលើឧបករណ៍ហិរញ្ញវត្ថុ ដែលអាចធ្វើទៅបានក្នុងរយៈពេល 12ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។ ECLពេញមួយអាយុកាល គឺជាECL ដែលជាលទ្ធផលពីព្រឹត្តការណ៍មិនទូទាត់សងដែលអាចកើតមានពេញមួយអាយុកាលរំពឹងទុកនៃឧបករណ៍ហិរញ្ញវត្ថុ។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ *(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

*ការវាយតម្លៃដំណាក់កាល*

វិធីសាស្ត្របីដំណាក់កាលសម្រាប់ឱនភាពនៃតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានប្រើប្រាស់ដោយផ្អែកលើថា តើមានការថយចុះខ្លាំងនៃហានិភ័យឥណទាននៃឧបករណ៍ហិរញ្ញវត្ថុដែរ ឬទេ។ បន្ទាប់មកដំណាក់កាលទាំងបីនេះកំណត់ចំនួននៃឱនភាពនៃតម្លៃដើម្បីទទួលស្គាល់។

សម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលមិនមានឱនភាពនៃតម្លៃឥណទាន៖

- ដំណាក់កាលទី1 រួមមាននូវឧបករណ៍ហិរញ្ញវត្ថុទាំងអស់ ដែលពុំធ្លាប់មានបទពិសោធន៍ជាមួយនឹង SICR (ការកំណត់នៃការកើនឡើងជាសារវន្តនូវហានិភ័យឥណទាន) ចាប់តាំងពីទទួលស្គាល់ដំបូង ឬត្រូវបានចាត់ទុកថាមានហានិភ័យឥណទានទាបនាកាលបរិច្ឆេទរាយការណ៍។ លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ថាគណនីគួរតែត្រូវបានវាយតម្លៃនៅដំណាក់កាលទី1 មានដូចតទៅ៖ (i) បច្ចុប្បន្ន ឬហួសកាលកំណត់រហូតដល់ 14ថ្ងៃ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុរយៈពេលខ្លី (ii) បច្ចុប្បន្ន ឬហួសកាលកំណត់រហូតដល់ 29ថ្ងៃ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុរយៈពេលវែង ឬ (iii) ពុំមានកំណើននៃប្រូបាប៊ីលីតេនៃការខកខានទូទាត់សង (PD)។ សម្ព័ន្ធធនាគារនិងធនាគារទទួលស្គាល់ ECL អាយុកាល12 ខែ សម្រាប់ឧបករណ៍ហិរញ្ញវត្ថុដំណាក់កាលទី1។

- ដំណាក់កាលទី2 រួមមានឧបករណ៍ហិរញ្ញវត្ថុទាំងអស់ដែលមានបទពិសោធន៍ជាមួយ SICR នាកាលបរិច្ឆេទរាយការណ៍ដោយប្រៀបធៀបទៅការទទួលស្គាល់ដំបូង។ ជាទូទៅ SICR ត្រូវបានចាត់ទុកថាមានវត្តមាននៅក្នុងគណនីដែល (i) ហួសកាលកំណត់ 15 ទៅ 29 ថ្ងៃសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុរយៈពេលខ្លី (ii) ហួសកាលកំណត់ 30 ទៅ 89ថ្ងៃ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុរយៈពេលវែង ឬ (iii) ជាមួយកំណើនគួរឲ្យកត់សម្គាល់នៅ PD។ សម្ព័ន្ធធនាគារនិងធនាគារទទួលស្គាល់ ECL ពេញមួយអាយុកាលសម្រាប់ឧបករណ៍ហិរញ្ញវត្ថុដំណាក់កាលទី2។

- ដំណាក់កាលទី3 រួមមានទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ដែលមានភស្តុតាងជាក់លាក់នៃ ឱនភាពនៃតម្លៃដោយលទ្ធផលនៃ ព្រឹត្តិការណ៍មួយ ឬច្រើនដែលបានកើតឡើងបន្ទាប់ពីការទទួលស្គាល់ដំបូងជាមួយផលប៉ះពាល់អវិជ្ជមានលើលំហូរទឹកប្រាក់អនាគតដែលបានរំពឹងទុកនៃឥណទាន ឬផលប័ត្រនៃឥណទាន។ លក្ខណៈវិនិច្ឆ័យសម្រាប់គណនីដំណាក់កាលទី3 របស់សម្ព័ន្ធធនាគារនិងធនាគារជាទូទៅត្រូវបានតម្រឹមគ្នា ជាមួយនឹងនិយមន័យនៃ “ការគ្មានលទ្ធភាពសង” ដែលនឹងត្រូវបានពន្យល់នៅកថាខណ្ឌបន្ទាប់។ ធនាគារទទួលស្គាល់ ECL ពេញមួយអាយុកាលសម្រាប់ឧបករណ៍ហិរញ្ញវត្ថុដំណាក់កាលទី3។

*និយមន័យនៃការគ្មានលទ្ធភាពសង*

សម្ព័ន្ធធនាគារនិងធនាគារចាត់ទុកទ្រព្យសកម្មហិរញ្ញវត្ថុថាមិនមានលទ្ធភាពសង នៅពេលដែល៖

- អតិថិជនទំនងជាមិនបង់កាតព្វកិច្ចឥណទានរបស់ខ្លួនទៅសម្ព័ន្ធធនាគារនិងធនាគារទាំងស្រុង ដោយមិនមានការពិចារណាដោយសម្ព័ន្ធធនាគារនិងធនាគារលើសកម្មភាពដូចជា ការទទួលស្គាល់ទ្រព្យធានា (ប្រសិនបើមានកាន់កាប់) ឬ

- សម្ព័ន្ធធនាគារនិងធនាគារពិចារណាថា ការកើនឡើងគួរឲ្យកត់សម្គាល់នូវហានិភ័យឥណទាន កើតឡើងមិនយឺតជាងពេលដែលទ្រព្យសកម្ម បានហួសកាលកំណត់លើសពី ឬស្មើនឹង 31ថ្ងៃសម្រាប់ ហ្វាស៊ីលីធីរយៈពេលខ្លី ឬហួសកាលកំណត់លើសពី ឬស្មើនឹង 90ថ្ងៃសម្រាប់ហ្វាស៊ីលីធីរយៈពេលវែង។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ *(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

*ហានិភ័យឥណទាននៅពេលទទួលស្គាល់ដំបូង*

សម្ព័ន្ធធនាគារនិងធនាគារប្រើប្រាស់ការវាយតម្លៃ និងការអនុម័តហានិភ័យផ្ទៃក្នុងនៅកម្រិតផ្សេងៗគ្នា ដើម្បីកំណត់ហានិភ័យឥណទាននៃការប្រឈមនៅពេលទទួលស្គាល់ដំបូង។ ការវាយតម្លៃអាចជាបរិមាណ ឬគុណភាព និងពឹងផ្អែកលើភាពជាសារវន្តនៃហ្វាស៊ីលីធី ឬ ភាពស្មុគស្មាញនៃផលប័ត្រដែលត្រូវវាយតម្លៃ។

*ការកើនឡើងគួរឲ្យកត់សម្គាល់នៃហានិភ័យឥណទាន*

សម្ព័ន្ធធនាគារនិងធនាគារវាយតម្លៃថាហានិភ័យឥណទានបានកើនឡើងគួរឲ្យកត់សម្គាល់ ចាប់ពីពេលទទួលស្គាល់ដំបូងនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍។ នៅពេលកំណត់ថាហានិភ័យឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុមានការកើនឡើងគួរឲ្យកត់សម្គាល់ចាប់ពីពេលទទួលស្គាល់ដំបូង និងនៅពេលប៉ាន់ស្មាន ECL នោះសម្ព័ន្ធធនាគារនិងធនាគារពិចារណាព័ត៌មានដែលសមហេតុផល និងអាចគាំទ្របាន ហើយវាមានការពាក់ព័ន្ធ ដោយគ្មានការចំណាយ ឬការប្រឹងប្រែងហួសហេតុ។ នេះរួមបញ្ចូលទាំងព័ត៌មាន និងការវិភាគបរិមាណ និងគុណភាព ដោយផ្អែកលើបទពិសោធន៍ប្រវត្តិសាស្ត្ររបស់សម្ព័ន្ធធនាគារនិងធនាគារ និងការវាយតម្លៃឥណទានដែលបានជូនដំណឹង និងរួមបញ្ចូលនូវព័ត៌មានប្រមើលមើលទៅពេលអនាគត។

សម្ព័ន្ធធនាគារនិងធនាគារចាត់ទុកថាការកើនឡើងគួរឲ្យកត់សម្គាល់នៃហានិភ័យឥណទាន កើតឡើងមិនយឺតជាងពេលដែលទ្រព្យសកម្មបានហួសកាលកំណត់លើសពី 90ថ្ងៃ។ ថ្ងៃហួសកាលកំណត់ត្រូវបានកំណត់ដោយរាប់ចំនួនថ្ងៃចាប់ពីកាលបរិច្ឆេទហួសកាលកំណត់មុនគេបំផុត ដែលការទូទាត់សងពេញលេញពុំត្រូវបានទទួល។ កាលបរិច្ឆេទផុតកាលកំណត់ត្រូវបានកំណត់ដោយមិនពិចារណា លើរយៈពេលអនុគ្រោះណាមួយដែលអាចប្រើប្រាស់បានសម្រាប់អ្នកខ្ចី។ ប្រសិនបើមានភស្តុតាង ដែលបង្ហាញថាពុំមានការកើនឡើងគួរឲ្យកត់សម្គាល់នៃ ហានិភ័យឥណទាន ដែលទាក់ទងទៅនឹងការទទួលស្គាល់ដំបូង នោះសំវិធានធនខាតបងលើឧបករណ៍នឹងត្រឡប់ទៅជាបានវាស់វែងជា ECL អាយុកាល 12ខែ។

*ការវាស់វែងនៃ ECL*

ECL គឺជាការប៉ាន់ស្មានដោយផ្អែកលើប្រូបាប៊ីលីតេជាមធ្យមនៃការខាតបង់ឥណទាន។ ECL ត្រូវបានវាស់ដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមានឱនភាពនៃតម្លៃឥណទាននៅកាលបរិច្ឆេទរាយការណ៍៖ ជាតម្លៃបច្ចុប្បន្ននៃកង្វះសាច់ប្រាក់ទាំងអស់ (ឧទាហរណ៍ ភាពខុសគ្នារវាងលំហូរទឹកប្រាក់ជំពាក់ទៅអង្គភាពដោយអនុលោមតាមកិច្ចសន្យា និងលំហូរទឹកប្រាក់ដែលធនាគាររំពឹងថានឹងទទួលបាន)។

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាននៅកាលបរិច្ឆេទរាយការណ៍៖ ដូចជាភាពខុសគ្នារវាងតម្លៃយោងដុល និងតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់អនាគត ដែលបានប៉ាន់ស្មាន។ និង

- កិច្ចសន្យាឥណទានដែលមិនទាន់ប្រើប្រាស់៖ ជាតម្លៃបច្ចុប្បន្ននៃភាពខុសគ្នារវាងលំហូរទឹកប្រាក់តាមកិច្ចសន្យា ដែលត្រូវសងទៅសម្ព័ន្ធធនាគារនិងធនាគារប្រសិនបើការកិច្ចសន្យាត្រូវបានចេញឲ្យ និងលំហូរទឹកប្រាក់ដែលសម្ព័ន្ធធនាគារនិងធនាគាររំពឹងថានឹងទទួលបាន។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ *(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

*ប៉ារ៉ាម៉ែត្រ និងវិធីសាស្ត្រ ECL*

ធាតុចូលសំខាន់ៗ ក្នុងការវាស់វែងរបស់ ECL ត្រូវបានកំណត់តាមលក្ខខណ្ឌដូចដូចខាងក្រោម៖

- ប្រូបាប៊ីលីតេនៃការខកខានទូទាត់សង (“PD”)
- ការខាតបង់ដោយការគ្មានលទ្ធភាពសង (“LGD”) និង
- ទំហំនៃការខកខានសង (“ EAD”)

ECL សម្រាប់ការប្រឈមនៅក្នុងដំណាក់កាលទី1 ត្រូវបានគណនាដោយគុណនឹង PD រយៈពេល 12ខែ ដោយ LGD និង EAD។ ECL ពេញមួយអាយុកាលត្រូវបានគណនាដោយគុណ PD ពេញមួយអាយុកាលដោយ LGD និង EAD។ គម្រូស្ថិតិត្រូវបានប្រើដើម្បីវិភាគទិន្នន័យដែលប្រមូលបាន និងបង្កើតការប៉ាន់ស្មាននៃអាយុកាល PD ដែលនៅសល់និងរបៀបដែលវាត្រូវបានរំពឹងទុកថានឹងផ្លាស់ប្តូរដោយលទ្ធផលនៃពេលវេលាដែលកន្លងផុត។

LGD គឺជាទំហំនៃការខាតបង់ដែលអាចកើតមានប្រសិនបើមានការគ្មានលទ្ធភាពសងកើតឡើង។ សម្ព័ន្ធធនាគារនិងធនាគារប៉ាន់ស្មានប៉ារ៉ាម៉ែត្ររបស់ LGD ផ្អែកលើប្រវត្តិនៃអត្រានៃការសងត្រឡប់មកវិញ នឹងការខកខានក្នុងការទូទាត់សងរបស់សមភាគី។ គម្រូ LGD ពិចារណាលើរចនាសម្ព័ន្ធ វត្ថុបញ្ចាំ អតីតភាពនៃការទាមទារ វិស័យ និងថ្លៃលើការសងត្រឡប់មកវិញនៃវត្ថុបញ្ចាំដែលមានសារៈសំខាន់ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ។

សម្រាប់ឥណទាន ដែលត្រូវបានធានាដោយអចលនទ្រព្យរាយ អនុបាត LTV គឺជាប៉ារ៉ាម៉ែតទំរមង្សនៅក្នុងការកំណត់ LGD។ ការប៉ាន់ស្មានរបស់ LGD ត្រូវបានគេគណនាឡើងវិញសម្រាប់សេណារីយ៉ូសេដ្ឋកិច្ចផ្សេងគ្នា និងសម្រាប់ការផ្តល់ប្រាក់កម្ចីអចលនទ្រព្យ ដើម្បីឆ្លុះបញ្ចាំងពីការប្រែប្រួល ដែលអាចកើតមានចំពោះថ្លៃនៃអចលនទ្រព្យ។ ពួកគេត្រូវបានគណនាដោយតាមមូលដ្ឋានធ្វើលំហូទឹកប្រាក់ ដែលបានធ្វើអប្បហារដោយប្រើប្រាស់អត្រាការប្រាក់ប្រសិទ្ធភាពជាកត្តានៃការធ្វើអប្បហារ។

EAD ទំហំហានិភ័យរំពឹងទុកករណីគ្មានលទ្ធភាពសង។សម្ព័ន្ធធនាគារនិងធនាគារទាញយក EAD ពីការប្រឈមនឹងហានិភ័យបច្ចុប្បន្នចំពោះសមភាគី និងការផ្លាស់ប្តូរសក្តានុពលចំពោះចំនួនទឹកប្រាក់បច្ចុប្បន្នដែលបានអនុញ្ញាតក្រោមកិច្ចសន្យា ហើយនិងកើតឡើងពីការរំលស់។ EAD នៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាតម្លៃយោងទ្រព្យសកម្មដុលរបស់វានៅពេលនៃការគ្មានលទ្ធភាពសង។ សម្រាប់ការសន្យាផ្តល់ប្រាក់កម្ចី EADs គឺជាចំនួនសក្តានុពលនាពេលអនាគតដែលអាចត្រូវបានទម្លាក់ក្រោមកិច្ចសន្យា ដែលត្រូវបានប៉ាន់ស្មានដោយផ្អែកលើការសង្កេតប្រវត្តិសាស្ត្រ និងការព្យាករណ៍ឆ្ពោះទៅមុខ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុមួយចំនួន EAD ត្រូវបានកំណត់ដោយយកគម្រូតាមកម្រិតនៃ លទ្ធផលនៃទំហំហានិភ័យដែលអាចកើតមាននៅចំណុចផ្សេងៗគ្នា ក្នុងពេលមួយដោយប្រើសេណារីយ៉ូ និងបច្ចេកទេសស្ថិតិ។

ដូចបានរៀបរាប់ខាងលើ និងជាកម្មវត្ថុចំពោះការប្រើប្រាស់អតិបរមានៃ12 ខែ PD សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី1 សម្ព័ន្ធនាគារនិងធនាគារវាស់វែង ECL ដោយពិចារណាលើហានិភ័យនៃការគ្មានលទ្ធភាពសងលើការិយបរិច្ឆេទកិច្ចសន្យាអតិបរមា (ដោយរាប់បញ្ចូលទាំងជម្រើសបន្ថែមរបស់អ្នកខ្ចី) ដែលវាត្រូវបានប្រឈមទៅនឹងហានិភ័យឥណទាន បើទោះបីជាសម្រាប់គោលបំណងនៃការគ្រប់គ្រងហានិភ័យឥណទាន សម្ព័ន្ធធនាគារនិងធនាគារពិចារណាលើរយៈពេលវែងជាងនេះ។ ការិយបរិច្ឆេទកិច្ចសន្យាអតិបរមា លាតសន្ធឹងរហូតដល់កាលបរិច្ឆេទដែលសម្ព័ន្ធធនាគារនិងធនាគារ មានសិទ្ធិដើម្បីតម្រូវឲ្យមានការទូទាត់សងប្រាក់ជាមុន ឬបញ្ចប់កិច្ចសន្យាឥណទាន ឬ ការធានាប្រាក់កម្ចី។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ *(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

*ព័ត៌មាននាពេលអនាគត*

សម្ព័ន្ធធនាគារនិងធនាគារបានរួមបញ្ចូលព័ត៌មាននាពេលអនាគតទៅក្នុងការវាយតម្លៃ ថាតើហានិភ័យឥណទាននៃឧបករណ៍បានកើនឡើងគួរឲ្យកត់សម្គាល់ចាប់តាំងពីពេលទទួលស្គាល់ដំបូង និងការវាស់វែងនៃ ECL។'

ព័ត៌មាននាពេលអនាគតយ៉ាងធំទូលាយ ត្រូវបានចាត់ទុកជាធាតុចូលសេដ្ឋកិច្ច ដូចជាកំណើនផលិតផលក្នុងស្រុកសរុប អត្រាប្តូរប្រាក់ អត្រាការប្រាក់ អត្រាគ្មានការងារធ្វើ និងសូចនាករសេដ្ឋកិច្ចផ្សេងៗទៀត។ ធាតុចូល និងម៉ូឌែលដែលត្រូវបានប្រើសម្រាប់គណនា ECL មិនតែងតែចាប់យកលក្ខណៈទាំងអស់នៃទីផ្សារនៅកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ។ ដើម្បីឆ្លុះបញ្ចាំងចំណុចនេះការកែតម្រូវគុណភាព ឬ ទំហំឥណទានខាតបង់បន្ថែមត្រូវបានធ្វើឡើងជាការកែតម្រូវបណ្តោះអាសន្ននៅពេលភាពខុសគ្នាបែបនេះមានភាពជាសារន្ត។

*ការរៀបចំទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ*

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចរចាឡើងវិញ ឬកែប្រែ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយទ្រព្យថ្មី ដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុរបស់អ្នកខ្ចី នោះការវាយតម្លៃត្រូវបានធ្វើឡើងថា តើទ្រព្យសកម្មហិរញ្ញវត្ថុគួរតែត្រូវបានឈប់ទទួលស្គាល់ និងECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ប្រសិនបើ ការរៀបចំរចនាសម្ព័ន្ធឡើងវិញដែលរំពឹងទុកនឹងមិនបណ្តាលឲ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ នោះលំហូរទឹកប្រាក់រំពឹងទុក ដែលកើតឡើងពីទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែប្រែ ត្រូវបានរាប់បញ្ចូលក្នុងការគណនាកង្វះខាតសាច់ប្រាក់ពីទ្រព្យសកម្មដែលមានស្រាប់។

- ប្រសិនបើ ការរៀបចំរចនាសម្ព័ន្ធឡើងវិញដែលរំពឹងទុក អាចឲ្យមានលទ្ធផលនៃការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ នោះតម្លៃសមស្រប ដែលរំពឹងទុកនៃទ្រព្យសកម្មថ្មីត្រូវបានចាត់ទុកថាជាលំហូរទឹកប្រាក់ចុងក្រោយពីទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ នៅពេលនៃការឈប់ទទួលស្គាល់របស់វា។ ចំនួននេះត្រូវបានរាប់បញ្ចូលក្នុងការគណនាកង្វះខាតសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ ដែលត្រូវបានធ្វើអប្បហារពីកាលបរិច្ឆេទរំពឹងទុកនៃការឈប់ទទួលស្គាល់រហូតដល់កាលបរិច្ឆេទរាយការណ៍ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់។

*ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាន*

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ សម្ព័ន្ធធនាគារនិងធនាគារវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានយោងតាមថ្លៃដើមរំលស់ និងទ្រព្យសកម្មហិរញ្ញវត្ថុបំណុលដែលបានយោងតាម FVOCI គឺមានឱនភាពនៃតម្លៃឥណទានដែរ ឬទេ (សំដៅទៅលើ 'ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី3')។ ទ្រព្យសកម្មហិរញ្ញវត្ថុមាន "ឱនភាពនៃតម្លៃឥណទាន" នៅពេលព្រឹត្តិការណ៍មួយ ឬច្រើន ដែលមានផលប៉ះពាល់យ៉ាងខ្លាំងលើលំហូរទឹកប្រាក់ហិរញ្ញវត្ថុនាពេលអនាគតរបស់ទ្រព្យសកម្មហិរញ្ញវត្ថុបានកើតឡើង។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ *(សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023)*

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃ រួមមានទិន្នន័យដែលអាចអង្កេតបានដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យា ដូចជាការខកខានមិនបានសង ឬហួសកាលកំណត់
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃការផ្តល់ឥណទានដល់អតិថិជនដែលសម្ព័ន្ធធនាគារនិងធនាគារមិនយល់ព្រម
- អតិថិជនទំនងនឹងក្ស័យធន ឬត្រូវរៀបចំហិរញ្ញវត្ថុឡើងវិញជាថ្មី
- ការបាត់បង់ទីផ្សារសកម្មសម្រាប់មូលបត្រដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ។

ឥណទានដែលត្រូវបានរៀបចំឡើងវិញ ដោយសារតែភាពមិនប្រក្រតីនៅក្នុងលក្ខខណ្ឌរបស់អតិថិជន ត្រូវបានចាត់ទុកជាឥណទានមានឱនភាពនៃតម្លៃ លុះត្រាតែមានភស្តុតាងបញ្ជាក់ថាហានិភ័យនៃការមិនទទួលបានលំហូរទឹកប្រាក់តាមកិច្ចសន្យាបានថយចុះជាសារវន្ត និងមិនមានសូចនាករផ្សេងទៀតដែលនាំឲ្យមានឱនភាពនៃតម្លៃ។ បន្ថែមលើនេះ ឥណទានដែលហួសកាលកំណត់សង ៩០ថ្ងៃ ឬលើសពីនេះត្រូវបានចាត់ទុកជាឥណទានមានឱនភាពនៃតម្លៃ ទោះបីជានិយមន័យនៃការហួសកាលកំណត់សង ដែលច្បាប់បានកំណត់ផ្សេងគ្នាក៏ដោយ។

*ការបង្ហាញនៃសំវិធានធនសម្រាប់ ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ*

សំវិធានធនលើការខាតបង់សម្រាប់ ECL ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងដោយថ្លៃដើមរំលស់៖ ដូចជាការដកចេញពីតម្លៃយោងដុលនៃទ្រព្យសកម្ម។

*ការលុបចោល*

ឥណទាន និងបុរេប្រទានត្រូវបានលុបចោល (ទាំងផ្នែកខ្លះ ឬ ទាំងស្រុង) នៅពេលដែលមិនមានការរំពឹងទុកដែលសមហេតុផលក្នុងការប្រមូលមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុទាំងមូល ឬផ្នែកណាមួយរបស់វា។ ជាទូទៅក្នុងករណីនេះ នៅពេលដែលសម្ព័ន្ធធនាគារនិងធនាគារកំណត់ថាអ្នកខ្ចីមិនមានទ្រព្យសកម្ម ឬប្រភពចំណូលដែលអាចបង្កើតជាលំហូរទឹកប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់សងចំនួនទឹកប្រាក់ ដែលជាកម្មវត្ថុក្នុងការលុបចោល។ ការវាយតម្លៃនេះត្រូវបានយោងទៅតាមកម្រិតនៃទ្រព្យសកម្មរបស់បុគ្គលម្នាក់ៗ។

ការប្រមូលមកវិញនៃចំនួនដែលបានលុបចោលពីមុន ត្រូវបានរួមបញ្ចូលនៅក្នុង "ចំណូលផ្សេងៗ" នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ ទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានលុបចោល គឺនៅតែជាកម្មវត្ថុចំពោះសកម្មភាពអនុវត្តច្បាប់ដើម្បីអនុលោមតាមនីតិវិធីរបស់ សម្ព័ន្ធធនាគារនិងធនាគារសម្រាប់ការប្រមូលមកវិញនៃចំនួនដែលត្រូវសង។

### 3.5. ឥណទាន និងបុរេប្រទានទៅអតិថិជន

'ឥណទាន និងបុរេប្រទាន' ដែលមាននៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រួមមាន ឥណទាន និងបុរេប្រទានដែលបានវាស់វែងតាមវិធីសាស្ត្ររំលស់ថ្លៃដើម ដែលឥណទាន និងបុរេប្រទាននោះ ត្រូវបានវាស់លើកដំបូងតាមតម្លៃសមស្របបូកនឹងថ្លៃចំណាយប្រតិបត្តិការផ្ទាល់ដែលកើតឡើង ហើយដែលក្រោយមកវាស់វែងតាមតាមវិធីសាស្ត្ររំលស់ថ្លៃដើម តាមការប្រាក់ប្រសិទ្ធភាព។

## 3.6. ការវិនិយោគលើក្រុមហ៊ុនបុត្រសម្ព័ន្ធ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក

ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាអង្គភាពដែលគ្រប់គ្រងដោយធនាគារ។ អត្ថិភាពនៃការគ្រប់គ្រងកើតមាននៅពេលដែលធនាគារមានអំណាច (ដោយផ្ទាល់ ឬដោយប្រយោល) ក្នុងការគ្រប់គ្រងគោលនយោបាយហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់អង្គភាព ដើម្បីទទួលបាននូវផលប្រយោជន៍ពីសកម្មភាពទាំងនោះ។ របាយការណ៍ហិរញ្ញវត្ថុនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានរួមបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមចាប់ពីកាលបរិច្ឆេទដែលការគ្រប់គ្រងបានចាប់ផ្តើម រហូតដល់កាលបរិច្ឆេទដែលការគ្រប់គ្រងនោះត្រូវបានបញ្ឈប់។ ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវរួមបញ្ចូល ដោយប្រើវិធីសាស្រ្តគណនេយ្យទាក់ទិននឹងការទិញ ("Acquisition method of accounting")។

## 3.7. ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាយោងតាមថ្លៃដើម ដកឱនភាពនៃតម្លៃ ប្រសិនបើមាន។

## 3.8. ទ្រព្យសកម្មរក្សាទុកសម្រាប់លក់

ទ្រព្យសកម្មរក្សាទុកសម្រាប់លក់ត្រូវបានកត់ត្រាទៅតាមតម្លៃទាបជាងរវាងតម្លៃយោង និងតម្លៃសមស្របដកថ្លៃដើមលក់។ ការខាតបង់ឱនភាពនៃតម្លៃណាមួយនៅពេលធ្វើចំណាត់ថ្នាក់ដំបូងថា ជាទ្រព្យសកម្មរក្សាទុកសម្រាប់លក់ និងការចំណេញ ឬខាតបន្ទាប់លើការវាស់វែងឡើងវិញត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

## 3.9. ទ្រព្យ និងបរិក្ខារ

### 3.9.1. ការទទួលស្គាល់ និងការវាស់វែង

ធាតុនៃទ្រព្យ និងបរិក្ខារ ត្រូវបានវាស់វែងនៅថ្លៃដើមដករំលស់បង្គរ និងការខាតបង់ឱនភាពនៃតម្លៃបង្គរផ្សេងទៀត។

ថ្លៃដើម រួមបញ្ចូលនូវចំណាយដែលកើតឡើងដោយផ្ទាល់ចំពោះការទិញទ្រព្យសកម្ម និងថ្លៃដើមដទៃទៀតដែលកើតឡើងពីការធ្វើឲ្យទ្រព្យសកម្មនោះ ឈានទៅដល់លក្ខខណ្ឌដំណើរការ សម្រាប់ការប្រើប្រាស់តាមបំណង ហើយថ្លៃដើមនៃការកម្ទេចចោល និងយកចេញទ្រព្យនោះ និងស្តារឡើងវិញនូវទីតាំងដែលទ្រព្យ និងបរិក្ខារត្រូវបានដាក់តាំងនៅ។ ថ្លៃដើមនៃទ្រព្យដែលបានសាងសង់ដោយខ្លួនឯង ក៏រួមបញ្ចូលទាំងថ្លៃដើមសម្ភារៈ និងកម្លាំងពលកម្មដោយផ្ទាល់ផងដែរ។ សម្រាប់ទ្រព្យសកម្ម ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ថ្លៃដើមកម្ចីត្រូវបានធ្វើមូលធនកម្ម ដោយផ្អែកតាមគោលនយោបាយគណនេយ្យលើថ្លៃដើមកម្ចី។ ថ្លៃដើមអាចរួមបញ្ចូលការផ្ទេរពីមូលធននៃចំណេញ ឬខាតផ្សេងៗលើការពារហានិភ័យលំហូរទឹកប្រាក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នៃការទិញទ្រព្យ និងបរិក្ខារដោយរូបិយប័ណ្ណបរទេស។

កម្មវិធីកុំព្យូទ័រដែលបានទិញ ដែលជាផ្នែកចំបងចំពោះមុខងាររបស់ឧបករណ៍ ដែលពាក់ព័ន្ធត្រូវបានធ្វើ មូលធនកម្មជាផ្នែកមួយនៃបរិក្ខារនោះ។ នៅពេលដែលផ្នែកសំខាន់ណាមួយនៃទ្រព្យ និងបរិក្ខារមានអាយុកាលប្រើប្រាស់ខុសពីគ្នា នោះទ្រព្យ និងបរិក្ខារត្រូវបានដាក់ជាធាតុដោយឡែកគ្នា (សមាសភាពចម្បង) នៃទ្រព្យ និងបរិក្ខារ។

ចំណេញ ឬខាតពីការលក់ផ្នែកនៃទ្រព្យ និងបរិក្ខារត្រូវបានកំណត់ដោយប្រៀបធៀបចំណូលទទួលបានពីការលក់ជាមួយនឹងតម្លៃយោងនៃទ្រព្យ និងបរិក្ខារ និងត្រូវបានទទួលស្គាល់ជាចំនួនសុទ្ធក្នុង "ចំណូលផ្សេងៗ" និង "ចំណាយផ្សេងទូទៅ និងរដ្ឋបាល" រៀងគ្នានៅក្នុងរបាយការណ៍ចំណេញ ឬខាត។

### 3.9.2. ចំណាយបន្ទាប់

ថ្លៃដើមនៃការជំនួសសមាសធាតុនៃទ្រព្យ និងបរិក្ខារត្រូវបានទទួលស្គាល់នៅក្នុងតម្លៃយោងនៃសមាសធាតុនោះ ប្រសិនបើវាអាចដឹងមានអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលរួមបញ្ចូលនៅក្នុងសមាសធាតុអាចនឹងហូរចូលមកសម្ព័ន្ធធនាគារនិងធនាគារ ហើយថ្លៃដើមរបស់វាអាចវាស់វែងបានដោយជឿជាក់បាន។ តម្លៃយោងនៃសមាសធាតុដែលបានផ្លាស់ប្តូរត្រូវបានឈប់ទទួលស្គាល់ទៅចំណេញ ឬខាត។ ថ្លៃដើមនៃការធ្វើសេវាកម្មពីមួយថ្ងៃទៅមួយថ្ងៃនៃទ្រព្យ និងបរិក្ខារត្រូវបានទទួលស្គាល់នៅចំណេញ ឬខាតដូចដែលបានកើតឡើង។

### 3.9.3. រំលស់

រំលស់ ត្រូវបានគណនាលើថ្លៃដើមនៃទ្រព្យ និងបរិក្ខារដកចេញនូវតម្លៃកាកសំណល់។ សមាសធាតុសំខាន់ៗនៃទ្រព្យសកម្មនីមួយៗត្រូវបានវាយតម្លៃ និងប្រសិនបើសមាសធាតុមួយ មានអាយុកាលប្រើប្រាស់ដែលខុសពីអ្វីដែលនៅសល់នៃទ្រព្យនោះ សមាសធាតុនោះត្រូវបានរំលស់ដោយឡែក។

រំលស់ត្រូវបានទទួលស្គាល់ជា ចំណាយនៅក្នុងចំណេញ ឬខាតតាមមូលដ្ឋានរំលស់ថេរលើអាយុកាលប្រើប្រាស់ ដែលបានប៉ាន់ស្មាននៃសមាសធាតុនីមួយៗនៃទ្រព្យ និងបរិក្ខារ។

រំលស់ ត្រូវបានទទួលស្គាល់ចាប់ពីកាលបរិច្ឆេទដែលទ្រព្យ និងបរិក្ខារត្រូវបានតម្លើង និងអាចប្រើប្រាស់បាន ឬទ្រព្យសកម្មដែលបានសាងសង់ ចាប់ពីការិយបរិច្ឆេទដែលទ្រព្យសកម្មនោះត្រូវបានបញ្ចប់ និងអាចប្រើប្រាស់បាន ។

អាយុកាលប្រើប្រាស់ប៉ាន់ស្មានសម្រាប់ការិយបរិច្ឆេទមានដូចខាងក្រោម៖

| | ឆ្នាំ |
|---|---|
| គ្រឿងជួសជុល និងកែលម្អ | 5 |
| បរិក្ខារការិយាល័យ | 5 |
| គ្រឿងសង្ហារឹម គ្រឿងបំពាក់ និងបរិក្ខារ | 5 |
| បរិក្ខារកុំព្យូទ័រ | 3 |
| យានយន្ត | 5 |

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ ត្រូវបានវាយតម្លៃឡើងវិញនៅចុង នៃការិយបរិច្ឆេទ និងត្រូវបានកែតម្រូវប្រសិនបើសមស្រប។

## 3.10. ទ្រព្យសកម្មអរូបី

ទ្រព្យអរូបីដែលរួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រ និងថ្លៃដើមពាក់ព័ន្ធ ត្រូវបានចែងនៅថ្លៃដើមដករំលស់បង្គរ និងការខាតបង់ឱនភាពនៃតម្លៃ។ អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ ត្រូវបានធ្វើមូលធនកម្មផ្អែកតាមថ្លៃដើមដែលកើតឡើងដើម្បីទិញកម្មវិធីកុំព្យូទ័រជាក់លាក់មួយ និងនាំយកវាទៅប្រើប្រាស់។

ទ្រព្យអរូបីត្រូវបានរំលស់លើអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃ 5ឆ្នាំ ដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរ។ ថ្លៃដើមទាក់ទងនឹងការអភិវឌ្ឍន៍ ឬថែរក្សានៃកម្មវិធីកុំព្យូទ័រ ត្រូវបានទទួលស្គាល់ជាចំណាយនៅពេលកើតឡើង។

### 3.11. ឱនភាពនៃតម្លៃ នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

នៅរៀងរាល់កាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ សម្ព័ន្ធធនាគារនិងធនាគារវាយតម្លៃថាតើមានសូចនាករ ដែលទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុអាចមានឱនភាពនៃតម្លៃដែរ ឬទេ។ នៅពេលសូចនាករនៃឱនភាពនៃតម្លៃកើតមានឡើង ឬនៅពេលការធ្វើតេស្តឱនភាពនៃតម្លៃប្រចាំ ឆ្នាំសម្រាប់ទ្រព្យសកម្មត្រូវបានតម្រូវឲ្យមាន នោះសម្ព័ន្ធធនាគារនិងធនាគារធ្វើការប៉ាន់ស្មានជាផ្លូវការនូវចំនួនដែលអាចប្រមូលបានមកវិញ។

តម្លៃដែលអាចប្រមូលបានមកវិញ គឺជាចំនួនធំជាងនៃ (ឬ ឯកតាបង្កើតសាច់ប្រាក់ CGU) តម្លៃសមស្របដកថ្លៃដើមក្នុងការលក់ទ្រព្យសកម្ម និងតម្លៃប្រើប្រាស់ និងត្រូវបានកំណត់សម្រាប់ទ្រព្យសកម្មមួយ លុះត្រាតែទ្រព្យសកម្មពុំបានបង្កើតលំហូរទឹកប្រាក់ដែលពឹងផ្អែកយ៉ាងខ្លាំងពីទ្រព្យសកម្ម ឬក្រុមនៃទ្រព្យសកម្មដែលក្នុងករណីតម្លៃដែលអាចប្រមូលបានមកវិញត្រូវបានវាយតម្លៃជាផ្នែកមួយនៃ CGU ដែលវាទាក់ទង។

នៅពេលដែលតម្លៃយោងនៃនៃទ្រព្យសកម្ម (ឬ CGU) លើសតម្លៃដែលអាចប្រមូលបានមកវិញរបស់វា នោះទ្រព្យសកម្ម (ឬ CGU) ត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ និងត្រូវលុបចោលទៅជាតម្លៃដែលអាចប្រមូលបានមកវិញរបស់វា។ ក្នុងការវាយតម្លៃ តម្លៃប្រើប្រាស់ លំហូរទឹកប្រាក់អនាគតដែលបានប៉ាន់ស្មានត្រូវបានធ្វើអប្បហារទៅជាតម្លៃបច្ចុប្បន្ន ដោយប្រើប្រាស់អត្រាអប្បហារមិនគិតពន្ធដែលឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលានៃសាច់ប្រាក់ និងហានិភ័យជាក់លាក់លើទ្រព្យសកម្ម (ឬ CGU)។

ការខាតបង់ឱនភាពនៃតម្លៃ ត្រូវបានគិតជាចំណាយលើប្រតិបត្តិការ នៅក្នុងការិយបរិច្ឆេទដែលវាបានកើតឡើង។ ការវាយតម្លៃ ត្រូវបានធ្វើឡើងនៅរៀងរាល់កាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុទៅតាមថាតើមានសូចនាករដែលពីមុន បានទទួលស្គាល់ការខាតបង់ឥណទានអាចនឹងមិនមានកើតឡើងតទៅទៀត ឬអាចថយចុះ។ ប្រសិនបើសូចនាករដូចនេះកើតមានឡើង នោះតម្លៃដែលអាចប្រមូលបានមកវិញត្រូវបានប៉ាន់ស្មាន។

ការខាតបង់ឥណទានដែលត្រូវបានទទួលស្គាល់ពីមុន ត្រូវបានកត់បញ្ច្រាស់ប្រសិនបើវាមានការផ្លាស់ប្តូរក្នុងការប៉ាន់ស្មាន ដែលប្រើដើម្បីកំណត់តម្លៃដែលអាចប្រមូលបានមកវិញរបស់ទ្រព្យសកម្មចាប់តាំងពីការខាតបង់ឥណទានពីមុនត្រូវបានទទួលស្គាល់។

ប្រសិនបើមានករណីបែបនេះ តម្លៃយោងនៃទ្រព្យសកម្ម (ឬ CGU) ត្រូវបានកើនឡើងទៅកាន់តម្លៃដែលអាចប្រមូលបានមកវិញ។ នៅពេលចំនួនកើនឡើងនោះ មិនអាចលើសតម្លៃយោងដែលត្រូវបានកំណត់កាត់កងជាមួយនឹងរំលស់ ពុំមានការខាតបង់ឥណទានត្រូវបានទទួលស្គាល់សម្រាប់ទ្រព្យសកម្មនៅការិយបរិច្ឆេទមុនឡើយ។ ការកត់ត្រាបញ្ច្រាស់បែបនេះ ត្រូវបានទទួលស្គាល់នៅចំណេញ ឬខាតលុះត្រាតែទ្រព្យសកម្ម (ឬ CGU) ត្រូវបានស្ថិតនៅតម្លៃដែលបានវាយតម្លៃឡើងវិញ ដែលក្នុងករណីការកត់ត្រាបញ្ច្រាស់ត្រូវបានចាត់ទុកជាការវាយតម្លៃកើនឡើង។ បន្ទាប់ពីការកត់ត្រាបញ្ច្រាស់បែបនេះ ចំណាយរំលស់ត្រូវបានកែតម្រូវនៅការិយបរិច្ឆេទអនាគតដើម្បីបែងចែកតម្លៃយោងដែលបានកែប្រែរបស់ទ្រព្យសកម្មដកតម្លៃកាកសំណល់តាមមូលដ្ឋានជាប្រព័ន្ធពេញអាយុកាលដែលនៅសល់របស់ទ្រព្យ។

### 3.12. ភតិសន្យា

នៅពេលចាប់ផ្តើមនៃកិច្ចសន្យា សម្ព័ន្ធធនាគារនិងធនាគារវាយតម្លៃថាតើកិច្ចសន្យា គឺជា ឬមានភតិសន្យា ឬទេ។ កិច្ចសន្យា គឺមានភតិសន្យា ប្រសិនបើកិច្ចសន្យាផ្តល់សិទ្ធិក្នុងការគ្រប់គ្រងការប្រើប្រាស់នៃទ្រព្យសកម្ម ដែលបានកំណត់ក្នុងការិយបរិច្ឆេទមួយជាថ្នូរនឹងការទូទាត់។

ដើម្បីវាយតម្លៃថាតើសិទ្ធិក្នុងការគ្រប់គ្រងការប្រើប្រាស់នៃទ្រព្យសកម្ម ដែលបានកំណត់ សម្ព័ន្ធធនាគារនិងធនាគារវាយតម្លៃថាតើ៖

- កិច្ចសន្យារួមបញ្ចូលការប្រើប្រាស់នៃទ្រព្យសកម្មដែលបានកំណត់ ដែលនេះអាចនឹងបញ្ជាក់យ៉ាងច្បាស់លាស់ ឬដោយប្រយោល ហើយគួរតែមានភាពខុសគ្នាជារូបរាង ឬតំណាងឲ្យសមត្ថភាពទាំងអស់នៃទ្រព្យសកម្មដែលខុសប្លែកនោះ។ ប្រសិនបើអ្នកផ្គត់ផ្គង់ មានសិទ្ធិជំនួសសំខាន់ៗពេញមួយរយៈពេលនៃការប្រើប្រាស់ នោះទ្រព្យសកម្មមិនត្រូវបានកំណត់អត្តសញ្ញាណទេ

- សម្ព័ន្ធធនាគារនិងធនាគារ មានសិទ្ធិក្នុងការទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចទាំងអស់យ៉ាងច្រើនពីការប្រើប្រាស់នៃទ្រព្យសកម្មក្នុងអំឡុងពេលនៃការប្រើប្រាស់ និង

- សម្ព័ន្ធធនាគារនិងធនាគារមានសិទ្ធិក្នុងការដឹកនាំការប្រើប្រាស់នៃទ្រព្យសកម្ម។ សម្ព័ន្ធធនាគារនិងធនាគារមានសិទ្ធិនេះនៅពេលពួកគេមានសិទ្ធិក្នុងការសម្រេចចិត្ត ដែលទាក់ទងយ៉ាងខ្លាំងទៅនឹងការផ្លាស់ប្តូរពីរបៀប និងសម្រាប់គោលបំណងអ្វីដែលទ្រព្យសកម្មត្រូវបានប្រើ។ នៅក្នុងករណី ដែលការសម្រេចចិត្តទាំងអស់របៀប និងសម្រាប់គោលបំណងអ្វីដែលទ្រព្យសកម្មត្រូវបានប្រើ ត្រូវបានកំណត់ជាមុន នោះសម្ព័ន្ធធនាគារនិងធនាគារមានសិទ្ធិដឹកនាំការប្រើប្រាស់ទ្រព្យសកម្មប្រសិនបើចំណុចមួយណាក៏ដោយក្នុងចំណោមខាងក្រោម៖

  - សម្ព័ន្ធធនាគារនិងធនាគារមានសិទ្ធិដើម្បីធ្វើប្រតិបត្តិការទ្រព្យសកម្ម ឬ
  - សម្ព័ន្ធធនាគារនិងធនាគារ បានរៀបចំទ្រព្យសកម្មតាមរបៀបមួយដែលកំណត់ទុកជាមុននូវរបៀប និងគោលបំណងអ្វីដែលទ្រព្យនឹងត្រូវប្រើ។

នៅពេលចាប់ផ្តើម ឬ ពេលវាយតម្លៃឡើងវិញនៃកិច្ចសន្យា ដែលមានភតិសន្យា និងសមាសធាតុមិនមែនជាភតិសន្យា សម្ព័ន្ធធនាគារនិងធនាគារបែងចែកការទូទាត់មកវិញ ក្នុងកិច្ចសន្យាទៅកាន់សមាសធាតុភតិសន្យានីមួយៗ និងរួមបញ្ចូលគ្នានៃសមាសធាតុ មិនមែនភតិសន្យាតាមមូលដ្ឋាននៃថ្លៃដាច់ដោយឡែក។ ទោះបីជាយ៉ាងណា សម្រាប់ភតិសន្យានៃដី និងអាគារដែលជាភតិសន្យា សម្ព័ន្ធធនាគារនិងធនាគារបានជ្រើសរើសមិនបែងចែកនូវសមាសធាតុមិនមែនភតិសន្យា និងចាត់ទុកសមាសធាតុភតិសន្យា និងមិនមែនភតិសន្យាជាសមាសធាតុភតិសន្យាតែមួយ។

#### 3.12.1. ភតិសន្យាដែលសម្ព័ន្ធធនាគារនិងធនាគារជាភតិកៈ

ការរៀបចំផ្តល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ប្រសិនបើមួយក្នុងចំណោមចំណុចខាងក្រោមបានឆ្លើយតប៖

- អ្នកទិញមានលទ្ធភាព ឬសិទ្ធិក្នុងការធ្វើប្រតិបត្តិការទ្រព្យសកម្មក្នុងពេលដែលទទួលបាន ឬត្រួតត្រាច្រើនជាងចំនួនមិនសំខាន់នៃលទ្ធផល។

- អ្នកទិញមានលទ្ធភាព ឬសិទ្ធិក្នុងការត្រួតត្រាលទ្ធភាពបានប្រើប្រាស់ជារូបវន្តចំពោះទ្រព្យសកម្មក្នុងពេលដែលទទួលបាន និងត្រួតត្រាច្រើនជាងចំនួនមិនសំខាន់នៃលទ្ធផល ឬ

- ហេតុការណ៍ពិត និងកាលៈទេសៈដែលបានបង្ហាញថាវាមិនអាចកើតឡើងទេដែលភាគីផ្សេងទៀតនឹងយកច្រើនជាងចំនួនមិនសំខាន់នៃលទ្ធផល ហើយថ្លៃក្នុងមួយឯកតា គឺមិនថេរក្នុងមួយឯកតានៃធាតុចេញ និងមិនស្មើនឹងថ្លៃក្នុងមួយឯកតានៃធាតុចេញនៃទីផ្សារបច្ចុប្បន្ន។

សម្ព័ន្ធធនាគារនិងធនាគារ ទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យានៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា។ សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានវាស់វែងលើកដំបូងនៅថ្លៃដើម ដែលរួមមានចំនួនដំបូងនៃបំណុលភតិសន្យា ដែលបានកែតម្រូវសម្រាប់ការទូទាត់ភតិសន្យាផ្សេងៗ ដែលបានធ្វើឡើងនៅ ឬមុនកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា បូកនឹងថ្លៃដើមផ្ទាល់ផ្សេងៗដែលកើតឡើង និងថ្លៃដើមក្នុងការកម្ទេចចោល ឬដកចេញនូវទ្រព្យសកម្មនោះដែលប៉ាន់ស្មាន ឬ ក្នុងការស្តារឡើងវិញនៃទ្រព្យសកម្ម ឬទីកន្លែងដែលទ្រព្យនោះស្ថិតនៅ ដកជាមួយនឹងភតិសន្យាដែលទទួលបាន។

សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានរំលស់ជាបន្តបន្ទាប់ ដោយប្រើប្រាស់វិធីរំលស់ថេរចាប់ពីកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា រហូតដល់ថ្ងៃបញ្ចប់មុនគេរវាងអាយុកាលប្រើប្រាស់នៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬទីបញ្ចប់នៃរយៈពេលជួល។

អាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកំណត់តាមមូលដ្ឋានដូចគ្នាដូចទ្រព្យ និងបរិក្ខារ។ បន្ថែមពីនេះសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកាត់បន្ថយជារៀងរាល់ការិយបរិច្ឆេទ ដោយការខាតបង់ឱនភាពនៃតម្លៃ ប្រសិនបើមាន និងត្រូវបានកែតម្រូវសម្រាប់ការវាស់វែងជាក់លាក់ឡើងវិញនៃបំណុលភតិសន្យា។

អាយុកាលប្រើប្រាស់ប៉ាន់ស្មានសម្រាប់ការិយបរិច្ឆេទបច្ចុប្បន្នមានដូចខាងក្រោម៖

- អាគារ និងការិយាល័យសាខា 2 – 15 ឆ្នាំ

បំណុលភតិសន្យាត្រូវបានវាស់វែងដំបូងនៅតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាដែលមិនត្រូវបានបង់នៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា និងត្រូវបានធ្វើអប្បហារដោយប្រើប្រាស់អត្រាការប្រាក់បង្កប់ នៅក្នុងភតិសន្យា ឬប្រសិនបើអត្រានេះមិនទាន់អាចកំណត់បាននៅឡើយ នោះអត្រាកម្ចីកើនឡើងរបស់ភតិកៈនឹងត្រូវបានប្រើជំនួស។ ជាទូទៅសម្ព័ន្ធធនាគារនិងធនាគារ ប្រើប្រាស់អត្រាកម្ចីកើនឡើងរបស់ពួកគេជាអត្រាអប្បហារ។

ការទូទាត់ភតិសន្យារួមបញ្ចូលនៅក្នុងការវាស់វែងនៃបំណុលភតិសន្យាដែលរួមបញ្ចូល៖

- ការទូទាត់ភតិសន្យាថេរ រួមមានការចំណាយថេរ

- ការទូទាត់ភតិសន្យាប្រែប្រួលអថេរ ដែលផ្អែកលើសន្ទស្សន៍ ឬអត្រាមួយ ដែលត្រូវបានវាស់វែងដំបូងដោយប្រើប្រាស់សន្ទស្សន៍ ឬអត្រានៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា។

- ចំនួនដែលរំពឹងទុកថានឹងត្រូវបង់ក្រោមតម្លៃកាកសំណល់ធានា និង

- ថ្លៃដែលអនុវត្ត ក្រោមជម្រើសទិញដែលធនាគារច្បាស់ថានឹងអនុវត្ត ការទូទាត់ភតិសន្យានៅក្នុងការិយបរិច្ឆេទបន្តដែលអាចជ្រើសរើស ប្រសិនបើសម្ព័ន្ធធនាគារនិងធនាគារច្បាស់ថានឹងអនុវត្តជម្រើសក្នុងការជួលបន្ត និងការពិន័យសម្រាប់ការបញ្ចប់មុននៃភតិសន្យា លុះត្រាតែសម្ព័ន្ធធនាគារនិងធនាគារច្បាស់ថានឹងមិនបញ្ចប់មុនកាលកំណត់។

បំណុលភតិសន្យា ត្រូវបានវាស់វែងនៅថ្ងៃដើមរំលស់ ដោយប្រើប្រាស់ប្រាស់វិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។ វាត្រូវបានគេវាស់វែងឡើងវិញ នៅពេលដែលមានការផ្លាស់ប្តូរនូវរយៈពេលនៃភតិសន្យា ការផ្លាស់ប្តូរក្នុងការវាយតម្លៃនៃជម្រើសក្នុងការទិញទ្រព្យសកម្មដែលមាន ការផ្លាស់ប្តូរ ការទូទាត់នាពេលអនាគតដែលកើតចេញពីការផ្លាស់ប្តូរនូវសន្ទស្សន៍ ឬអត្រា ឬប្រសិនបើមានការផ្លាស់ប្តូរនៃការប៉ាន់ស្មាននៃតម្លៃរំពឹងថានឹងទូទាត់សងក្រោមតម្លៃកាកសំណល់ធានារបស់សម្ព័ន្ធធនាគារនិងធនាគារ។

នៅពេលដែលបំណុលភតិសន្យាត្រូវបានវាស់វែងឡើងវិញក្នុងវិធីបែបនេះ ការកែតម្រូវដែលស្របគ្នានឹងត្រូវបានធ្វើឡើងទៅលើតម្លៃយោងនៃសិទ្ធប្រើប្រាស់ទ្រព្យសកម្ម ឬត្រូវបានកត់ត្រានៅក្នុងចំណេញ និងខាតប្រសិនបើតម្លៃយោងនៃសិទ្ធប្រើប្រាស់ទ្រព្យសកម្មបានថយចុះដល់សូន្យ។

### 3.12.2. ភតិសន្យារយៈពេលខ្លី និងភតិសន្យានៃទ្រព្យសកម្មមានតម្លៃទាប

សម្ព័ន្ធធនាគារនិងធនាគារបានជ្រើសរើសមិនទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យាសម្រាប់ភតិសន្យារយៈពេលខ្លីដូចជាម៉ាស៊ីនដែលមានរយៈពេលជួល 12 ខែ ឬតិចជាងនេះ និងទ្រព្យសកម្មមានតម្លៃទាប។ សម្ព័ន្ធធនាគារនិងធនាគារទទួលស្គាល់ការទូទាត់ការទូទាត់ភតិសន្យាដែលទាក់ទងជាមួយនឹងភតិសន្យាទាំងនេះជាចំណាយតាមមូលដ្ឋានថេរលើរយៈពេលភតិសន្យា។

## 3.13. អត្ថប្រយោជន៍របស់និយោជិត

### 3.13.1. សំវិធានធនសម្រាប់ប្រាក់បំណាច់អតីតភាពការងារ

នៅថ្ងៃទី21 ខែកញ្ញា ឆ្នាំ2018 ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (“ ក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ”) បានចេញប្រកាសលេខ 443 ស្តីពីការទូទាត់ប្រាក់អតីតភាពដល់សហគ្រាសគ្រឹះស្ថាន និងអ្នកទាំងឡាយណាដែលមានចែងក្នុងមាត្រា 89 (ថ្មី) នៃច្បាប់ស្តីពីការងារ។ ចំពោះសហគ្រាសក្រៅពីសហគ្រាសវាយនភណ្ឌកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ប្រកាសតម្រូវឲ្យមានប្រាក់អតីតភាពអតីតកាល (មុនពេលចេញសេចក្តីប្រកាស) ដែលស្មើនឹងដប់ប្រាំថ្ងៃ (15) ថ្ងៃនៃប្រាក់ឈ្នួលរបស់និយោជិត។

នៅថ្ងៃទី22 ខែមីនា ឆ្នាំ2019 ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីណែនាំលេខ 042/19 ដើម្បីពន្យារពេលការទូទាត់ប្រាក់អតីតភាពអតីតកាល ដែលចាប់ផ្តើមពី ខែធ្នូ ឆ្នាំ2021 ហើយត្រូវបង់ដូចខាងក្រោម៖

- ស្មើនឹងបីថ្ងៃដែលត្រូវបង់រៀងរាល់ ខែមិថុនា និង
- ស្មើនឹងបីថ្ងៃដែលបង់រៀងរាល់ ខែធ្នូ។

ប្រាក់អតីតភាពការងារដែលមានអតីតកាលមិនត្រូវលើសពី 6ខែ នៃប្រាក់ឈ្នួលជាមធ្យមរបស់និយោជិតនៃឆ្នាំនីមួយៗ។ និយោជិតមិនមានសិទ្ធិទទួលបានប្រាក់ឈ្នួលទេ ប្រសិនបើពួកគេលាលែងមុនពេលទទួលបាន។

ចំនួនទឹកប្រាក់ដែលបានប៉ាន់ស្មាន នៃការទូទាត់អតីតភាពការងារ ត្រូវបានទទួលស្គាល់ក្រោមទ្រព្យបំណុលផ្សេងៗ (កំណត់សម្គាល់លេខ 19)។

**3.13.2. អត្ថប្រយោជន៍របស់និយោជិតរយៈពេលខ្លី**

អត្ថប្រយោជន៍របស់និយោជិតរយៈពេលខ្លី ជាចំណាយដែលទាក់ទងនឹងសេវាដែលបានផ្តល់ឲ្យ។ ទ្រព្យអកម្ម ត្រូវបានទទួលស្គាល់សម្រាប់ចំនួនដែលបានរំពឹងទុកក្នុងការបង់ ប្រសិនបើសម្ព័ន្ធធនាគារនិងធនាគារមានកាតព្វកិច្ចផ្លូវច្បាប់ ឬស្ថាបនាបច្ចុប្បន្នក្នុងការទូទាត់ចំនួននេះដែលជាលទ្ធផលនៃសេវាពីមុនដែលបានផ្តល់ដោយនិយោជិត និងកាតព្វកិច្ចដែលអាចប៉ាន់ស្មានគួរឲ្យជឿជាក់បាន។

**3.13.3. អត្ថប្រយោជន៍របស់និយោជិតរយៈពេលវែងផ្សេងៗ**

កាតព្វកិច្ចសុទ្ធ របស់សម្ព័ន្ធធនាគារនិងធនាគារចំពោះអត្ថប្រយោជន៍របស់និយោជិតរយៈពេលវែង គឺជាចំនួននៃអត្ថប្រយោជន៍ ដែលនិយោជិតបានទទួលជាការតបស្នងនឹងសេវារបស់ពួកគេនៅការិយបរិច្ឆេទបច្ចុប្បន្ន និងអតីតកាល។ អត្ថប្រយោជន៍នោះត្រូវបានធ្វើអប្បហារ ដើម្បីកំណត់តម្លៃបច្ចុប្បន្នរបស់វា។ ការវាស់វែងឡើងវិញត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតក្នុងការិយបរិច្ឆេទដែលវាបានកើតឡើង។

## 3.14. សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលសម្ព័ន្ធធនាគារនិងធនាគារ មានកាតព្វកិច្ចស្របច្បាប់ ឬស្ថាបនាដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងមក ហើយវាអាចទៅរួចដែលថាលំហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ចនឹងត្រូវបានទាមទារ ដើម្បីដោះស្រាយកាតព្វកិច្ចនោះ។ ប្រសិនបើផលប៉ះពាល់មានភាពសារវន្ត សំវិធានធនត្រូវបានកំណត់ដោយការធ្វើអប្បហារ លំហូរទឹកប្រាក់នាពេលអនាគតដែលរំពឹងទុកក្នុងអត្រាមុនគិតពន្ធ ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃសាច់ប្រាក់នៃពេលវេលា ហើយក្នុងករណីដែលសមស្រប ហានិភ័យជាក់លាក់ចំពោះបំណុល។ ចំនួននៅសល់ពីការធ្វើអប្បហារ ត្រូវបានទទួលស្គាល់ជាថ្លៃដើមហិរញ្ញវត្ថុ។

## 3.15. ប្រាក់បញ្ញើពីអតិថិជន និងធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ

ប្រាក់បញ្ញើពីអតិថិជន និងធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ត្រូវបានវាស់វែងដំបូងតាមតម្លៃទីផ្សារដកការកើនឡើងផ្ទាល់នៃថ្លៃដើមប្រតិបត្តិការ និងវាស់វែងបន្ទាប់តាមរំលស់ថ្លៃដើម ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

## 3.16. ប្រាក់កម្ចី និងអនុបំណុល

ប្រាក់កម្ចី និងអនុបំណុល ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប ដកថ្លៃដើមប្រតិបត្តិការបន្ថែមដោយផ្ទាល់ និងវាស់វែង បន្ទាប់តាមរំលស់ថ្លៃដើម ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

## 3.17. ចំណូល/ចំណាយការប្រាក់

### 3.17.1. អត្រាការប្រាក់ប្រសិទ្ធភាព

ចំណូល និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់នៅចំណេញ និងខាតដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ “អត្រាការប្រាក់ប្រសិទ្ធភាព” គឺជាអត្រាដែលធ្វើអប្បហារយ៉ាងពិតប្រាកដលើការទូទាត់សាច់ប្រាក់អនាគត ឬចំណូលតាមរយៈអាយុកាលហិរញ្ញវត្ថុដែលរំពឹងទុកទៅ៖

- តម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ
- ថ្លៃដើមរំលស់នៃបំណុលហិរញ្ញវត្ថុ

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព សម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ក្រៅពីទ្រព្យសកម្មដែលមានឱនភាពនៃតម្លៃឥណទានបានទិញ ឬបង្កើតឡើង សម្ព័ន្ធធនាគារនិងធនាគារប៉ាន់ស្មានលំហូរទឹកប្រាក់អនាគតដោយពិចារណាលើលក្ខខណ្ឌកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនមែន ECL។ សម្រាប់ទ្រព្យសកម្មដែលមានឱនភាពនៃតម្លៃឥណទានបានទិញ ឬបង្កើតឡើង អត្រាការប្រាក់ប្រសិទ្ធភាពដែលជាការកែតម្រូវឥណទាន ត្រូវបានគណនាដោយប្រើប្រាស់លំហូរទឹកប្រាក់អនាគតប៉ាន់ស្មានដែលរួមមាន ECL។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាពរួមមានថ្លៃដើមប្រតិបត្តិការ និងកម្រៃជើងសារ រួមទាំងពិន្ទុដែលបានបង់ ឬទទួលបានដែលជាផ្នែកសំខាន់នៃអត្រាការប្រាក់ប្រសិទ្ធភាព។ ថ្លៃដើមប្រតិបត្តិការរួមមានថ្លៃដើមកើនឡើងដែលកើតឡើងដោយផ្ទាល់លើការទិញ ឬចេញផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

### 3.17.2. ថ្លៃដើមរំលស់ និងតម្លៃយោងដុល

‘ថ្លៃដើមរំលស់’ នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យអកម្មហិរញ្ញវត្ថុ គឺជាចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យអកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងនៅពេលទទួលស្គាល់ដំបូងដកនឹងការទូទាត់ប្រាក់ដើម ហើយបូក ឬដករំលស់បង្គរដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព នៃភាពខុសគ្នារវាងតម្លៃដំបូង និងតម្លៃកាលវសាន្ត សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានកែតម្រូវសម្រាប់សំវិធានធននៃការខាតបង់ឥណទានដែលបានរំពឹងទុក។

“តម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ” គឺជាថ្លៃដើមរំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុមុនពេលកែតម្រូវសម្រាប់សំវិធានធននៃការខាតបង់ឥណទានដែលបានរំពឹងទុក។

### 3.17.3. ការគណនាចំណូល និងចំណាយការប្រាក់

អត្រាការប្រាក់ប្រសិទ្ធភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យអកម្មហិរញ្ញវត្ថុត្រូវបានគណនានៅពេលទទួលស្គាល់ដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យអកម្មហិរញ្ញវត្ថុ។

នៅក្នុងការគណនាចំណូល និងចំណាយការប្រាក់ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានអនុវត្តលើតម្លៃយោងដុលនៃទ្រព្យសកម្ម (នៅពេលទ្រព្យសកម្ម មិនបានថយចុះនៃឥណទាន) ឬលើថ្លៃដើមរំលស់នៃទ្រព្យអកម្ម។

អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានត្រួតពិនិត្យឡើងវិញ ជាលទ្ធផលនៃការប៉ាន់ស្មានឡើងវិញជារៀងរាល់ការិយបរិច្ឆេទនៃលំហូរទឹកប្រាក់ នៃឧបករណ៍អត្រាអណ្តែត ដើម្បីឆ្លុះបញ្ចាំងបម្រែបម្រួលក្នុងអត្រាទីផ្សារនៃការប្រាក់។ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានពិនិត្យឡើងវិញ សម្រាប់ការកែម្រូវការពារហានិភ័យតម្លៃសមស្រប នៅកាលបរិច្ឆេទរំលស់នៃការកែម្រូវការពារហានិភ័យចាប់ផ្តើម។

ទោះបីជាយ៉ាងណា ទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានថយចុះនៃឥណទាន បន្ទាប់ពីការទទួលស្គាល់ដំបូង នោះចំណូលការប្រាក់ត្រូវបានគណនា ដោយអនុវត្តអត្រាប្រាក់ប្រសិទ្ធភាពចំពោះថ្លៃដើមរំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ។ ប្រសិនបើទ្រព្យសកម្មលែងមានការថយចុះនៃឥណទានទៅទៀតនោះ ការគណនាចំណូលការប្រាក់នឹងត្រឡប់ទៅតាមមូលដ្ឋានដុលវិញ។

សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលធ្លាប់មានការថយចុះនៃឥណទាន នៅពេលទទួលស្គាល់ដំបូង នោះចំណូលការប្រាក់ត្រូវបានគណនា ដោយអនុវត្តអត្រាការប្រាក់ប្រសិទ្ធភាពដែលមានការថយចុះនៃឥណទានទៅថ្លៃដើមរំលស់នៃទ្រព្យសកម្ម។ ការគណនាចំណូលការប្រាក់នឹងមិនត្រឡប់ទៅតាមមូលដ្ឋានដុលវិញនោះទេ បើទោះបីជាហានិភ័យឥណទាននៃទ្រព្យសកម្មមានភាពប្រសើរឡើង។

**3.17.4. ការបង្ហាញ**

ចំណូលការប្រាក់ដែលបានគណនាដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព និងដែលបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ រួមមានការប្រាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យអកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាមរំលស់ថ្លៃដើម។

ចំណាយការប្រាក់ដែលបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួមមាន ទ្រព្យអកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាមរំលស់ថ្លៃដើម ។

## 3.18. សេវា និងកម្រៃជើងសារ

ចំណូល និងចំណាយនៃសេវា និងកម្រៃជើងសារ ដែលមានសារៈសំខាន់ចំពោះអត្រាការប្រាក់ប្រសិទ្ធភាពលើទ្រព្យសកម្ម ឬទ្រព្យអកម្មហិរញ្ញវត្ថុត្រូវបានរាប់បញ្ចូលក្នុងអត្រាការប្រាក់ប្រសិទ្ធភាព។

ប្រាក់ចំណូលពីកម្រៃជើងសារផ្សេងៗ រួមមានទាំងថ្លៃសេវាគណនី ត្រូវបានទទួលស្គាល់នៅពេលសេវាកម្មពាក់ព័ន្ធត្រូវបានបំពេញ។

កិច្ចសន្យាជាមួយអតិថិជនដែលជាលទ្ធផល ធ្វើឲ្យមានការទទួលស្គាល់ឧបករណ៍ហិរញ្ញវត្ថុ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារនិងធនាគារអាចស្ថិតនៅផ្នែកខ្លះនៃវិសាលភាពនៃ ស.រ.ហ.អ.ក 9 និងផ្នែកខ្លះនៃវិសាលភាពនៃ ស.រ.ហ.អ.ក 15។ ប្រសិនបើមានករណីនេះ សម្ព័ន្ធធនាគារនិងធនាគារជាដំបូងនឹងអនុវត្ត ស.រ.ហ.អ.ក 9 ដើម្បីញែក និងវាស់វែងផ្នែកនៃកិច្ចសន្យាដែលស្ថិតក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក 9 និងបន្ទាប់មកអនុវត្ត ស.រ.ហ.អ.ក 15 ចំពោះផ្នែកដែលនៅសល់។

## 3.19. ពន្ធលើប្រាក់ចំណេញ

ចំណាយពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណេញត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត លើកលែងតែពន្ធនេះទាក់ទងទៅនឹងធាតុដែលត្រូវទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន ឬលទ្ធផលលម្អិតផ្សេងៗ។

សម្ព័ន្ធធនាគារនិងធនាគារបានកំណត់ថា ការប្រាក់ និងការដាក់ពិន័យទាក់ទងនឹងពន្ធលើប្រាក់ចំណេញ រួមបញ្ចូលបំណកស្រាយពន្ធមិនច្បាស់លាស់ មិនបំពេញទៅនឹងនិយមន័យនៃពន្ធលើប្រាក់ចំណេញ ដូច្នេះហើយវាត្រូវបានកត់ត្រាក្រោមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា ("ស.គ.អ.ក") 37 សំវិធានធន បំណុលយថាភាព និងទ្រព្យសកម្មយថាភាព ហើយត្រូវបានទទួលស្គាល់ថាជាការចំណាយដែលពាក់ព័ន្ធ "ការចំណាយផ្សេងទៀត"។

### 3.19.1. ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ រួមមានពន្ធដែលត្រូវបង់ ឬទទួល លើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍ និងនិយ័តភាពណាមួយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ។

### 3.19.2. ពន្ធពន្យារ

ពន្ធពន្យារត្រូវបានទទួលស្គាល់ដោយផ្អែកលើភាពលម្អៀងបណ្តោះអាសន្នរវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវទទួលស្គាល់ ចំពោះការខាតបង់ពន្ធមិនទាន់បានប្រើប្រាស់ និងភាពលម្អៀងបណ្តោះអាសន្នដែលអាចកាត់កងបាន ត្រឹមកម្រិតដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត អាចប្រើប្រាស់សម្រាប់កាត់កងជាមួយភាពលម្អៀងបណ្តោះអាសន្ននោះបាន។

ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានត្រួតពិនិត្យ នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានកាត់បន្ថយក្នុងករណីមិនអាចប្រើប្រាស់នូវអត្ថប្រយោជន៍ ពន្ធទាំងនោះបាន។ ការកាត់បន្ថយនោះត្រូវកត់ត្រាបញ្ច្រាសមកវិញនៅពេល ដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតមានលក្ខណៈប្រសើរឡើង។

ពន្ធពន្យារ ជាទ្រព្យសកម្មត្រូវបានវាស់វែងតាមអត្រាពន្ធ ដែលរំពឹងថានឹងត្រូវប្រើចំពោះភាពលម្អៀងបណ្តោះអាសន្ន នៅពេលដែលវាអាចប្រើប្រាស់បាន ឬកាត់កងបាន ដោយប្រើអត្រាពន្ធនៅកាលបរិច្ឆេទរាយការណ៍។

ការវាស់វែងពន្ធពន្យារ ឆ្លុះបញ្ចាំងនូវពន្ធដែល ធនាគាររំពឹងថាអាចប្រើប្រាស់បាន ឬអាចកាត់កងបាននូវតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល។

ពន្ធពន្យារជាទ្រព្យសកម្ម និងពន្ធពន្យារជាបំណុល អាចកាត់កងបានតែក្នុងករណីវាបានបំពេញលក្ខខណ្ឌជាក់លាក់ណាមួយ។

ប្រាក់ចំណេញរក្សាទុកតំណាងឲ្យប្រាក់ចំណេញបង្គរ របស់សម្ព័ន្ធធនាគារនិងធនាគារ ដកនឹងការប្រកាសភាគលាភ។

## 3.20. ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិ ត្រូវបានបង្កើតឡើងសម្រាប់ភាពខុសគ្នារវាងសំវិធានធនលើការខាតបង់ឥណទានដោយអនុលោមតាម ស.រ.ហ.អ.ក 9 និងបទប្បញ្ញត្តិស្របតាមប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា លេខ ធ7-017-344 ចុះថ្ងៃទី1 ខែធ្នូ ឆ្នាំ2017 និងសារាចរលេខ ធ7-018-001 ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2018 ស្តីពីចំណាត់ថ្នាក់នៃហានិភ័យឥណទាន និងការផ្តល់សំវិធានធនលើឱនភាពនៃតម្លៃ សម្រាប់ស្ថាប័នធនាគារ និងហិរញ្ញវត្ថុ។

សម្ព័ន្ធធនាគារនិងធនាគារបានប្រៀបធៀប សំវិធានធនតាមបទប្បញ្ញត្តិ ជាមួយសំវិធានធនដែលបានគណនាអនុលោមតាម ស.រ.ហ.អ.ក 9 និង

(i) ក្នុងករណីសំវិធានធនតាមបទប្បញ្ញត្តិដែលបានគណនា ទាបជាងសំវិធានធនដែលបានគណនាស្របតាម ស.រ.ហ.អ.ក 9 នោះគ្រឹះស្ថានធនាគារកត់ត្រាសំវិធានធនតាម ស.រ.ហ.អ.ក 9 និង

(ii) ក្នុងករណីសំវិធានធនតាមបទប្បញ្ញត្តិដែលបានគណនា ខ្ពស់ជាងសំវិធានធនដែលបានគណនាស្របតាម ស.រ.ហ.អ.ក 9 នោះគ្រឹះស្ថានធនាគារកត់ត្រាសំវិធានធនដែលបានគណនាស្របតាម CIFRS 9 និងផ្ទេរភាពខុសគ្នាពីគណនីប្រាក់ចំណេញបង្គរ ទៅគណនីទុនបម្រុងតាមបទប្បញ្ញត្តិ នៅក្នុងផ្នែកមូលធននៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ប្រកាសលើការធ្វើសំវិធានធនតាមបទប្បញ្ញត្តិនេះ តម្រូវឲ្យធនាគារ និងស្ថាប័នហិរញ្ញវត្ថុធ្វើការចាត់ថ្នាក់សម្ភាធឥណទានរបស់ខ្លួនទៅជា 5ថ្នាក់ និងផ្តល់នូវសំវិធានធនទូទៅ និងជាក់លាក់ដោយផ្អែកលើចំណាត់ថ្នាក់ឥណទានដូចខាងក្រោម៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃហួសកាលកំណត់ | អត្រាសំវិធានធន |
|---|---|---|
| ស្តង់ដា | 0 ទៅ 14ថ្ងៃ (រយៈពេលខ្លី)<br>0 ទៅ 29ថ្ងៃ (រយៈពេលវែង) | 1% |
| ឃ្លាំមើល | 15ថ្ងៃ ទៅ 30ថ្ងៃ (រយៈពេលខ្លី)<br>30ថ្ងៃ ទៅ 89ថ្ងៃ (រយៈពេលវែង) | 3% |
| ក្រោមស្តង់ដា | 31ថ្ងៃ ទៅ 60ថ្ងៃ (រយៈពេលខ្លី)<br>90ថ្ងៃ ទៅ 179ថ្ងៃ (រយៈពេលវែង) | 20% |
| សង្ស័យ | 61ថ្ងៃ ទៅ 90ថ្ងៃ (រយៈពេលខ្លី)<br>180ថ្ងៃ ទៅ 359ថ្ងៃ (រយៈពេលវែង) | 50% |
| បាត់បង់ | ពី 91ថ្ងៃ (រយៈពេលខ្លី)<br>360ថ្ងៃ ឬ ច្រើន (រយៈពេលវែង) | 100% |

### 3.21. ដើមទុន

ភាគហ៊ុនធម្មតាត្រូវបានចាត់ថ្នាក់ជាមូលធន។ ថ្លៃដើមកើនឡើងដែលកើតឡើងចំពោះការចេញផ្សាយនៃភាគហ៊ុនធម្មតាត្រូវបានទទួលស្គាល់ជាការបន្ថយពីមូលធន កាត់កងនឹងផលប៉ះពាល់ផ្សេងៗ នៃពន្ធ។ ភាគហ៊ុនផ្សេងៗទៀត ត្រូវបានចាត់ថ្នាក់ជាមូលធន និង/ឬជាទ្រព្យអកម្មលើសារធាតុ សេដ្ឋកិច្ចនៃឧបករណ៍ពិសេសមួយ។ ការចែកចាយទៅអ្នកកាន់កាប់នៃឧបករណ៍ហិរញ្ញវត្ថុដែលបានចាត់ថ្នាក់ជាឧបករណ៍មូលធនត្រូវបានកត់ដោយផ្ទាល់ទៅជាមូលធន។

### 3.22. ទ្រព្យសកម្មយថាភាព

ក្នុងករណីដែលមិនមានលទ្ធភាពដែលលំហូរចូលនៃផលប្រយោជន៍សេដ្ឋកិច្ចនឹងបានតម្រូវឲ្យមាន ឬចំនួនទឹកប្រាក់មិនអាចត្រូវបានប៉ាន់ប្រមាណបានទេ នោះទ្រព្យសកម្មមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនោះទេ និងត្រូវបានលាតត្រដាងជាទ្រព្យសកម្មជាយថាភាព លុះត្រាតែប្រូបាប៊ីលីតេនៃលំហូរអត្ថប្រយោជន៍សេដ្ឋកិច្ចមិនបានរាប់បញ្ចូល។ កាតព្វកិច្ចដែលអាចមាន ដែលវត្តមានរបស់វានឹងត្រូវបានបញ្ជាក់ ត្រឹមតែដោយការកើតឡើង ឬការមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគតមួយ ឬច្រើន ក៏ត្រូវបានលាតត្រដាងជាទ្រព្យសកម្មយថាភាពលុះត្រាតែប្រូបាប៊ីលីតេ នៃលំហូរអត្ថប្រយោជន៍សេដ្ឋកិច្ចមិនបានរាប់បញ្ចូល។

### 3.23. បំណុលយថាភាព

ក្នុងករណីដែលមិនមានលទ្ធភាពដែលលំហូរនៃអត្ថប្រយោជន៍សេដ្ឋកិច្ចនឹងបានតម្រូវឲ្យមាន ឬចំនួនទឹកប្រាក់ដែលមិនអាចប៉ាន់ស្មានបាន នោះកាតព្វកិច្ចមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនោះទេ និងត្រូវបានលាតត្រដាងជាបំណុលយថាភាព លុះត្រាតែប្រូបាប៊ីលីតេ នៃលំហូរអត្ថប្រយោជន៍សេដ្ឋកិច្ច មិនបានរាប់បញ្ចូល។ កាតព្វកិច្ចដែលអាចមានដែលវត្តមានរបស់វានឹងត្រូវបានបញ្ជាក់ត្រឹមតែដោយការកើតឡើង ឬ ការមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគតមួយ ឬច្រើន ក៏ត្រូវបានលាតត្រដាងជាបំណុលយថាភាពផងដែរ លុះត្រាតែប្រូបាប៊ីលីតេនៃលំហូរអត្ថប្រយោជន៍សេដ្ឋកិច្ចមិនបានរាប់បញ្ចូល។

### 3.24. ស្តង់ដាដែលបានចេញផ្សាយ និងធ្វើវិសោធនកម្ម ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព

ស្តង់ដាគណនេយ្យថ្មី និងវិសោធនកម្មមួយចំនួន ដែលនឹងត្រូវចូលជាធរមាន សម្រាប់របាយការណ៍ប្រចាំឆ្នាំពីថ្ងៃទី1 ខែមករា ឆ្នាំ2024 ដែលអាចអនុញ្ញាតឲ្យអនុវត្តមុនថ្ងៃចូលជាធរមាននេះ។ សម្ព័ន្ធធនាគារនិងធនាគារ មិនទាន់អនុវត្ត ស្តង់ដាគណនេយ្យថ្មី និងវិសោធនកម្មទាំងនេះសម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនៅឡើយទេ។

| ថ្ងៃចូលជាធរមាន | ស្តង់ដារគណនេយ្យថ្មី វិសោធនកម្ម និងបំណកស្រាយ |
|---|---|
| ថ្ងៃទី1 ខែមករា ឆ្នាំ2024 | ការចាត់ថ្នាក់បំណុលរយៈពេលខ្លី ឬរយៈពេលវែង (វិសោធនកម្មលើ ស.គ.អ.ក 1) |
| | បំណុលរយៈពេលវែង ដែលមានលក្ខខណ្ឌកំហិត (វិសោធនកម្មលើ ស.គ.អ.ក 1) |
| | ការរៀបចំហិរញ្ញប្បទានរបស់អ្នកផ្គត់ផ្គង់ (វិសោធនកម្មលើ ស.គ.អ.ក 7 និងស.រ.ហ.អ.ក 7) |
| | បំណុលភតិសន្យាក្នុងប្រតិបត្តិការលក់ និងជួលត្រឡប់វិញ (វិសោធនកម្មលើ ស.រ.ហ.អ.ក 16) |
| ថ្ងៃទី1 ខែមករា ឆ្នាំ2025 | កង្វះខាតនៃការដោះដូរ (វិសោធនកម្មលើ ស.គ.អ.ក 21) |

## 4. ការវិនិច្ឆ័យ និងការប៉ាន់ស្មានគណនេយ្យសំខាន់ៗ

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ អ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែលើការប៉ាន់ស្មាន ត្រូវបានទទួលស្គាល់តាមវិធីសាស្រ្តទស្សនៈវិស័យ។

ព័ត៌មានអំពីការវិនិច្ឆ័យ ដែលបានធ្វើឡើងក្នុងការអនុវត្តគោលនយោបាយគណនេយ្យដែលមានផលប៉ះពាល់ជាសារវន្ត លើចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ដូចខាងក្រោម៖

- កំណត់សម្គាល់ 3.4.2៖ ការចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ៖ ការវាយតម្លៃគម្រូអាជីវកម្មដែលទ្រព្យទាំងនោះត្រូវបានកាន់កាប់ និងការវាយតម្លៃថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាការទូទាត់តែប្រាក់ដើម និងការប្រាក់ (“SPPI”) លើចំនួនប្រាក់ដើមដែលនៅសល់។

- កំណត់សម្គាល់ 3.4.7៖ ការបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ថាតើហានិភ័យឥណទានលើទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់ដំបូង ដោយកំណត់វិធីសាស្រ្តសម្រាប់បញ្ចូលព័ត៌មានប្រមើលមើលអនាគតទៅក្នុងការវាស់វែងលើការខាតបង់ឥណទានរំពឹងទុក (“ECL”) និងការជ្រើសរើស និងការអនុម័តលើគម្រូដែលប្រើដើម្បីវាស់វែងលើការខាតបង់ឥណទានរំពឹងទុក។

